## ការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅកម្ពុជា

**វិវេចនានិពន្ធ**

ពីអ្នកលក់ដូរចំណីអាហារតាមចញ្ចើមផ្លូវ ទៅដល់អ្នករត់ម៉ូតូឌុប និងអ្នកធ្វើការនៅតាមផ្ទះនៅក្នុងប្រទេសកម្ពុជា អ្នកទាំងអស់នេះគឺជាចំណែករួមនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានទំហំធំធេង នៅក្នុងប្រទេសអាស៊ីអគ្នេយ៍មួយនេះ។ ការរួមចំណែកនៃអ្នកធ្វើការទាំងនេះជានិច្ចកាលមិនត្រូវបានគេទទួលស្គាល់ ឬមិនមានស្ថិតិគ្រប់គ្រាន់នោះទេ តែអ្នកធ្វើការទាំងនេះមាននៅគ្រប់កន្លែងដើម្បីផ្តល់ផលិតផល និងសេវាកម្មនានា ដែលមនុស្សស្ទើរតែគ្រប់គ្នាបានប្រើប្រាស់ ហើយជួយបំពេញមុខងារសេដ្ឋកិច្ច។

ប៉ុន្តែអ្នកធ្វើការក្រៅប្រព័ន្ធជានិច្ចកាលមិនត្រូវបានគេទទួលស្គាល់ និងចុះឈ្មោះក្នុងស្ថិតិទេ ដូច្នេះទើបពួកគេពុំបានទទួលអត្ថប្រយោជន៍ផ្សេងៗ គ្មានការធានារ៉ាប់រងសុខភាព ហើយតែងតែធ្វើការច្រើនម៉ោងនៅក្នុងល័ក្ខខ័ណ្ឌប្រកបដោយគ្រោះថ្នាក់ ។

វិវេចនានិពន្ធនេះដែលបានរៀបចំឡើងនៅឆ្នាំ ២០០៤ ផ្តល់នូវទស្សនៈយល់ដឹងអំពីអ្វីដែលបង្កើតទៅជាសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា និងសារៈសំខាន់នៃការធ្វើអោយមានការងារសមរម្យ ព្រមទាំងមធ្យោបាយនានាក្នុងការលើកកំពស់ការងារសមរម្យនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

---

វិវេចនានិពន្ធនេះគឺជាផ្នែកមួយនៃស៊េរីឯកសារដែលបានបោះពុម្ពផ្សាយដោយគំរោងស្តីពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងារ ដែលបានអនុវត្តដោយការិយាល័យអនុតំបន់របស់អង្គការ ILO ប្រចាំនៅទីក្រុងបាងកក ។ គំរោងនេះត្រូវបានឧបត្ថម្ភថវិកាដោយក្រសួងអភិវឌ្ឍន៍អន្តរជាតិ (DFID) នៃចក្រភពអង់គ្លេស ។

ISBN 92-2-818738-7
978-92-2-818738-0

២

ការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា : វិវេចនានិពន្ធ

ការិយាល័យ
ពលកម្ម
អន្តរជាតិ



# ការងារសមរម្យ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅកម្ពុជា

## វិវេចនានិពន្ធ

សេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងារ

កម្ពុជាស៊េរី | លេខ ២

សេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងារ

កម្ពុជាស៊េរី | លេខ ២

# ការងារសមរម្យ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ៖ វិភាគករណីសិក្សា

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

ការិយាល័យពលកម្មអន្តរជាតិ



រក្សាសិទ្ធិ © អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០០៦
បោះពុម្ពលើកទី១ ឆ្នាំ ២០០៦

ការបោះពុម្ពផ្សាយរបស់ការិយាល័យពលកម្មអន្តរជាតិ ទទួលការរក្សាសិទ្ធិក្រោមពិធីសារទី ២ នៃអនុសញ្ញារក្សាសិទ្ធិជាសកល ។ ទោះជាយ៉ាងដូច្នេះក្តី ការដកស្រង់ខ្លីៗចេញពីឯកសារបោះពុម្ពផ្សាយអាចប្រព្រឹត្តធ្វើទៅបាន ដោយពុំចាំបាច់សុំការអនុញ្ញាត ឱ្យតែមានសេចក្តីបញ្ជាក់ច្បាស់លាស់ពីប្រភពដើមនៃឯកសារ ។ សំរាប់សិទ្ធិក្នុងការផលិតឡើងវិញ និងការបកប្រែ គប្បីត្រូវដាក់ពាក្យសុំការអនុញ្ញាតពីផ្នែកបោះពុម្ពផ្សាយរបស់អង្គការ ILO (ផ្នែកសិទ្ធិ និងការអនុញ្ញាត) នៃការិយាល័យពលកម្មអន្តរជាតិ អាស័យដ្ឋាន CH-1211 Geneva 22 ប្រទេសស្វីស ។ ការិយាល័យពលកម្ម អន្តរជាតិស្វាគមន៍ចំពោះការដាក់ពាក្យសុំ ។

បណ្ណាល័យ និងស្ថាប័ននានា ព្រមទាំងអ្នកប្រើប្រាស់ផ្សេងៗទៀតដែលមានចុះបញ្ជីកានៅចក្រភពអង់គ្លេសជាមួយនឹងទីភ្នាក់ងារផ្តល់អាជ្ញាប័ណ្ណលើការរក្សាសិទ្ធិ អាស័យដ្ឋាន : 90 Tottemham Court Road, London W1P 9HE (ទូរសារ : +44 171 436 3986) នៅសហរដ្ឋអាមេរិក ជាមួយមជ្ឈមណ្ឌលផ្តល់ការអនុញ្ញាតលើការរក្សាសិទ្ធិ អាស័យដ្ឋាន : 222 Rosewood Drive, Danvers, MA 091923 (ទូរសារ : +1 508 750 4470) ឬនៅក្នុងប្រទេសដទៃទៀត ជាមួយអង្គការសមាគមផ្តល់សិទ្ធិផលិតឡើងវិញ អាចធ្វើការថតចំលងបាន យោងទៅតាមអាជ្ញាប័ណ្ណ ដែលចេញឱ្យពួកគេ សំរាប់គោលបំណងនេះ ។

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា
*ការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា : វិវេចនានិពន្ធ*
បាងកក និងភ្នំពេញ ការិយាល័យពលកម្មអន្តរជាតិ ឆ្នាំ ២០០៦ ។
ច្បាប់ចេញផ្សាយជាភាសាខ្មែរ :
ISBN 92-2-818738-7 & 978-92-2-818738-0 (ឯកសារបោះពុម្ពផ្សាយ)
ISBN 92-2-818739-5 & 978-92-2-818739-7 (ការផ្សាយតាមវិបសាយ)
ច្បាប់ចេញផ្សាយជាភាសាអង់គ្លេស :
ISBN 92-2-118738-1 & 978-92-2-118738-7 (ឯកសារបោះពុម្ពផ្សាយ)
ISBN 92-2-118739-X & 978-92-2-118739-4 (ការផ្សាយតាមវិបសាយ)

ការរចនាប្លង់បោះពុម្ពដែលមានប្រើនៅក្នុងការបោះពុម្ពផ្សាយរបស់ ILO ដែលស្របទៅតាមការអនុវត្តរបស់អង្គការសហប្រជាជាតិ និងទស្សនៈយោបល់ ដែលមានបង្ហាញនៅក្នុងឯកសារបោះពុម្ពនេះ មិនញ្ជាក់ថាជាការបញ្ចេញមតិយោបល់អ្វីមួយ ដោយការិយាល័យពលកម្មអន្តរជាតិនោះទេ ទាក់ទងទៅនឹងស្ថានភាពផ្នែកច្បាប់នៃប្រទេសណាមួយ តំបន់ ឬទឹកដីណាមួយ ឬអាជ្ញាធរនៃប្រទេស តំបន់ ឬទឹកដីទាំងនោះ ឬទាក់ទងនឹងការកំណត់ព្រំដែននៃទីកន្លែងទាំងនោះ ។

សេចក្តីយោងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ព្រមទាំងដំណើរការផលិត មិនបញ្ជាក់ថា ការិយាល័យពលកម្មអន្តរជាតិមានការឯកភាពតាមសេចក្តីយោងទាំងនោះឡើយ ហើយការដែលមិនបានបញ្ចេញឈ្មោះក្រុមហ៊ុនណាមួយ ផលិតផលពាណិជ្ជកម្មណាមួយ ឬដំណើរការផលិត ក៏មិនមែនជាសញ្ញានៃការមិនយល់ស្របដែរ ។

សេចក្តីយោងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ព្រមទាំងដំណើរការផលិត មិនបញ្ជាក់ថា ការិយាល័យពលកម្មអន្តរជាតិមានការឯកភាពតាមសេចក្តីយោងទាំងនោះឡើយ ហើយការដែលមិនបានបញ្ចេញឈ្មោះក្រុមហ៊ុនណាមួយ ផលិតផលពាណិជ្ជកម្មណាមួយ ឬដំណើរការផលិតក៏មិនមែនជាសញ្ញានៃការមិនយល់ស្របដែរ ។

ការបោះពុម្ពផ្សាយរបស់ ILO អាចរកបាននៅតាមបណ្ណាគារធំៗ ឬនៅតាមការិយាល័យរបស់អង្គការ ILO នៅក្នុងប្រទេសជាច្រើន ឬអាចរកបានដោយផ្ទាល់ពីផ្នែកបោះពុម្ពផ្សាយរបស់អង្គការ ILO នៅឯការិយាល័យពលកម្មអន្តរជាតិ អាស័យដ្ឋាន CH-1211 Geneva 22 ប្រទេសស្វីស។ កាតាឡុក ឬបញ្ជីនៃការបោះពុម្ពផ្សាយថ្មីៗ អាចរកបានតាមអស័យដ្ឋានខាងលើ ឬតាមអ៊ីមែល : pubvente@ilo.org ។

បោះពុម្ពនៅប្រទេសកម្ពុជា



# អារម្ភកថា

គោលដៅជាចម្បងរបស់អង្គការពលកម្មអន្តរជាតិ (ILO) គឺដើម្បី "លើកកំពស់ឱកាសសំរាប់ស្ត្រី និងបុរស ឱ្យទទួលបានការងារសមរម្យ និងប្រកបដោយផលិតភាពក្នុងល័ក្ខខ័ណ្ឌនៃសេរីភាព សមធម៌ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស"។ អាណត្តិតួនាទីរបស់អង្គការនេះទៅហួសពីរង្វង់នៃទីផ្សារពលកម្មក្នុងប្រព័ន្ធ ហើយរាប់បញ្ចូលនូវអ្នកធ្វើការគ្រប់ប្រភេទ មានដូចជា កម្មករនិយោជិតស៊ីប្រាក់ឈ្នួលម្តងម្កាល អ្នកប្រកបរបររកស៊ីដោយខ្លួនឯង និងអ្នកធ្វើការនៅតាមផ្ទះ ។ ហេតុដូច្នេះ ការផ្តួចផ្តើមគំនិតរបស់អង្គការនេះស្តីពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺមានឫសគល់ចេញពីក្តីបារម្ភរបស់ខ្លួន ចំពោះអ្នកធ្វើការទាំងអស់ ដែលអង្គការពលកម្មអន្តរជាតិ (ILO) បញ្ជាក់ថាមានសិទ្ធិជាមូលដ្ឋាននៅក្នុងការងារ ។

អង្គការពលកម្មអន្តរជាតិ (ILO) បានបញ្ជាក់អះអាងសារជាថ្មីឡើងវិញអំពីអាណត្តិតួនាទីនេះ នៅឯសន្និសីទអន្តរជាតិស្តីពីវិស័យការងារក្នុងឆ្នាំ ១៩៩៩ ហើយបន្តដោយការពិភាក្សាលំអិតនៅឯសន្និសីទដដែលនេះក្នុងឆ្នាំ ២០០២ ស្តីពីការងារសមរម្យ និងបញ្ហាប្រឈមនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយកំណត់ចេញច្បាស់ក្នុងន័យធ្វើការដោះស្រាយឱនភាពនៃការងារ សិទ្ធិ ការការពារខាងសង្គមកិច្ច និងភាពតំណាង ។

ក្នុងកិច្ចខិតខំប្រឹងប្រែងមួយដើម្បីធ្វើការដោះស្រាយបញ្ហាប្រឈមមុខនេះ ការិយាល័យអនុតំបន់អាស៊ីបូព៌ារបស់អង្គការ ILO ប្រចាំនៅទីក្រុងបាងកក បានបង្កើតគំរោងស្តីពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងារ ដែលបានទទួលការឧបត្ថម្ភថវិកាពីក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស ។ គំរោងដែលបានអនុវត្តពីឆ្នាំ ២០០៣-២០០៦ ផ្តល់ឱកាសដើម្បីធ្វើការដោះស្រាយឱនភាពនៃការងារសមរម្យ តាមរយៈសកម្មភាពសហប្រតិបត្តិការបច្ចេកទេស។ គំរោងផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងចំនួនបីដែលមានការជំពាក់ទាក់ទងគ្នាទៅវិញទៅមកគឺ : ទី១ ជំរុញឱ្យមានការរៀបចំជាអង្គការ ភាពតំណាង និងសំលេង ឬការបញ្ចេញមតិ ទី២ បង្កើនផលិតភាព និងលទ្ធភាពចូលទៅរកទីផ្សារ និងទី៣ កាត់បន្ថយភាពងាយរងគ្រោះ។ គំរោងនេះអនុវត្តនៅប្រទេសកម្ពុជា ម៉ុងហ្គោលី និងថៃ។

នៅក្នុងប្រទេសកម្ពុជា គំរោងមានបំណងរួមចំណែកដល់ការបង្កើននូវគោលនយោបាយ និងផែនការសកម្មភាពសំដៅសំរេចនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ។

យុទ្ធសាស្ត្រចតុកោណ ដែលផ្តល់មាគ៌ាណែនាំសំរាប់ការអនុវត្តរបៀបវារៈនៃគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ផ្តោតការយកចិត្តទុកដាក់ទៅលើអភិបាលកិច្ច និងការរីកលូតលាស់សេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍវិស័យឯកជន និងការកសាងសមត្ថភាព។ អាណត្តិតួនាទីរបស់អង្គការ ILO ក៏ដូចជារបស់គំរោងស្តីពីសេដ្ឋកិច្ចក្រៅប្រព័ន្ធដែរ គឺគាំទ្រដល់គោលដៅទាំងអស់នេះ ។

ការបោះពុម្ពផ្សាយនេះស្តីពីការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាវិវេចនានិពន្ធ ដែលពិពណ៌នាអំពីបញ្ហាប្រឈមនៃការងារសមរម្យ នៅក្នុងបរិបទសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា ។ ឯកសារនេះរៀបរាប់សង្ខេបអំពីហេតុការណ៍ និងនិន្នាការនានានៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងពិពណ៌នាអំពីការងារកន្លងមកនៃដៃគូសង្គមរបស់អង្គការ ILO និងអង្គការសង្គមស៊ីវិល ។ ការអង្កេតពិនិត្យលើបទនិពន្ធផ្សេងៗ ត្រូវបានគេធ្វើឡើងនៅក្នុងប្រទេសកម្ពុជា តាំងតែពីដើមដំបូងនៃគំរោងក្នុងគោលបំណងក្តាប់ឱ្យបានច្បាស់អំពីស្ថានភាពនៃចំណេះដឹង និងគំនិតផ្តួចផ្តើមនានា មុនពេលអនុវត្តន៍បទអន្តរាគមន៍របស់គំរោង។

យើងសូមថ្លែងអំណរគុណដល់មនុស្សជាច្រើននាក់ដែលបានធ្វើឱ្យបោះពុម្ពផ្សាយនេះលេចចេញជារូបរាងឡើង ។ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) បានរៀបចំរបាយការណ៍នៃវិវេចនានិពន្ធនេះ ។ លោក ទុន សុភ័ណ មន្ត្រីសំរបសំរួលគំរោងប្រចាំនៅកម្ពុជា ដែលបានសំរបសំរួលចំពោះការរៀបចំ និងការធ្វើឱ្យចប់ជាស្ថាពរនូវការបោះពុម្ពផ្សាយនេះ។ កញ្ញា Sandra O. Yu ជាប្រធានទីប្រឹក្សាបច្ចេកទេសគំរោង ដែលបានផ្តល់ការត្រួតពិនិត្យជាទូទៅខាងផ្នែកបច្ចេកទេស ។ លោកស្រី Ginette Forgues ជាអ្នកឯកទេសជាន់ខ្ពស់ខាងយុទ្ធសាស្ត្រមូលដ្ឋានសំរាប់ការងារសមរម្យដែលបានផ្តល់យោបល់ដ៏មានតំលៃទៅលើរបាយការណ៍ និងបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសដល់គំរោងស្តីពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

យើងសង្ឃឹមថា ការសិក្សានេះនឹងរួមចំណែកក្នុងការវាយតំលៃអំពីតម្រូវការនៃការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា និងចាត់ទុកជាចំណុចចាប់ផ្តើមសំរាប់បង្កើតនូវការមូលមតិគ្នាអំពីមាគ៌ាឆ្ពោះទៅមុខ ។

បាងកក ប្រទេសថៃ



**Christine Evans-Klock**

នាយិកា

ការិយាល័យប្រចាំអនុតំបន់អាស៊ីបូព៌ា

នៃអង្គការពលកម្មអន្តរជាតិ (ILO)



# មាតិកា


**អារម្ភកថា ....................................................................................................៣**

**បញ្ជីពាក្យកាត់ ..............................................................................................៦**

**១. សេចក្តីពិពណ៌នាសង្ខេប ...................................................................... ៩**

**២. ទស្សនាទាន និងលក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ............................១២**

២.១. និយមន័យ និងប្រភេទនៃសកម្មភាព.........................................១២

២.២. លក្ខណៈទូទៅ និងទំហំនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ..................... ១៦

២.៣. កត្តាដែលបណ្តាលឱ្យមានកំណើននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ................ ១៨

**៣. ការងារសមរម្យ និង សេដ្ឋកិច្ចក្រៅប្រព័ន្ធ ..........................................២៣**

៣.១. ឱនភាពនៃការងារ...............................................................២៣

៣.២. ឱនភាពនៃសិទ្ធិ...................................................................២៥

៣.៣. ឱនភាពនៃការការពារខាងសង្គម.............................................២៦

៣.៤. ឱនភាពនៃភាពតំណាង...........................................................២៩

**៤. គោលនយោបាយកម្ពុជា ចំពោះការងារសមរម្យ.................................៣៣**

៤.១. ការបញ្ចូលសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងក្របខ័ណ្ឌច្បាប់.....................៣៤

៤.២. ការអភិវឌ្ឍសហគ្រាសដើម្បីបង្កើនផលិតភាព
និងគុណភាពការងារ............................................................ ៤១

៤.៣. មីក្រូហិរញ្ញវត្ថុ និងការសន្សំប្រាក់ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ.......... ៤៧

៤.៤. ការបណ្តុះបណ្តាលដើម្បីបង្កើនផលិតភាព
និងឱកាសរកបានការងារធ្វើ.......................................................៤៩

៤.៥. ការលើកកំពស់ការការពារខាងសង្គមកិច្ច....................................៥២

៤.៦. ការពង្រឹងនូវសំលេង ឬការបញ្ចេញមតិ នៃអ្នកធ្វើការ
ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ.......................................................... ៥៨

**៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍...................................................៧០**

**ឯកសារយោង...................................................................................៧៤**

# បញ្ជីពាក្យកាត់

| | |
|---|---|
| AAC | សមាគមសិប្បករកម្ពុជា |
| ABC | សមាគមធនាគារនៅកម្ពុជា |
| ACHR | សម្ព័ន្ធអាស៊ីដើម្បីសិទ្ធិលំនៅដ្ឋាន |
| ACLEDA | សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADRA | ទីភ្នាក់ងារសង្គ្រោះ និងអភិវឌ្ឍន៍គ្រីស្តបរិស័ទ |
| AMDA | សមាគមគ្រូពេទ្យអាស៊ី |
| CAID | សមាគមកម្ពុជាអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ |
| CARERE/UNDP | កម្មវិធីការតាំងទីលំនៅថ្មី និងនិតិសម្បទាកម្ពុជា / កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| CBO | អង្គការនៅតាមសហគមន៍ |
| CCBO | អង្គការនៅតាមសហគមន៍ឃុំ |
| CCC | សារជីវកម្មសិប្បកម្មកម្ពុជា |
| CDC | គណៈកម្មការអភិវឌ្ឍន៍ឃុំ |
| CDW | អ្នកបំរើនៅតាមផ្ទះជាកុមារ |
| CCTU | សហភាពសហព័ន្ធសហជីពជាតិកម្ពុជា |
| CIDSE Cambodia | កិច្ចសហប្រតិបត្តិការអន្តរជាតិសំរាប់ការអភិវឌ្ឍ និងសាមគ្គីភាពកម្ពុជា |
| CSARO | អង្គការកែច្នៃ និងអនាម័យសហគមន៍ |
| YCK | អង្គការថែទាំយុវជនខ្មែរ |
| DDD | អង្គការប្រព័ន្ធទិន្នន័យកម្ពុជា |
| DFID | ក្រសួងអភិវឌ្ឍន៍អន្តរជាតិ |
| EDC | អង្គការអភិវឌ្ឍន៍សហគ្រាសកម្ពុជា |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (វ.ស.ក) |

| | |
|---|---|
| ESCAP | គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក |
| EU | សហគមន៍អឺរ៉ុប |
| FDI | វិនិយោគផ្ទាល់ពីបរទេស |
| GDG | ផលិតផលក្នុងស្រុកសរុប |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| GRET | ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិជ្ជា |
| GTL-PAC | សមាគមការពារពលកម្ម និងការដឹកជញ្ជូនទំនិញក្នុងប្រទេសកម្ពុជា |
| GTZ | សហប្រតិបត្តិការបច្ចេកទេសរបស់អាល្លឺម៉ង់ |
| JFPR | មូលនិធិជប៉ុនសំរាប់ការកាត់បន្ថយភាពក្រីក្រ |
| HI | អង្គការជនគ្មានលំនៅដ្ឋានអន្តរជាតិ |
| HIV/AIDS | មេរោគអេដស៍ / ជំងឺអេដស៍ |
| ICLS | សន្និសីទអន្តរជាតិនៃអ្នកស្ថិតិការងារ |
| IE | សេដ្ឋកិច្ចក្រៅប្រព័ន្ធ |
| ILO-IPEC | អង្គការពលកម្មអន្តរជាតិ - កម្មវិធីអន្តរជាតិលប់បំបាត់ពលកម្មកុមារ |
| KHANA | សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលខ្មែរប្រយុទ្ធនឹងមេរោគអេដស៍ / ជំងឺអេដស៍ |
| KfW | Kreditanstalt für Wiederaufbau |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoP | ក្រសួងផែនការ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoSAVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MPDF | កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ |
| MSE | មីក្រូសហគ្រាស និងសហគ្រាសធុនតូច |
| MSME | មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម |
| NCDP | មជ្ឈមណ្ឌលជាតិជនពិការ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| OSH | សុវត្ថិភាព និងអនាម័យការងារ |
| PADEK | ប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (ប៉ាដិក) |
| PAP | កម្មវិធីសកម្មភាពអាទិភាព |
| PICDM | គំរូអភិវឌ្ឍន៍សហគមន៍ចំរុះរបស់អង្គការប៉ាដិក |
| PPHA | សមាគមសណ្ឋាគារភ្នំពេញ |
| RDA | សមាគមអភិវឌ្ឍន៍ជនបទ |
| RDP | គំរោងអភិវឌ្ឍន៍ជនបទ |
| SHG | ក្រុមជួយខ្លួនឯង |
| SIDA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសស៊ុយអែដ |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| SNA | ប្រព័ន្ធគណនេយ្យជាតិ |
| SRAHGA | សមាគមសណ្ឋាគារ និងផ្ទះសំណាក់សៀមរាបអង្គរ |
| SUPF | សាមគ្គីភាពដើម្បីសហព័ន្ធអ្នកក្រីក្រនៅទីក្រុង |
| UDHR | សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធមនុស្ស |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNESCO | អង្គការយូណេស្កូ |
| UNFPA | មូលនិធិសហប្រជាជាតិសំរាប់ប្រជាជន |
| UPDF | មូលនិធិអភិវឌ្ឍន៍អ្នកក្រីក្រនៅទីក្រុង |
| UPRS | យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅទីក្រុង |
| USAID | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក |
| USG | គណៈកម្មាធិការសំរបសំរួលអភិវឌ្ឍន៍ទីក្រុង |
| VDC | គណៈកម្មការអភិវឌ្ឍន៍ភូមិ |
| WHO | អង្គការសុខភាពពិភពលោក |
| WISH | ការកែលំអការងារដើម្បីសុវត្ថិភាពអ្នកធ្វើការនៅតាមផ្ទះ |
| WPD | អង្គការអភិវឌ្ឍន៍អ្នករើសសំរាម |
| WRF | មូលនិធិស្ថានីតិសម្បទាពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# ១ សេចក្តីពិពណ៌នាសង្ខេប

ជាមួយនឹងការបង្កើតរដ្ឋាភិបាលចំរុះលើកដំបូងនៅពាក់កណ្តាលឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាមានបំណងកសាងខ្លួនឱ្យទៅជាប្រទេសប្រជាធិបតេយ្យដែលមានការរីកចំរើនមួយ ។ ក្រិត្យក្រមចំបងនៃសិទ្ធិមនុស្សត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។ យុត្តិធម៌សង្គម និងការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានលើកតម្កើង ។ ដើម្បីគាំទ្រគោលបំណងនយោបាយទាំងនេះ គោលនយោបាយទីផ្សារសេរីត្រូវបានពង្រឹង ហើយទំនាក់ទំនងជាមួយសហគមន៍ហិរញ្ញវត្ថុអន្តរជាតិនានាត្រូវបានបង្កើតឡើងជាថ្មី ។ នៅក្នុងឆ្នាំ ១៩៩៤ កម្មវិធីកែទំរង់រយៈពេលមធ្យម ដែលមានគោលបំណងស្តារនូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានដាក់អោយអនុវត្ត ហើយដំណើរការនៃការពង្រឹងស្ថាប័នដែលគាំទ្រដោយសហគមន៍អន្តរជាតិក៏ត្រូវបានចាប់ផ្តើមផងដែរ ។

ទោះបីជាកំណែទំរង់ដំបូងទាំងនេះ បានផ្តល់លទ្ធផលវិជ្ជមានមួយចំនួនក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញពាណិជ្ជកម្មក្រៅប្រទេសក៏ដោយ ក៏ប្រជាជនកម្ពុជាទាំងអស់មិនបានទទួលនូវប្រយោជន៍ពេញលេញពីកំណែទំរង់ទាំងនេះដែរ ។ កំណើនសេដ្ឋកិច្ចមានតែនៅតាមទីប្រជុំជនធំៗតែប៉ុណ្ណោះ ចំណែកនៅតាមជនបទស្រែចំការវិញ គេសង្កេតឃើញមានការរីកចំរើនតិចតួចណាស់ ។ ទោះបីជាកំណើនសេដ្ឋកិច្ចទូទៅមានសន្ទុះខ្លាំង (ប្រហែល ៦ ភាគរយជាប្រចាំឆ្នាំ អំឡុងឆ្នាំ ១៩៩៤-២០០៣) ក៏កំណើននេះមានមូលដ្ឋានតូចចង្អៀត ផុយស្រួយ និងពុំបានបែងចែកឱ្យបានស្មើភាពឡើយ ។ សព្វថ្ងៃនេះ កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសក្រីក្របំផុតនៅអាស៊ីខាងកើត និងមានការលូតលាស់ខាងធនធានមនុស្សទាបជាងគេនៅក្នុងពិភពលោក ។

ផ្អែកលើការប៉ាន់ស្មានរបស់ធនាគារពិភពលោក[១] និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ការងារដែលមានប្រាក់ឈ្នួលមានចំនួនប្រហែល ១៥ ភាគរយនៃកំលាំងពលកម្មសរុបចំនួន ៦ លាននាក់ ។ ដោយមានមូលដ្ឋានតែនៅតាមទីប្រជុំជន ប្រភេទនៃការងារនេះភាគច្រើនប្រមូលផ្តុំលើវិស័យសេដ្ឋកិច្ចទំនើប ដែលទទួលផលគួរសមពីឱកាសពាណិជ្ជកម្មដែលផ្តល់ដោយសកលភាវូបនីយកម្ម ។ ទោះបីជាយ៉ាងនេះក្តី នៅពេលដែលយើងក្រឡេកមើលការងារដែលមិនទទួលបានប្រាក់ឈ្នួលនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ វាបង្ហាញឱ្យឃើញច្បាស់ថាវិស័យនេះបានស្រូបយកចំណែកការងារយ៉ាងធំនៅកម្ពុជា ។ នៅក្នុងបរិបទនៃការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ការងារសមរម្យ (ដូចដែលបានកំណត់ដោយអង្គការពលកម្ម

[១] ធនាគារពិភពលោក ឆ្នាំ ២០០៤

អន្តរជាតិនៃអង្គការសហប្រជាជាតិ) វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីលក្ខណៈ និងសមាសភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ យើងត្រូវតែយល់ពីរបៀបដែលសេដ្ឋកិច្ចក្រៅប្រព័ន្ធដំណើរការ ប្រសិនជាយើងចង់សំរបសំរួលក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ដែលកំពុងមានការរីកចំរើនយ៉ាងលឿននោះ ហើយនៅទីបំផុត វានឹងផ្តល់ឱ្យកម្ពុជានូវឱកាសមួយដើម្បីទទួលបានផលប្រយោជន៍កាន់ទូលាយពីសកលភាវូបនីយកម្ម ។

សន្និទានភាពសំរាប់ការងារសមរម្យនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានពន្យល់ដោយសេចក្តីថ្លែងការណ៍នៃកតិកាសញ្ញាស្តីពីសិទ្ធិជាមូលដ្ឋានក្រោមច្បាប់អន្តរជាតិ។ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សបានបញ្ជាក់យ៉ាងច្បាស់ថា មនុស្សគ្រប់ៗរូបត្រូវមានសិទ្ធិស្មើគ្នាដើម្បីធ្វើការងារ។ រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាបានអនុម័តយ៉ាងច្បាស់នូវសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងបានបញ្ជាក់ពីគោលបំណងរបស់កម្ពុជា ក្នុងការគោរព និងទទួលស្គាល់សិទ្ធិមនុស្ស រួមទាំងសិទ្ធិស្ត្រី និងសិទ្ធិកុមារផងដែរ ។ ទោះបីនេះជាគោលដៅដ៏សំខាន់ក៏ដោយ នៅក្នុងសភាពជាក់ស្តែង ប្រជាជនកម្ពុជាជាច្រើនត្រូវបានបង្ខំឱ្យប្រកបរបរចិញ្ចឹមជីវិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសារពួកគេមិនអាចរកការងារធ្វើបាននៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ អ្នកធ្វើការងាយនឹងទទួលរងនូវបញ្ហាធំៗជាច្រើន ឬការរំលោភបំពាន ពីព្រោះពួកគេមិនមានសិទ្ធិស្របច្បាប់នៅក្រោមច្បាប់ស្តីពីការងារឡើយ ហើយថែមទាំងមិនមានការការពារនៅក្រោមបទប្បញ្ញត្តិស្តីពីសុវត្ថិភាព សុខភាព និងអនាម័យការងារ ហើយមិនមានមធ្យោបាយស្វែងរកការការពារផ្នែកសន្តិសុខសង្គមទៀតផង ។

បន្ថែមលើស្ថានភាពដ៏លំបាកទាំងនេះ អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនមានសំលេង ឬអ្នកតំណាងឡើយ ដូចនេះពួកគេមានសិទ្ធិសំរេចតិចតួច ឬគ្មានសោះតែម្តងនៅក្នុងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៃប្រទេសរបស់ខ្លួន។ ល័ក្ខខ័ណ្ឌទាំងនេះ ខុសប្លែកឆ្ងាយពីសេចក្តីថ្លែងការណ៍នៅក្រុងហ្វីឡាឌែលហ្វី [២] ដែលចែងពីសិទ្ធិរបស់មនុស្សគ្រប់រូបចំពោះ "ល័ក្ខខ័ណ្ឌនៃសេរីភាព និងសេចក្តីថ្លៃថ្នូរ សិទ្ធិទទួលបានសន្តិសុខសេដ្ឋកិច្ច និងឱកាសស្មើភាពគ្នា "។

គោលបំណងដ៏ចំបងនៃឯកសារនេះ គឺធ្វើការពិនិត្យមើលល័ក្ខខ័ណ្ឌការងារនៃអ្នកធ្វើការក្រៅប្រព័ន្ធនៅកម្ពុជា និងពិនិត្យមើលថាតើការងារសមរម្យមានឬទេ បើមានតើមាននៅកន្លែងណា និងដើម្បីកំណត់ពីអ្វីដែលត្រូវធ្វើដើម្បីបង្កើនឱកាសការងារសមរម្យ ។ អង្គការពលកម្មអន្តរជាតិបានបង្កើតនូវទំរង់នៃការវាស់វែងមួយដែលគេស្គាល់ថា "ឱនភាពការងារសមរម្យ " ។ សមាសភាពសំខាន់ ៤ នៃឱនភាពការងារសមរម្យគឺ ការងារ សិទ្ធិ ការការពារខាងសង្គម និងភាពតំណាង [៣] ។

[២] សេចក្តីថ្លែងការណ៍ទីក្រុងហ្វីឡាដែលហ្វី ឆ្នាំ ១៩៤៤ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងធម្មនុញ្ញរបស់ ILO បានពង្រីកអាណត្តិតួនាទីរបស់ ILO ដូចដែលមានចែងនៅក្នុងធម្មនុញ្ញនេះដើម្បីជំរុញកំណើនស្មើភាពនៅក្នុងសេដ្ឋកិច្ចក្រោយសង្រ្គាម។

[៣] អង្គការ ILO ឆ្នាំ ២០០២ a

ដើម្បីយល់ពីល័ក្ខខ័ណ្ឌនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា និងទស្សនៈវិស័យសំរាប់ការងារសមរម្យឱ្យកាន់តែច្បាស់ថែមទៀតនោះ ចំណេះដឹងជាសារវ័ន្តអំពីលក្ខណៈទូទៅ និងទស្សនាទាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺមានភាពចាំបាច់ ។ យើងនឹងពិភាក្សានិយមន័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងធ្វើការវាយតំលៃលក្ខណៈការងារមួយចំនួន ដើម្បីកំណត់លក្ខណៈ និងវិសាលភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ។ ប្រការនេះប្រហែលជាផ្តល់នូវចក្ខុវិស័យខ្លះអំពីមូលហេតុ ថាតើហេតុអ្វីបានជាផ្នែកក្រៅប្រព័ន្ធនេះមានទំហំធំម្ល៉េះនៅក្នុងបរិបទនៃប្រទេសកម្ពុជា ។ ជាមួយនឹងការយល់ដឹងអំពីកត្តាពាក់ព័ន្ធនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បន្ទាប់មកឯកសារនេះនឹងពិនិត្យមើលទៅលើឱនភាពការងារនៅក្នុងប្រទេសកម្ពុជា ។ យើងនឹងក្រឡេកមើលការផ្តួចផ្តើមគោលនយោបាយខ្លះៗ តាមរយៈបទពិសោធន៏របស់ភាគីពាក់ព័ន្ធមួយចំនួន ដែលជាអ្នកដើរតួគួរឱ្យកត់សំគាល់នៅក្នុងការជំរុញការងារសមរម្យនៅក្នុងសេដ្ឋកិច្ចនេះ ។ នៅទីបញ្ចប់ឯកសារនេះនឹងផ្តល់ការសន្និដ្ឋាន និងអនុសាសន៏មួយចំនួន ដើម្បីសំរេចបាននូវអ្វីមួយដែលខិតជិតទៅរកភាពឥតខ្ចោះនៃការងារសមរម្យ ។

# ២ ទស្សនាទាន និងលក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

## ២.១. និយមន័យ និងប្រភេទនៃការងារ

អង្គការពលកម្មអន្តរជាតិបានបង្កើតបច្ចេកស័ព្ទ "វិស័យក្រៅប្រព័ន្ធ ឬ សេដ្ឋកិច្ចក្រៅប្រព័ន្ធ" ប្រហែល ៣០ ឆ្នាំមកហើយ ។ អង្គការនេះប្រើបច្ចេកស័ព្ទ "វិស័យក្រៅប្រព័ន្ធ" ដើម្បីពិពណ៌នាសកម្មភាពទាំងឡាយរបស់កម្មករនិយោជិតក្រីក្រដែលមិនត្រូវបានគេទទួលស្គាល់ កត់ត្រាក្នុងស្ថិតិ ការពារ ឬគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ ។ កំណើនយ៉ាងលឿននៃការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍ និងប្រទេសឋិតនៅក្នុងរយៈពេលអន្តរកាលបានក្លាយជាប្រធានបទនៃចំណាប់អារម្មណ៍របស់អង្គការនេះ នៅក្នុងសម័យប្រជុំលើកទី ៧៨ នៃសន្និសីទអន្តរជាតិស្តីពីវិស័យការងារ[៤] ។ សន្និសិទ្ធអន្តរជាតិនៃអ្នកស្ថិតិការងារ (ICLS) បានកំណត់យកនិយមន័យវិស័យក្រៅប្រព័ន្ធនៅឆ្នាំ ១៩៩៣ ដូចដែលបានបង្ហាញនៅក្នុងប្រអប់លេខ ២.១ ។

និយមន័យនេះសំដៅដល់អង្គភាពផលិតកម្មនានានៃសហគ្រាស ជាជាងសំដៅដល់លក្ខណៈទូទៅនៃពលកម្ម ។ ក្រោយមកទៀតអង្គការ ILO បានពង្រីកទស្សនទាន និងនិយមន័យនេះទៅដល់វិស័យក្រៅប្រព័ន្ធ។ បច្ចេកស័ព្ទ "សេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដែលមានកំណត់អំពីការងារក្រៅប្រព័ន្ធ វិស័យក្រៅប្រព័ន្ធ និងការងារដែលគ្មានការការពារត្រូវបានកំណត់និយមន័យឡើងវិញតាមការពិពណ៌នាដែលមានលក្ខណៈជាក់លាក់ជាងមុនអំពីអ្វីដែលបង្កើតទៅជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (សូមមើលប្រអប់លេខ ២.២) ។

[៤] *ibid.*

**ប្រអប់លេខ ២.១ :**

**និយមន័យនៃវិស័យក្រៅប្រព័ន្ធ**

"សំរាប់គោលបំណងខាងស្ថិតិ វិស័យក្រៅប្រព័ន្ធត្រូវបានទទួលស្គាល់ថា ជាក្រុមនៃអង្គភាពផលិតកម្មដែលនៅក្នុងក្របខ័ណ្ឌប្រព័ន្ធគណនេយ្យជាតិ (SNA) បង្កើតជាផ្នែកមួយនៃវិស័យសហគ្រាសគេហជន ជាសហគ្រាសមិនមែនក្រុមហ៊ុនជាកម្មសិទ្ធិរបស់គេហជន ។ សហគ្រាសគេហជន (ឬសហគ្រាសមិនមែនក្រុមហ៊ុនដែលកាន់កាប់ដោយគេហជន) មានលក្ខណៈខុសពីក្រុមហ៊ុន ឬអង្គភាពពាក់កណ្ដាលក្រុមហ៊ុននៅលើមូលដ្ឋាននៃក្របខ័ណ្ឌច្បាប់ និងប្រភេទនៃគណនីដែលពួកគេកាន់កាប់ : អាស្រ័យហេតុនេះ សហគ្រាសគេហជនមិនត្រូវបានគេចាត់ថា ជានីតិបុគ្គលដោយឡែកដាច់ចេញពីគេហជន ឬពីសមាជិកគេហជនដែលកាន់កាប់សហគ្រាសនោះទេ និងមិនមានសំណុំគណនីគ្រប់គ្រាន់សំរាប់បង្ហាញពីភាពខុសគ្នារវាងសកម្មភាពផលិតកម្មរបស់សហគ្រាសទាំងនេះ និងសកម្មភាពដទៃទៀតរបស់ម្ចាស់កម្មសិទ្ធិឡើយ។ វិស័យក្រៅប្រព័ន្ធត្រូវបានកំណត់ (ដោយមិនគិតពីប្រភេទនៃកន្លែងធ្វើការ ទំហំនៃទ្រព្យមូលធនអចល័ត និងរយៈពេលនៃសកម្មភាពរបស់សហគ្រាស និងដំណើរការរបស់សហគ្រាសជាសកម្មភាពចំបង ឬបន្ទាប់បន្សំនោះឡើយ) ថា មាន :

១) សហគ្រាសគ្រប់គ្រងដោយខ្លួនឯងក្រៅផ្លូវការដែលអាចជួលមានកម្មករជាសមាជិកគ្រួសារខ្លួន និងនិយោជិតម្ដងម្កាលសំរាប់គោលបំណងប្រតិបត្តិការ និងពឹងផ្អែកលើកាលៈទេសៈជាតិ ឬជួលតែអ្នកដែលមិនចុះបញ្ជីក្រោមទំរង់ជាក់លាក់ណាមួយនៃច្បាប់ជាតិ (ច្បាប់រោងចក្រ ឬពាណិជ្ជកម្ម ច្បាប់ពន្ធដារ ឬច្បាប់របបសន្តិសុខសង្គមក្រុមអាជីពច្បាប់ ឬបញ្ញត្តិស្រដៀងគ្នា និងច្បាប់ ឬបទប្បញ្ញត្តិបង្កើតដោយអង្គនីតិបញ្ញត្តិជាតិ) ។

២) សហគ្រាសរបស់និយោជកក្រៅប្រព័ន្ធដែលប្រហែលជាជួលនិយោជិតម្នាក់ ឬច្រើនជាងនេះជាប្រចាំ និងដែលគោរពតាមលក្ខណៈវិនិច្ឆ័យមួយ ឬពីរនៃលក្ខណៈវិនិច្ឆ័យនានា ដូចតទៅនេះ : ទំហំនៃគ្រឹះស្ថានដែលស្ថិតនៅក្រោមកំរិតជាក់លាក់មួយនៃការងារ (កំណត់នៅលើមូលដ្ឋានតំរូវការទំហំអប្បបរមាដែលមានចែងនៅក្នុងច្បាប់ជាតិដែលពាក់ព័ន្ធ ឬការអនុវត្តន៍ជាក់ស្ដែង ឬតាមស្ថិតិ : ជំរើសនៃកំរិតទំហំខ្ពស់ជាងការកំណត់ដោយគិតពិចារណាអំពីទំហំដែលត្រូវរាប់បញ្ចូលក្នុងស្ថិតិដើម្បីជៀសវាងនូវការត្រួតលើគ្នា) ឬការមិនចុះបញ្ជីសហគ្រាស ឬនិយោជិតរបស់ខ្លួន "។

*ប្រភព : អង្គការ ILO ឆ្នាំ ២០០២ b*

**ប្រអប់លេខ ២.២ :**

**និយមន័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

អង្គភាពតូចៗផលិត និងចែកចាយទំនិញ និងសេវាកម្ម ដែលបង្កើតឡើងដោយផលិតករឯករាជ្យ ជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯង ដែលអ្នកខ្លះក៏មានប្រើសមាជិកគ្រួសារ ឬកម្មករពីរបីនាក់ ឬកូនជាង។ អង្គភាពទាំងនេះដំណើរការដោយមានដើមទុនតិច ឬគ្មានតែម្តង ដែលប្រើបច្ចេកទេស និងជំនាញកំរិតទាប ដូចនេះផលិតភាពក៏មានកំរិតទាបដែរ ហើយជាទូទៅផ្តល់នូវប្រាក់ចំណូលតិច និងមិនទៀងទាត់ ព្រមទាំងផ្តល់នូវការងារដែលមានកំរិតអស្ថេរភាពខ្ពស់ ចំពោះអ្នកធ្វើការនៅតាមអង្គភាពទាំងនោះ ។ អង្គភាពទាំងនេះឋិតនៅក្រៅប្រព័ន្ធដោយហេតុថា ភាគច្រើនមិនបានចុះបញ្ជី និងមានកត់ត្រានៅក្នុងស្ថិតិផ្លូវការ ហើយហាក់ដូចជាមិនមានលទ្ធភាព ឬមានលទ្ធភាពតិចតួចចូលទៅដល់ទីផ្សារដែលមានការរៀបចំល្អ ស្ថាប័នឥណទាន ការអប់រំក្នុងប្រព័ន្ធ និងស្ថាប័នបណ្តុះបណ្តាល ឬទទួលបានសេវាកម្ម សាធារណៈ និងការជួយសំរួលផ្សេងៗ។ អង្គភាពទាំងនេះក៏មិនត្រូវបានគេទទួលស្គាល់ គាំទ្រ ឬគ្រប់គ្រងដោយរដ្ឋាភិបាល ទេ ហើយជានិច្ចកាលត្រូវបង្ខំឱ្យដំណើរការនៅក្រៅក្របខ័ណ្ឌច្បាប់ បើទោះណាជាអ្នកខ្លះបានចុះបញ្ជី ហើយគោរព តាមបទប្បញ្ញត្តិមួយចំនួននៃច្បាប់ក៏ដោយ។ អង្គភាពទាំងនេះឋិតនៅក្រៅវង្វង់ការពារខាងសង្គមកិច្ច ច្បាប់ស្តីពី ការងារ និងវិធានការការពារនៅកន្លែងធ្វើការស្ទើរតែទាំងស្រុង ”។

អង្គការ ILO ថ្លែងថា លក្ខណៈនៃភាពក្រៅប្រព័ន្ធ ជាអង្គភាពផលិតកម្មក្តី ឬការងារក្តី គឺសំដៅដល់ :

- អង្គភាពផលិតកម្មដែលមានទំហំនៅកំរិតមួយដែលថាអង្គភាពទាំងនេះមិនបានរាប់បញ្ចូលក្នុងស្ថិតិផ្លូវការ មិនមានធនធានដែលផ្តល់ដោយស្ថាប័នសាធារណៈ និងឯកជន ហើយមិនគោរពតាមច្បាប់បញ្ញត្តិទាំងស្រុង ។
- ការងារមានទំហំក្នុងកំរិតមួយ ក្នុងនោះកម្មករនិយោជិតដែលគេជួលឱ្យបំរើការ មិនត្រូវបានប្រកាស ឬប្រាប់ឱ្យដឹងជាសាធារណៈ (ដោយសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ) ហើយដែលមិនបានទទួលអត្ថប្រយោជន៍ខាងសង្គមកិច្ច ដូចមានបញ្ញត្តិដោយច្បាប់ ។

អង្គការ ILO បែងចែកវិស័យក្រៅប្រព័ន្ធជាបីផ្នែកសំខាន់ៗ គឺ :

(ក) និយោជកនៃមីក្រូសហគ្រាស ឬសហគ្រាសធុនតូចក្រៅប្រព័ន្ធដែលជួលកម្មករនយោជិតពីរបីនាក់

(ខ) អ្នកប្រកបរបររកស៊ីដោយខ្លួនឯង ឬអ្នកប្រកបការងារដោយខ្លួនឯងដែលធ្វើការតែឯង ឬរួមជាមួយនិយោជិតដែលមិនមានប្រាក់ឈ្នួល ។

(គ) អ្នកធ្វើការដែលឋិតក្នុងមីក្រូសហគ្រាស ឬសហគ្រាសធុនតូចក្រៅប្រព័ន្ធ ឬអ្នកធ្វើការទាំងឡាយណា (ដូចជា អ្នកបំរើតាមផ្ទះ កម្មករជាប់កិច្ចសន្យា) ដែលមិនមាននិយោជកច្បាស់លាស់ ឬគ្មានកិច្ចសន្យា ។

ទស្សនាទាន និងបច្ចេកស័ព្ទនៃ " សេដ្ឋកិច្ចក្រៅប្រព័ន្ធ " ប្រហែលជាថ្មីសំរាប់កម្ពុជា ប៉ុន្តែតាមនិយមន័យរបស់ ILO វាមានកំណើតនៅក្នុងប្រទេសនេះរាប់ទសវត្សមកហើយ ប្រសិនបើមិនដល់សតវត្សទេនោះ ។ តាមពិតទៅ "សេដ្ឋកិច្ចក្នុងប្រព័ន្ធ" ត្រូវបានបង្កើតឡើងវិញបន្ទាប់ពីឆ្នាំនៃសង្គ្រាម និងការបំផ្លិចបំផ្លាញ ។ និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធខុសប្លែកគ្នាបន្តិចពីប្រទេសមួយទៅប្រទេសមួយ អាស្រ័យលើស្ថានភាពបច្ចុប្បន្នរបស់ប្រទេសនោះ ។ កម្ពុជាបានកំណត់និយមន័យ "វិស័យក្រៅប្រព័ន្ធ" ថាមានលក្ខណៈតទៅនេះ : សកម្មភាពទាំងឡាយណាដែលមិនមានគ្រឹះស្ថាន អាស័យដ្ឋានច្បាស់លាស់ដែលមានអ្នកប្រកបរបររកស៊ីដោយខ្លួនឯង និងមានប្រើកម្មករពេញម៉ោង ឬមិនពេញម៉ោង ប្រតិបត្តិការដោយពឹងផ្អែកលើកំលាំងពលកម្មច្រើន និងមានការផ្លាស់ប្តូរការងាររឆាប់រហ័ស មានប្រើប្រាស់ថាមពលជាមុខចូលដែលមានប្រភពពីមនុស្ស ឬសត្វ មិនមានទិន្នន័យស្តីអំពីអាជីវកម្មទាំងនេះ តាមរយៈការអង្កេតជំរឿន សកម្មភាពដែលមិនទទួលស្គាល់តាមផ្លូវច្បាប់ការងារនៅកន្លែងដែលមិនមានការរៀបចំត្រឹមត្រូវ មិនឋិតនៅក្រោមបទប្បញ្ញត្តិណាមួយអាជ្ញាប័ណ្ណណាមួយ ឬការធានារ៉ាប់រង និងមិនមានបង់ពន្ធ[៥] ។

តាមនិយមន័យខាងលើ ភាគច្រើននៃសេដ្ឋកិច្ចកម្ពុជាអាចត្រូវបានបញ្ចូលជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ក្នុងន័យការងារ សេដ្ឋកិច្ចក្រៅប្រព័ន្ធរួមបញ្ចូលសកម្មភាព មួយចំនួនធំដូចជាមុខរបរចញ្ចឹមជីវិត ឬមុខរបរសំរាប់តែមួយរស់ និងអ្នកដែលប្រកបការងារដោយខ្លួនឯង ព្រមទាំងអ្នកធ្វើការមានប្រាក់ឈ្នួល និងគ្មានប្រាក់ឈ្នួលនៅក្នុងសហគ្រាសក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ។ អ្នកធ្វើការខ្លះនៅក្នុងសហគ្រាសក្នុងប្រព័ន្ធត្រូវបានគេបញ្ចូលជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសារនិយោជករបស់ពួកគេមិនបានប្រកាសជូនដំណឹងអំពីបុគ្គលិកដល់ក្រសួងការងារ ។ ទាក់ទងនឹងផលិតភាព និងទំហំ សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជាគ្របដណ្តប់លើសហគ្រាសមួយចំនួនធំ រួមបញ្ចូលទាំងសហគ្រាសធុនតូច និងមធ្យមដែលយកផ្ទះរបស់ខ្លួនធ្វើជាមូលដ្ឋាន។ សហគ្រាសក្រៅប្រព័ន្ធទាំងនេះដែលតាមពិតទៅស្វែងរកការចុះបញ្ជី និងការបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់បានត្អូញត្អែរអំពីឧបសគ្គចំពោះការចុះបញ្ជី ។ យោងទៅតាមការសិក្សាមួយរបស់សមាគមសិប្បករកម្ពុជាដែលគាំទ្រដោយ ILO ឧបស័គ្គទាំងនោះរួមមាននីតិវិធីនៃការចុះបញ្ជីស្មុគស្មាញ ជាងនេះទៅទៀតគឺការធ្វើអធិការកិច្ចច្រើន កង្វះតម្លាភាពនៅក្នុងការចុះបញ្ជី តំលៃនៃការចុះបញ្ជីខ្ពស់ បទប្បញ្ញត្តិច្បាប់ និងកង្វះការលើកទឹកចិត្តក្នុងការចុះបញ្ជី[៦] ។

នៅទីក្រុងភ្នំពេញ មុខរបរក្រៅប្រព័ន្ធរួមមាន : ការរត់តាក់ស៊ី និងអ្នកធាក់ស៊ីក្លូដោយខ្លួនឯង អ្នកលក់តាមតាមដងផ្លូវ អ្នកខាត់ស្បែកជើង អ្នកប្រមូលសំរាម អ្នកជួសជុលយានយន្តតាមចិញ្ចើមថ្នល់ អ្នកលក់សាំងតាមចិញ្ចើមថ្នល់ ជាងកំបោរ កម្មករសំណង់ សិប្បករជាងកាត់ដេរសំលៀកបំពាក់នារី និងជាងកាត់ដេរសំលៀកបំពាក់បុរស ជាងអ៊ុតសក់ និងអ្នកបំរើតាមផ្ទះ ។

[៥] អង្គការ ILO ឆ្នាំ ២០០២ ៦

[៦] AAC ឆ្នាំ ២០០៤

មុខរបរក្រៅប្រព័ន្ធនៅតាមទីជនបទប្រមូលផ្តុំលើវិស័យកសិកម្ម និងឧស្សាហកម្មកសិកម្ម ព្រមទាំងសកម្មភាពក្រៅពីស្រែចំការ ។ មុខរបរទាំងនេះរួមមាន : នេសាទ ការកែច្នៃត្រី ការជីករ៉ែ ការធ្វើគ្រឿងសង្ហារឹម ការត្បាញរវៃ ការកែច្នៃម្ហូប ការកាត់ដេរសំលៀកបំពាក់នៅតាមផ្ទះ ការជួសជុលយានយន្តនៅតាមផ្ទះ សិប្បកម្មនានា ការផលិតអគ្គិសនី ការលក់រាយតាមផ្ទះ ការងារសំណង់ និងការដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវទឹក[៧] ។

អ្នកធ្វើការជាច្រើននៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាអ្នកប្រកបការងារដោយខ្លួនឯង ។ ការអង្កេតមួយដែលរៀបចំដោយសមាគមកម្ពុជាអភិវឌ្ឍន៏សេដ្ឋកិច្ចក្រៅប្រព័ន្ធ (CAID) ក្នុងចំណោមមុខរបរប្រាំផ្សេងៗគ្នានៅខេត្តបួនរបស់កម្ពុជា បង្ហាញឱ្យឃើញថា ៩៨,៩ ភាគរយនៃអ្នកទាំងនោះប្រកបរបររកស៊ីដោយខ្លួនឯង[៨] ។ មុខរបរទាំងប្រាំនេះ ដែលបានធ្វើការអង្កេតគឺ កសិករ អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប អ្នករត់ម៉ូតូឌុបកង់បី អ្នកលក់តាមផ្សារ និងអ្នកលក់តាមដងផ្លូវ ។

## ២.២. លក្ខណៈទូទៅ និងទំហំនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សមាសភាពបីនៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធនៅកម្ពុជា គឺវិស័យកាត់ដេរ (កម្មករ ២៣០.០០០ នាក់) ទេសចរណ៍ (ប្រហែល ៧០.០០០ នាក់) និងរដ្ឋបាលសាធារណៈ (៣៥០.០០០ ការងារ)[៩] ។វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (វ.ស.ក) យល់ស្របជាមួយនាយកដ្ឋានពន្ធដារក្នុងការកំណត់និយមន័យ "វិស័យក្នុងប្រព័ន្ធ" ថាជាសហគ្រាសទាំងឡាយណាដែលបង់ពន្ធដល់នាយកដ្ឋានពន្ធដារ ក្រោមទំរង់មួយចំនួននៃអាជ្ញាប័ណ្ណ ។ តួលេខទាំងនេះផ្អែកលើទិន្នន័យដែលបានមកពីទិន្នន័យរបស់ វ.ស.ក និងមានលក្ខណៈស្របគ្នានឹងទស្សនៈដែលគេប្រកាន់យកយ៉ាងទូលាយអំពីកំរិតនៃការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធសំខាន់ៗទាំងបី ។

ដើម្បីយល់ពីសារៈសំខាន់នៃការរួមចំណែកផ្នែកសេដ្ឋកិច្ចសង្គម ដែលសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្តល់ឱ្យចំពោះផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងការងារ វ.ស.ក (EIC) បានបង្កើតវិធីសាស្ត្រ ដើម្បីប៉ាន់ស្មានតំលៃនៃវិស័យក្រៅប្រព័ន្ធចំពោះសេដ្ឋកិច្ចដែលនាំឱ្យយើងប្រៀបធៀបសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅនឹងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។ តួរលេខបង្ហាញឱ្យឃើញថាផ្នែកក្រៅប្រព័ន្ធបានរួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ច។ ការរួមចំណែកនៃវិស័យក្រៅប្រព័ន្ធបានធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលក្លាយជាផ្នែកមួយនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ ជាពិសេសវិស័យទេសចរណ៍ និងកាត់ដេរបានកើនឡើងយ៉ាងខ្លាំង ។ ទោះបីជាយ៉ាងនេះក្តី ការរួមចំណែក (៦២% នៃ ផ.ស.ស) នៃវិស័យក្រៅប្រព័ន្ធ ក្នុងសេដ្ឋកិច្ច នៅតែមានទំហំធំ (តារាងលេខ ២.១) ។

[៧] Acharya, *et al* ឆ្នាំ ២០០៣

[៨] CAID ឆ្នាំ ២០០៤

[៩] EIC ឆ្នាំ ២០០៣ ទិន្នន័យសេដ្ឋកិច្ច

**តារាងលេខ ២.១ : ទំហំនៃវិស័យក្រៅប្រព័ន្ធនៅក្នុងសេដ្ឋកិច្ច (%)**

| | ១៩៩៨ | ២០០០ | ២០០៣ |
|---|---|---|---|
| កំលាំងពលកម្ម | ៨៥% | ៨៥% | ៨៥% |
| ផ.ស.ស | ៧០% | ៦៤% | ៦២% |

*ប្រភព : វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា*

ដោយប្រើប្រាស់កំលាំងពលកម្ម ឬប្រភេទនៃការងារ បានបង្ហាញឱ្យឃើញថា សេដ្ឋកិច្ចកម្ពុជាត្រូវបានបង្កើតឡើងដោយចំណែកមួយយ៉ាងធំនៃអ្នកធ្វើការពីរក្រុមនេះ បើយោងទៅតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ ។ តារាងលេខ ២,២ បង្ហាញថា ក្នុងឆ្នាំ ២០០១ អ្នកធ្វើការពីរក្រុម គឺអ្នកប្រកបការងារដោយខ្លួនឯង និងអ្នកធ្វើការជួយគ្រួសារដោយមិនយកប្រាក់ឈ្នួល មានចំនួន ៥,២ លាននាក់ ពោលគឺ ៨៤% នៃអ្នកធ្វើការសរុបចំនួន ៦,២ លាននាក់ ។ មានលក្ខណៈគួរឱ្យចាប់អារម្មណ៍ពីរ ប៉ុន្តែមិនគួរឱ្យភ្ញាក់ផ្អើលឡើយនៃអ្នកធ្វើការទាំងពីរក្រុមនេះ : ទីមួយ ពួកគេប្រមូលផ្ដុំនៅទីជនបទ និងទីពីរចំនួននៃអ្នកប្រកបការងារដោយខ្លួនឯងនៅទីប្រជុំជនមានចំនួនច្រើនជាងចំនួនអ្នកធ្វើការជួយគ្រួសារដែលមិនយកបានប្រាក់ឈ្នួល ។

**តារាងលេខ ២.២: ទំហំប៉ាន់ស្មាននៃកំលាំងពលកម្មនៅកម្ពុជាក្នុងឆ្នាំ ២០០១**

| | អ្នកប្រកបការងារដោយខ្លួនឯង | | អ្នកធ្វើការជួយគ្រួសារដោយមិនយកប្រាក់ឈ្នួល | | អ្នកធ្វើការដទៃទៀត | | អ្នកធ្វើការសរុប |
|---|---|---|---|---|---|---|---|
| | (000') | % នៃចំនួនសរុប | (000') | % នៃចំនួនសរុប | (000') | % នៃចំនួនសរុប | |
| **កម្ពុជា** | ២ ៤៤០ | ៤០% | ២ ៧៤៧ | ៤៤% | ៩៨៨ | ១៦% | ៦ ១៧៥ |
| **ទីប្រជុំជន** | ៣០៦ | ៤២% | ១៩៧ | ២៧% | ២៣១ | ៣១% | ៧៣៤ |
| **ទីជនបទ** | ២ ១៣៤ | ៣៩% | ២ ៥៥០ | ៤៧% | ៧៥៧ | ១៤% | ៥ ៤៤១ |

*ប្រភព : សៀវភៅស្ថិតិប្រចាំឆ្នាំកម្ពុជា ឆ្នាំ ២០០៣ របស់វិទ្យាស្ថានជាតិស្ថិតិ*

ទោះបីជាមានព័ត៌មានទាំងនេះមានចំនួនច្រើនក៏ដោយ ក៏មិនមានទិន្នន័យត្រឹមត្រូវណាមួយត្រូវបានគេប្រមូលនៅក្នុងបរិបទនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជាឡើយ ។ ការប្រមូលទិន្នន័យនៅកម្ពុជាមានលក្ខណៈរប៉េះរប៉ោះ ដោយសារការខ្វះខាតធនធានមនុស្ស និងហិរញ្ញវត្ថុ ។ ប៉ុន្តែដោយមានការគាំទ្រពីសហគមន៍ហិរញ្ញវត្ថុអន្តរជាតិមួយចំនួន រួមទាំង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិសហប្រជាជាតិសំរាប់ប្រជាជន (UNFPA) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងធនាគារពិភពលោក វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានបំពាក់នូវប្រព័ន្ធស្ថិតិមួយដើម្បីធ្វើការអង្កេតផ្នែកសេដ្ឋកិច្ចសង្គម ដោយមានការផ្សព្វផ្សាយលទ្ធផលផង ។ ទោះជាយ៉ាងនេះក្តី ស្ថិតិសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនទាន់ត្រូវបានគេកំណត់ និងប្រមូលឱ្យបានច្បាស់លាស់នៅឡើយទេ។ ទិន្នន័យជាក់លាក់អំពីមុខរបរផ្សេងៗគ្នានៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅមានកំរិតនៅឡើយ[១០] ។

## ២.៣ កត្តាដែលបណ្តាលឱ្យមានកំណើននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ស្ថិតិបានបង្ហាញថា មានការកើនឡើងនូវទំហំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ។ ចំណែករួមនៃអ្នកធ្វើការក្រៅប្រព័ន្ធក្នុងកំលាំងពលកម្មក្រៅពីកសិកម្មមានចំនួនចាប់ពីជាង ៥៥% នៅអាមេរិកឡាទីន ទៅ ៤៥-៨៥% នៅក្នុងផ្នែកផ្សេងទៀតនៃអាស៊ី និងក្បែរ ៨០% នៅអាហ្វ្រិក[១១] ។ ផ្ទុយមកវិញ កំលាំងពលកម្មនៅក្នុងផ្នែកក្រៅប្រព័ន្ធនៅកម្ពុជាទំនងជាមិនមានការកើនឡើងឡើយ បើផ្អែកលើទិន្នន័យក្នុងតារាងលេខ ២.១ ខាងលើ ។

កត្តានានាដែលមានឥទ្ធិពលទៅលើទំហំនៃកំលាំងពលកម្មនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា មានលក្ខណៈដូចគ្នានឹងកត្តានៅក្នុងប្រទេសដទៃទៀត ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចតួចដែលសេដ្ឋកិច្ចមានលក្ខណៈអាចប្រៀបធៀបគ្នាបាន ។ កត្តាទាំងនេះគឺ : ការិយាធិបតេយ្យ អំពើពុករលួយ និងថ្លៃខ្ពស់នៃប្រតិបត្តិការអាជីវកម្មនៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ប្រជាជនក្រីក្រច្រើន កំណើនសេដ្ឋកិច្ចមិនគ្រប់គ្រាន់ អតិរេកនៃកំលាំងពលកម្ម និងការលុបបំបាត់ចោលទូទាំងពិភពលោកនូវប្រព័ន្ធកូតាលើការនាំចេញសំលៀកបំពាក់ ។

[១០] ទោះបីជាយ៉ាងនេះក្តី ក្នុងបំណងបង្កើនស្ថិតិនៃអនុផ្នែកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ILO-IPEC (កម្មវិធីអន្តរជាតិលុបបំបាត់ពលកម្មកុមារ ) សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ (NIS) ថ្មីៗនេះ បានផ្សព្វផ្សាយការអង្កេតរបស់ខ្លួនអំពីកុមារ ដែលបំរើនៅតាមផ្ទះក្នុងទីក្រុងភ្នំពេញ។ ជាមួយនឹងបំណងដូចគ្នាដែរ អង្គការ NGO ខ្លះ ដូចជា USG បានធ្វើការយ៉ាងជិតដិតនឹងអ្នកប្រកបរបរផ្សេងៗនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

[១១] អង្គការ ILO ឆ្នាំ ២០០២ c

## កង្វះតម្លាភាព ការិយាធិបតេយ្យដ៏ច្រើន ៈ ពេលវេលា និង ថ្លៃដើមនៃការប្រកបអាជីវកម្ម

ការិយាធិបតេយ្យ និងអំពើពុករលួយនៅកម្ពុជាមានការពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួត ដែលបណ្តាលឱ្យថ្លៃនៃការប្រកបអាជីវកម្មគ្រប់ប្រភេទបានក្លាយជាឧបសគ្គមួយគួរឱ្យបារម្ភ។ ប្រតិបត្តិករអាជីវកម្មមិនមានការលើកទឹកចិត្ត ដើម្បីស្នើសុំឋានៈអាជីវកម្មចូលក្នុងប្រព័ន្ធ លុះត្រាតែអាជីវកម្មមានទំហំធំដែលពួកគេមិនអាចគេចវេសបាន។ យោងតាមការអង្កេតរបស់ធនាគារពិភពលោក កំរិតនៃអំពើពុករលួយនៅកម្ពុជាមានកំរិតពីរដងខ្ពស់ជាងប្រទេសបង់ក្លាដេស ប៉ាគីស្ថាន និងចិន ។ ចំណាយលើអំពើពុករលួយមានប្រហែលរហូតដល់ ៥% នៃចំណូលពីការលក់ប្រចាំឆ្នាំ គឺលើសពី ៦% ចំពោះក្រុមហ៊ុនធំៗ[១២] ។ ការជៀសវាងពីការិយាធិបតេយ្យដ៏ច្រើនលើសលប់របស់រដ្ឋាភិបាល គឺជាហេតុផលចាប់បង្ខំមួយ ដែលធ្វើឱ្យសហគ្រាសមួយចំនួនព្យាយាមស្ថិតនៅក្រៅប្រព័ន្ធ។

នីតិវិធីសុំអាជ្ញាប័ណ្ណសាំញ៉ាំ និងចំណាយខ្ពស់នៃការចុះបញ្ជីធ្វើឱ្យមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម (MSMEs) ជាច្រើនធ្វើការសន្និដ្ឋានថា ការចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធគឺមិនអាចធ្វើទៅបាន[១៣]។ ប្រតិបត្តិករដែលមានបំណងធ្វើអាជីវកម្មនៅកម្ពុជា ចាំបាច់ត្រូវតែឆ្លងកាត់វង្វង់ការិយាធិបតេយ្យមួយចំនួន ។ ការសិក្សាលើការចុះបញ្ជីពាណិជ្ជកម្មរបស់សមាគមសិប្បករកម្ពុជា បង្ហាញឱ្យឃើញថា មានតែក្រុមហ៊ុនមួយចំនួនប៉ុណ្ណោះដែលត្រូវបានទាមទារឱ្យចុះបញ្ជីដោយផ្ទាល់ជាមួយនាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម ។ សហគ្រាសឯកកម្មសិទ្ធិត្រូវបានទាមទារឱ្យចុះបញ្ជីជាមួយការិយាល័យខេត្ត ឬក្រុងនៃក្រសួងពាណិជ្ជកម្ម[១៤]។ នោះនៅមិនទាន់គ្រប់គ្រាន់ទៀត ហើយមិនតែប៉ុណ្ណោះពួកគេត្រូវតែរក្សានូវលេខអត្តសញ្ញាណប័ណ្ណនៃពន្ធប៉ាតង់ និងពន្ធតំលៃបន្ថែមដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវតែទទួលបានការអនុញ្ញាតយល់ព្រមទៅលើបទបញ្ជាផ្ទៃក្នុងនៃសហគ្រាសរបស់ខ្លួនពីសំណាក់ក្រសួងការងារ ។ ប្រព័ន្ធនៃការចុះបញ្ជីនៅថ្នាក់ខេត្ត ឬក្រុងតែម្យ៉ាង វាគ្រប់គ្រាន់ណាស់ទៅហើយ ក្នុងការបំបាក់ទឹកចិត្តសហគ្រាសធុនតូចដែលឋិតនៅទីជនបទដាច់ស្រយាល ។ ទោះបីយ៉ាងនេះក្តី ប្រសិនបើសកម្មភាពអាជីវកម្មដែលស្នើឡើងទាក់ទងនឹងផ្នែកជាក់លាក់ណាមួយដែលជាប់ពាក់ព័ន្ធនឹងក្រសួងដទៃទៀត អាជ្ញាប័ណ្ណពីក្រសួងពាក់ព័ន្ធទាំងនោះត្រូវបានគេទាមទារឱ្យមានថែមទៀតដើម្បីបំពេញឱ្យគ្រប់បែបបទចុះបញ្ជីពាណិជ្ជកម្ម ។ ការចុះបញ្ជីពាណិជ្ជកម្មមួយក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធនៅកម្ពុជាត្រូវបានប៉ាន់ស្មានឃើញថា ត្រូវចំណាយប្រហែល ១៥០០ ដុល្លារអាមេរិក និងចំណាយពេលអស់ ៩៤ ថ្ងៃ[១៥] ។

---

[១២] អង្គការ ILO ឆ្នាំ ២០០៤

[១៣] AAC ឆ្នាំ ២០០៤

[១៤] *Ibid*

[១៥] IFC & MPDF ឆ្នាំ ២០០៤ a

ថ្មីៗនេះ ដំណើរការចុះបញ្ជីពាណិជ្ជកម្មថ្មីនៅក្រសួងពាណិជ្ជកម្ម ត្រូវបានគេរៀបចំឡើងវិញក្រោមកម្មវិធីកំចីមួយដែលផ្តល់ដោយ ADB ។ ជាលទ្ធផល ប្រកាសលេខ ១៦២ ចេញនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤ ដោយក្រសួងពាណិជ្ជកម្មជាផ្លូវការ បានបន្ថយថ្លៃចុះបញ្ជីមកនៅត្រឹមតែ ១៧៧ ដុល្លារអាមេរិក ។ ប៉ុន្តែការសិក្សានាពេលថ្មីៗនេះរបស់ AAC និង ILO បង្ហាញឱ្យឃើញថា បុគ្គលិកក្រសួងនេះនៅតែបន្តស្នើសុំថ្លៃសេវាសំរបសំរួល ហើយថ្លៃនៃការចុះបញ្ជីជាទូទៅមានចំនួនចាប់ពី ២៥០ ដល់ ៣០០ ដុល្លារអាមេរិក រួមទាំងថ្លៃផ្លូវការ និងថ្លៃសេវាសំរបសំរួល[១៦] ។ ជាលទ្ធផល សហគ្រាសធុនតូច និងមធ្យម (SME) ជាច្រើននៅតែមិនត្រូវបានលើកទឹកចិត្តអោយចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ គេប៉ាន់ស្មានឃើញថា មានសហគ្រាសខ្នាតតូច និងមធ្យម ចំនួនប្រហែល ២៧.០០០ សហគ្រាស នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានសំរេចមិនចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ។ មិនមានមូលហេតុគួរជាទីទាក់ទាញសំរាប់សហគ្រាសណាមួយឡើយ លើកលែងតែសហគ្រាសដែលមានបំណងធ្វើការនាំចេញ និងនាំចូលតែប៉ុណ្ណោះ ទើបសំរេចចិត្តចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។ មានមូលហេតុជាច្រើនដែលធ្វើឱ្យប្រតិបត្តិករអាជីវកម្មយល់ថាការដែលនៅក្រៅប្រព័ន្ធមានភាពប្រសើរជាង យ៉ាងហោចណាស់ក៏អាចជៀសវាងការមកត្រួតពិនិត្យដោយអធិការកិច្ចជាផ្លូវការ និងក្រៅផ្លូវការ ចាប់ពីរដ្ឋអំណាចមូលដ្ឋាន ដល់រដ្ឋបាលកណ្តាលដែលស្វែងរកសំណូក ។ ការគេចពន្ធ និងកង្វះការជឿទុកចិត្តលើតម្លាភាពរបស់រដ្ឋាភិបាលលើការគ្រប់គ្រងពន្ធ គឺជាទឡ្ហីករណ៍ដ៏មានឥទ្ធិពលសំរាប់ភាពក្រៅប្រព័ន្ធ[១៧] ។

## ភាពក្រីក្រ និង សេដ្ឋកិច្ចក្រៅប្រព័ន្ធ

ផលិតភាពទាប និងចំណូលតិច ជាពិសេសនៅតំបន់ជនបទ មានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ។ គេប៉ាន់ស្មានឃើញថា ពី ៤០ ទៅ ៤៥% នៃប្រជាជនកម្ពុជាទាំងមូលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ គម្លាតនេះមានទំហំធំធេងណាស់រវាងទីជនបទនានា ដែលរាប់បញ្ចូលទាំងទីប្រជុំជនខេត្តនានាផង និងក្រុងភ្នំពេញ ។ កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោកដែលមានចំណាត់ថ្នាក់ទី ១៣០ ក្នុងចំណោម ១៧៥ ប្រទេស បើយោងតាមរបាយការណ៍អភិវឌ្ឍមនុស្សឆ្នាំ ២០០៤ របស់ UNDP ។ លទ្ធផលជាក់ស្តែងមួយនៃគំលាតរវាងទីជនបទ និងទីក្រុង គឺការធ្វើចំណាកស្រុកមកកាន់ទីក្រុងនានា ជាពិសេសក្រុងភ្នំពេញដែលជាមជ្ឈមណ្ឌលនៃការវិនិយោគលើសណ្ឋាគារ រោងចក្រ និងក្រុមហ៊ុននានា បើប្រៀបធៀបនឹងទីជនបទ (សូមមើលតារាងលេខ ២.៣) ។

[១៦] AAC ឆ្នាំ ២០០៤

[១៧] Gërxhani ឆ្នាំ ១៩៩៩

**តារាងលេខ ២.៣ : ទីតាំងនៃរោងចក្រកាត់ដេរ និងកម្មកររោងចក្រក្នុងឆ្នាំ ២០០៣**

| | ចំនួនរោងចក្រ | | ចំនួនកម្មករ | |
|---|---|---|---|---|
| | ឯកតា | % នៃចំនួនសរុប | ឯកតា | % នៃចំនួនសរុប |
| **ភ្នំពេញ** | ១៧៦ | ៨៦% | ១៣៤.៣៤១ | ៨៧% |
| **កណ្ដាល** | ២០ | ១០% | ១៧.៣១៨ | ១១% |
| **ខេត្តដទៃទៀត** | ៩ | ៤% | ២.៨២០ | ២% |
| **សរុប** | **២០៥** | **១០០%** | **១៥៤.៤៧៩** | **១០០%** |

*ប្រភព : គណនាពីតារាងនៃរោងចក្រកាត់ដេរ ជាសមាជិកនៃសមាគមរោងចក្រកាត់ដេរកម្ពុជា GMAC*
*ចំណាំ : តារាងនេះរាប់បញ្ចូលទាំងរោងចក្រកាត់ដេរដែលកំពុងដំណើរការ ឬមិនដំណើរការ និងកំពុងសាងសង់ ។*

## កំណើនសេដ្ឋកិច្ចមិនគ្រប់គ្រាន់ និង អតិរេកនៃកំលាំងពលកម្ម

ការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលផ្ដល់នូវឱកាសការងារនៅវិស័យក្នុងប្រព័ន្ធ គឺជាកត្តាមួយដែលធ្វើឱ្យមានចលនាផ្ទុយគ្នាទៅនឹងការរីកដុះដាលនៃអ្នកធ្វើការក្រៅប្រព័ន្ធនៅកម្ពុជា ។ ការវិនិយោគផ្ទាល់ពីបរទេសដែលបានកើនឡើង និងធ្លាក់ចុះនៅទសវត្សមុន ដែលជាការឆ្លើយតបនឹងស្ថានភាពនយោបាយ និងសេដ្ឋកិច្ចបានបង្កើតការងារក្នុងប្រព័ន្ធខ្លះៗ ប៉ុន្តែមិនគ្រប់គ្រាន់ ដើម្បីស្រូបយកនូវចំនួនដ៏ច្រើននៃអ្នកចំណូលថ្មីក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំឡើយ ។ FDI ដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានកើនដល់ចំនួន ៥១៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ ១៩៩៦ និងធ្លាក់ចុះមកនៅ ៣៨៣ លានដុល្លារអាមេរិក ក្នុងឆ្នាំ ១៩៩៧ ដោយសារវិបត្តិនយោបាយក្នុងប្រទេស និងវិបត្តិសេដ្ឋកិច្ចក្នុងតំបន់ ប៉ុន្តែបានកើនឡើងវិញដល់ ៤៧៨ លានដុល្លារអាមេរិក នៅឆ្នាំ ២០០០[១៨] ។ ក្នុងឆ្នាំ ២០០៣ មានគំរោងថ្មីចំនួន ៥១ បានចុះបញ្ជីជាមួយក្រុមប្រឹក្សានេះ ដើម្បីវិនិយោគដែលមានទឹកប្រាក់ចំនួន ២៦៣ លានដុល្លាអាមេរិក ។ ទោះជាយ៉ាងនេះក្ដី គំរោងទាំងនោះនឹងបង្កើតការងារដោយផ្ទាល់ចំនួនត្រឹមតែ ៣៣.៧០៣ ការងារតែប៉ុណ្ណោះ[១៩] ។ ចំនួននេះទាបឆ្ងាយណាស់ជាងចំនួនអ្នកចូលមកកាន់ទីផ្សារការងារ ដែលគេប៉ាន់ស្មានឃើញថា អាចកើនដល់ជាង ២០០.០០០ នាក់ក្នុងមួយឆ្នាំ ។ លើសពីនេះទៅទៀត គួរកត់សំគាល់ថា តួលេខ FDI ទាំងនេះគ្រាន់តែបង្ហាញពីតំលៃនៃគំរោង ដែលបានអនុម័តប៉ុណ្ណោះ ។ រដ្ឋាភិបាលកម្ពុជាមិនបានព្យាយាមប្រមូលទិន្នន័យអំពី FDI ដែលបាន

[១៨] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)-ស្ថិតិនៃគណៈកម្មការវិនិយោគកម្ពុជា

[១៩] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ចំណោយឡើយ ។ ចំនួនពិតប្រាកដនៃ FDI ក្នុងឆ្នាំណាមួយទំនងជាមានតំលៃទាបជាងតំលៃដែលបានឯកភាពនៃគំរោងទៅទៀត ។

## ការលុបបំបាត់ចោលកូតារបស់អាមេរិក និងអនាគតនៃការនាំចេញសំលៀកបំពាក់

កត្តាសក្តានុពលមួយទៀតដែលអាចបង្កើនទំហំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺការលុបបំបាត់ចោលកូតាសំរាប់ការនាំចេញផលិតផលសំលៀកបំពាក់ចាប់ពី ខែ កញ្ញា ឆ្នាំ ២០០៥ នេះទៅ ។ ការងារនៅក្នុងវិស័យកាត់ដេរឥឡូវនេះមានចំនួន ២៣០ ០០០ ដែលធ្វើឱ្យវិស័យនេះ ក្លាយជាមូលដ្ឋានគ្រឹះសំរាប់ផ្នែកក្នុងប្រព័ន្ធ ។ កម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ជាផ្នែកមួយដើម្បីការពារ និងជំរុញឧស្សាហកម្មកាត់ដេរ ។ ជាមួយនឹងការបញ្ចប់កូតាទូទាំងពិភពលោក កម្ពុជានឹងប្រកួតប្រជែងជាមួយប្រទេសដទៃទៀតរួមទាំងអ្នកប្រកួតដ៏ធំគឺប្រទេសចិន ។ ក្រៅពីចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែជួយវិស័យកាត់ដេរដោះស្រាយបញ្ហាជាច្រើនដែលរារាំងដល់ផលិតភាព និងបង្កើនថ្លៃដើម ។ ក្នុងចំណោមក្តីកង្វល់ធំៗ គឺថ្លៃខ្ពស់នៃការទូទាត់គយ ការិយាធិបតេយ្យ សំណូក ការរត់ពន្ធ និងថ្លៃថាមពលខ្ពស់ [២០] ។

បើគ្មានការកែទំរង់ដើម្បីជំរុញផ្នែកឯកជន ហើយជាពិសេសវិស័យកាត់ដេរទេនោះ ការងារក្នុងប្រព័ន្ធនឹងអាចបាត់បង់យ៉ាងច្រើន ។ កម្មករភាគច្រើនដែលបាត់បង់ការងារក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធនឹងត្រលប់ទៅរកសេដ្ឋកិច្ចក្រៅប្រព័ន្ធវិញដែលនឹងក្លាយជាជំរើសតែមួយគត់របស់ពួកគេ ។

[២០] IFC & MPDF ឆ្នាំ ២០០៤ b

# ៣ ការងារសមរម្យ និង សេដ្ឋកិច្ចក្រៅប្រព័ន្ធ

នៅក្នុងប្រទេសកម្ពុជា គេបានយកចិត្តទុកដាក់ជាវិជ្ជមានមួយចំនួន ទៅលើការលើកកំពស់ការងារសមរម្យក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។ កម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាសំខាន់ៗជាច្រើនរបស់ ILO និងបន្តអភិវឌ្ឍ និងកែលំអច្បាប់ការងារ[២១] ។ មានការរីកចំរើនក្នុងការកំណត់សិទ្ធិរបស់កម្មករនិយោជិត ។ ទោះបីជាយ៉ាងណាក៏ដោយ ការយកចិត្តទុកដាក់នេះកម្រផ្តោតលើសេដ្ឋកិច្ចក្រៅប្រព័ន្ធណាស់ ។ ហេតុដូច្នេះ ទើបគ្មានការសិក្សាស្រាវជ្រាវអំពីការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ដើម្បីសំរេចគោលដៅនេះ ការវាស់វែងរបស់ ILO លើឱនភាពការងារនឹងត្រូវបានប្រើប្រាស់ ហើយយើងនឹងពិនិត្យទៅលើកត្តាទាំងបួន នៃនិយមន័យស្តីពីការងារសមរម្យគឺ : ការងារ សិទ្ធិ ការការពារខាងសង្គមកិច្ច និងភាពតំណាង ។

## ៣.១. ឱនភាពនៃការងារ

ឱនភាពការងារនៅក្នុងទស្សនាទាននៃការងារសមរម្យសំដៅដល់ល័ក្ខខ័ណ្ឌដែលមនុស្សមិនអាចរកបានការងារធ្វើ ឬធ្វើអាជីវកម្មក្នុងរង្វង់សេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ដោយសារគ្មានឱកាសការងារនៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ មនុស្សងាកទៅរកការងារដែលមិនសូវឱ្យផល និងមិនសូវទទួលបានប្រាក់ឈ្នួលច្រើន ។

ទំហំ និងការកើនឡើងនូវសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា អាស្រ័យដោយមនុស្សមិនអាចស្វែងរកការងារ ឬធ្វើអាជីវកម្មនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធបាន ។ខណៈដែលសេដ្ឋកិច្ចក្រៅប្រព័ន្ធ យ៉ាងហោចណាស់ក្នុងន័យការងារបានបន្តកើនឡើងនៅកម្ពុជា គេក៏អាចសន្និដ្ឋានបានថា មានការធ្លាក់ចុះនូវឱកាសការងារសមរម្យនៅក្នុងប្រទេសនេះ ។

គេអាចសន្និដ្ឋានបានថា កម្ពុជាបានទទួលរងឱនភាពការងារយ៉ាងខ្លាំងក្នុងន័យការងារសមរម្យ ។ ទោះបីជាកំលាំងពលកម្មមួយផ្នែកធំប្រហែលត្រូវបានបំរើការជាអ្នកប្រកបការងារដោយខ្លួនឯង ឬជាអ្នកធ្វើការដោយមានប្រាក់ឈ្នួល ឬគ្មានប្រាក់ឈ្នួលក្តី ក៏មុខរបរទាំងនេះជំនួសឱ្យការងារ និងឱកាសដែលមិនអាចរកបាននៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។

[២១] ក្រសួងការងារនៃសហរដ្ឋអាមេរិក និងស្ថានទូតអាមេរិក ប្រចាំនៅភ្នំពេញ ឆ្នាំ ២០០៣

ភាគរយនៃការងារនៅទីក្រុងដែលមានលក្ខណៈក្រៅប្រព័ន្ធនៅកម្ពុជា មានទំហំធំ គឺ ៦៩% ( សូមមើលតារាងលេខ ៣.១ ) ។

**តារាងលេខ ៣.១ : ភាគរយនៃផ្នែកក្រៅប្រព័ន្ធក្នុងការងារនៅទីក្រុង នៅប្រទេសអាស៊ីខ្លះ**

| ប្រទេស | | | ប្រភព |
|---|---|---|---|
| បង់ក្លាដេស......... | ៥៩% | (១៩៩៥-១៩៩៦) | **Mahmud ( 2001, p.9)** |
| ឥណ្ឌា.......... | ៤៤% | (១៩៩៣) | របាយការណ៍ស្តីពីពលកម្មពិភពលោក **(2000, p. 285)** |
| ប៉ាគីស្ថាន.......... | ៦៧% | (១៩៩៦) | របាយការណ៍ស្តីពីពលកម្មពិភពលោក **(2000, p. 285)** |
| ឥណ្ឌូនេស៊ី.......... | ៦៣% | (១៩៩០) | **Firdausy (1996, p.105)** |
| ថៃ.......... | ៤៨% | (១៩៩៤) | របាយការណ៍ស្តីពីពលកម្មពិភពលោក **(2000, p. 285)** |
| សាធារណរដ្ឋកូរេ.... | ២៧% | (១៩៨០) | ការិយាល័យជំរឿននៃសហរដ្ឋអាមេរិក |
| កម្ពុជា (* )..... | ៦៩% | (២០០១) | សៀវភៅប្រចាំឆ្នាំ **2003** |

*ប្រភព : អង្គការ ILO ឆ្នាំ ២០០៥ b*

*(*) រួមបញ្ចូលតែអ្នកប្រកបការងារដោយខ្លួនឯង និងអ្នកធ្វើការជួយគ្រួសារដោយមិនយកប្រាក់ឈ្នួល ( ដកស្រង់ពីតារាងលេខ ២.២ ) ។*

មានឱកាសតិចតួចណាស់សំរាប់អ្នកធ្វើការក្រៅប្រព័ន្ធ និងប្រតិបត្តិករអាជីវកម្មក្រៅប្រព័ន្ធ ដើម្បីប្រែក្លាយទៅជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ភាពក្រៅប្រព័ន្ធនៃការងាររបស់ពួកគេគឺជារបាំងចំពោះលទ្ធភាពចូលទៅដល់ស្ថាប័នឥណទាន និងទីផ្សារ ។ ពួកគេត្រូវតែងាកទៅរកអ្នកចងការប្រាក់ក្រៅប្រព័ន្ធ ហើយបង់ការប្រាក់ខ្ពស់។ អ្នកធ្វើការក្រៅប្រព័ន្ធខ្វះលទ្ធភាពទទួលបានការបណ្តុះបណ្តាល និងខ្វះចំណេះដឹង ហើយជំនាញបច្ចេកទេសបានកំរិតពួកគេឱ្យទទួលបានផលិតភាពទាប។ សហគ្រាសគេហជននៅទីជនបទមានត្រឹមតែជំនាញទទួលបានពីសមាជិកគ្រួសារ ញាតិមិត្ត ឬអ្នកផ្គត់ផ្គង់សំភារៈបរិក្ខាប៉ុណ្ណោះ[២២] ។ អ្នកធ្វើការដែលមិនបានទទួលការបណ្តុះបណ្តាលទាំងនេះ មានការលំបាកក្នុងការធានានូវឋានៈនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ របាយការណ៍ពីការស្រាវជ្រាវមួយ ដោយក្រុមសំរបសំរួល

[២២] Acharya, *et al* ឆ្នាំ ២០០៣

អភិវឌ្ឍន៍ទីក្រុង (USG) លើមីក្រូសហគ្រាសស្ត្រីដែលមានមូលដ្ឋាននៅទីក្រុងនៅភ្នំពេញ បង្ហាញឱ្យឃើញថា ៤១% នៃពួកគេជ្រើសរើសយកមុខរបរលក់ដូរតូចតាច ពីព្រោះពួកគេខ្វះទុន ហើយពួកគេក៏គ្មានជំរើសផ្សេងទៀតដែរ (២៦%) ដោយសារមានកំរិតវប្បធម៌ និងជំនាញទាប[២៣] ។

## ៣.២. ឱនភាពនៃសិទ្ធិ

អ្នកធ្វើការក្រៅប្រព័ន្ធ រាប់បញ្ចូលទាំងអ្នកធ្វើការមានប្រាក់ឈ្នួល អ្នកប្រកបការងារដោយខ្លួនឯង និងប្រតិបត្តិករក្រៅប្រព័ន្ធមិនត្រូវបានគេទទួលស្គាល់ ឬគ្រប់គ្រងដោយរដ្ឋាភិបាល និងមិនសិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ ក្រោមច្បាប់ការងារ និងបទប្បញ្ញត្តិការងារ ព្រមទាំងបទប្បញ្ញត្តិពាណិជ្ជកម្មឡើយ ។ ដូច្នេះ អ្នកធ្វើការទាំងនេះជានិច្ចកាលទទួលរងនូវការជំរិតយកប្រាក់ ការស៊ីសំណូក ការបង្ក្រាប និងការយាយីរំខាន ហើយជួនកាលមានការបៀតបៀនខាងផ្លូវភេទទៀតផងពីសំណាក់អាជ្ញាធរសាធារណៈ ។ អ្នកលក់ដូរតូចតាចនៅទីក្រុងភ្នំពេញ ជាទូទៅមានការត្អូញត្អែរចំពោះការដេញ និងយាយីរំខានពីសំណាក់សន្តិសុខ និងប៉ូលីស[២៤] ។

ការយាយីរំខាននេះ កើតមានដោយកន្លែង និងបានធ្វើឱ្យពួកគាត់មានការធុញទ្រាន់យ៉ាងខ្លាំង។ ឧទាហរណ៍ មានការកើតឡើងបញ្ហាជាច្រើន ដែលក្នុងនោះប៉ូលីស "យល់ច្រឡំ" សកម្មភាពនានានៃអាជីវកម្មតូចតាចទាំងនេះ ដែលមិនត្រូវបានគ្រប់គ្រងដោយច្បាប់ជាមួយនឹងសកម្មភាពមិនស្របច្បាប់ ដែលភ្នាក់ងារប៉ូលីសទាំងនោះត្រូវបានទទួលការណែនាំអោយចុះបង្ក្រាប ។ នៅក្នុងទីក្រុងភ្នំពេញ ជួនកាលប៉ូលីសដោះយកគំរបធុងសាំងម៉ូតូ ឬខ្សែក្បាលប៊ូហ្សុីពីម៉ូតូរបស់អ្នករត់ម៉ូតូឌុប បន្ទាប់មកទាររកការបង់ប្រាក់ថ្លៃផាកពិន័យជាថ្នូរនឹងវត្ថុទាំងនោះ។ អ្នកលក់បន្លែចាំបាច់ត្រូវបង់ប្រាក់ជាប្រចាំថ្ងៃឱ្យក្រុមប៉ូលីសជាសំណូក។ បើមិនដូច្នោះទេ បុគ្គលិកសន្តិសុខនឹងមិនអនុញ្ញាតិឱ្យដាក់លក់ឡើយ ។ អ្នកលក់តាមដងផ្លូវផ្សេងៗទៀត ត្អូញត្អែរពីការបង់ប្រាក់ជាសំណូកឱ្យទៅប៉ូលីស ដើម្បីអាចលក់បាន។ ជួនកាលរបស់របររបស់ពួកគាត់ត្រូវបានរឹបអូសយកដោយប៉ូលីស និងត្រូវតែទៅស្ថានីយ៍ប៉ូលីស ហើយត្រូវបង់ប្រាក់ដើម្បីបានរបស់ទាំងនោះត្រលប់មកវិញ[២៥] ។

អ្នកធ្វើការក្រៅប្រព័ន្ធមិនត្រូវបានគ្របដណ្តប់ដោយច្បាប់ការងារឡើយ ជាពិសេសដោយសារតែគ្មានទំនាក់ទំនងជានិយោជិត និងនិយោជកដែលត្រូវបានគេទទួលស្គាល់ជាផ្លូវការ។ ដូច្នេះ ពួកគាត់មិនអាចទាមទារប្រាក់ឈ្នួលអប្បបរមា មិនអាចទទួលជំនួយសង្គ្រោះអោយចេញផុតពីល័ក្ខខ័ណ្ឌការងារដ៏អន់ថយ និងការជួយឧបត្ថម្ភផ្សេងៗជាដើម ។

[២៣] Agnello, *et al* ឆ្នាំ ២០០៤

[២៤] Ibid

[២៥] USG ឆ្នាំ ២០០៣

ជាងនេះទៀត សិទ្ធិមានកម្មសិទ្ធិរបស់អ្នកធ្វើការក្រៅប្រព័ន្ធ ជានិច្ចកាលមិនត្រូវបានការយកចិត្តទុកដាក់ឡើយ ។ នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ប្រជាពលរដ្ឋរស់នៅក្នុងផ្ទះតូចចង្អៀត ដែលពួកគេមិនមែនជាម្ចាស់កម្មសិទ្ធិទេ ដូច្នេះពួកគេត្រូវធ្វើតាមចិត្តម្ចាស់ផ្ទះដែលជាអ្នកជួលផ្ទះអោយ ។ បើសិនជាមានការបង្ខំឱ្យចាកចេញ ជាទូទៅពួកគាត់ត្រូវទៅតាំងទីលំនៅ នៅតំបន់តាមជាយក្រុង ដែលនៅទីនោះខ្វះហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ផ្លូវ ប្រព័ន្ធបង្ហូរទឹក ការប្រមូលសំរាម ទឹកស្អាត អគ្គិសនី ការការពារទឹកជំនន់ សាលារៀន មន្ទីរពេទ្យ មធ្យោបាយធ្វើដំណើរផ្សេងៗ[២៦] ។ ការទទួលបានហេដ្ឋារចនាសម្ព័ន្ធសាធារណៈមិនគ្រប់គ្រាន់នេះ បណ្តាលឱ្យមានបញ្ហាសុខភាព និងសុវត្ថិភាពដ៏ធ្ងន់ធ្ងរ ។

## ៣.៣. ឱនភាពនៃការការពារខាងសង្គមកិច្ច :

ឱនភាពនៃការការពារខាងសង្គមកិច្ច គឺជាទិដ្ឋភាពមួយផ្សេងទៀតនៃឱនភាពការងារ ដែលមានការពាក់ព័ន្ធទៅនឹងអសន្តិសុខនៃការងារ ចំណូល និងគ្មានការការពារនៅកន្លែងការងារ និងនៅក្នុងសង្គម ។ បន្ថែមទៅលើពីឱនភាពការងារ និងឱនភាពនៃសិទ្ធិនោះ អ្នកធ្វើការក្រៅប្រព័ន្ធងាយនឹងទទួលរងគ្រោះ ពីព្រោះពួកគាត់ទទួលបានតិចតួច ឬក៏មិនទទួលបានសោះនូវការការពារខាងសង្គមកិច្ច ។

អ្នកធ្វើការក្រៅប្រព័ន្ធមិនត្រូវបានគ្របដណ្តប់ដោយច្បាប់ការងារទេ ដូច្នេះហើយពួកគាត់មិនអាចពឹងផ្អែកទៅលើច្បាប់ស្តីពីរបបសន្តិសុខសង្គម ដើម្បីទទួលបានផលប្រយោជន៍ និងការការពារណាមួយពីច្បាប់នេះឡើយ ។ មាត្រា ១ នៃច្បាប់ស្តីរបបសន្តិសុខសង្គមចែងយ៉ាងច្បាស់ថា ច្បាប់នេះមានគោលបំណងបង្កើតឱ្យមានសន្តិសុខ សំរាប់ជនទាំងឡាយណាដែលគ្របដណ្តប់ដោយច្បាប់ការងារ ។ បើតាមនិយមន័យ អ្នកធ្វើការក្រៅប្រព័ន្ធត្រូវបានដកហូតមិនឱ្យទទួលបានអត្ថប្រយោជន៍ពីការចូលនិវត្តន៍ ប្រាក់បំណាច់ពេលមានជំងឺ និងគ្រោះថ្នាក់ការងារ ដូចជា ការកើតមានគ្រោះថ្នាក់ពេលធ្វើការ និងគ្រោះថ្នាក់ផ្នែកសុខភាពនៅកន្លែងធ្វើការរបស់ខ្លួនឡើយ ។ តែប្រហែលជាអ្នកធ្វើការក្រៅប្រព័ន្ធមិនបានបាត់បង់ច្រើនទេ នៅពេលដែលច្បាប់ស្តីពីរបបសន្តិសុខសង្គមរបស់កម្ពុជាមិនទាន់ត្រូវបានគេអនុវត្តនៅឡើយ ។

អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធកំពុងទទួលរងហានិភ័យនៃគ្រោះថ្នាក់ផ្នែកសុខភាព និងសុវត្ថិភាពការងារដ៏ធ្ងន់ធ្ងរ ។ ឧទាហរណ៍មួយនៃល័ក្ខខ័ណ្ឌការងារពោរពេញដោយទុក្ខលំបាកនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺជីវិតនៃអ្នករើសសំរាម ឬអ្នករើសអេតចាយ ។ ពួកគេធ្វើការទាំងថ្ងៃទាំងយប់ ដើម្បីប្រមូលសំរាម និងអេតចាយនៅទូទាំងទីក្រុង និងនៅកន្លែងចាក់សំរាមដែលស្ថានភាពអនាម័យនៅទីនោះអាក្រក់ពិបាកនឹងទ្រាំ ។ អ្នករើសសំរាម ឬអេតចាយភាគច្រើន ជាក្មេងតាមចិញ្ចើមផ្លូវ ដើររើសសំរាមដែល

[២៦] សារពត៌មានសហគមន៍ ឆ្នាំ ២០០៣

អាចប្រើ និងលក់បានដើម្បីបំពេញចំណូលគ្រួសាររបស់ខ្លួន។ ជាមួយនឹងអ្នករើសសំរាមដែលមានវ័យច្រើនជាងខ្លួន ក្មេងរើសសំរាមទាំងនោះ ត្រូវគេមើលឃើញនៅពាសពេញទីក្រុង ដែលជាញឹកញាប់ដើរកាន់ស្បោងធំៗ ឬរុញរទេះធុនធំៗ។ របស់របរដែលពួកគេប្រមូលបានជាវត្ថុដែលអាចមានគ្រោះថ្នាក់បំផុត។ នៅក្នុងប្រទេសកម្ពុជាគ្មានប្រព័ន្ធគ្រប់គ្រងសំរាប់ប្រភេទនៃសំរាមផ្សេងៗទាំងនេះទេ។ សំណល់ ឬសំរាមដ៏មានគ្រោះថ្នាក់ទាំងនេះ ដែលចេញមកពីរោងចក្រប្រើជាតិគីមី ឬមន្ទីរពេទ្យ ត្រូវបានគេចាក់គរដូចសំរាមរបស់គ្រួសារធម្មតាដែរ។ ដោយគ្មានប្រដាប់ការពារ ដូចជា ស្រោមដៃ ស្បែកជើងការពារ និងម៉ាស់រុំមុខ ក្មេងរើសសំរាមទាំងនោះតែងតែប្រឈមមុខទៅនឹងហានិភ័យផ្នែកសុខភាពជាប្រចាំ។ ពួកគេបានជួបប្រទះនូវគ្រោះថ្នាក់ជាញឹកញាប់នៅពេលដែលពួកគេសំរុកចូលទៅក្នុងគំនរសំរាមដែលទើបនឹងយកមកចាក់ថ្មីៗនោះ ដោយមិនបានប្រុងប្រយ័ត្នចំពោះឡានដឹកសំរាម ឬម៉ាស៊ីនដែលកំពុងដំណើរការនៅកន្លែងនោះ[២៧]។

ក្មេងមួយក្រុមទៀតដែលស្ថិតទំរង់ធ្ងន់ធ្ងរបំផុតមួយនៃពលកម្មកុមារ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាអ្នកបំរើនៅតាមផ្ទះ។ ដូចពលករកុមារដទៃទៀតដែរ ពួកគេបានបោះបង់ចោលការសិក្សា ហើយបែរមកធ្វើការក្រោមល័ក្ខខ័ណ្ឌការងារដ៏លំបាកក្រៃលែង។ យោងទៅតាមការអង្កេតលើអ្នកបំរើតាមផ្ទះជាកុមារ (CDW) នៅក្នុងទីក្រុងភ្នំពេញ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ សហការជាមួយ ILO-IPEC មានអ្នកបំរើនៅតាមផ្ទះជាកុមារប្រហែលជា ២៨,០០០ នាក់។ ខណៈដែល ៥៥,៤ ភាគរយ នៃក្មេងទាំងនេះធ្វើការផង និងបានចូលរៀននៅសាលាផងនោះ ៤០ ភាគរយទៀតលែងទៅរៀន ហើយ ៤,៦ ភាគរយទៀតមិនដែលបានចូលសាលាសោះ។ ជារួម ១៤,២ ភាគរយនៃកុមារទាំងនេះមិនចេះអក្សរ[២៨]។

មិនត្រឹមតែសមាសធាតុនៃការរៀបចំជាមូលដ្ឋានសំរាប់ជីវិតយុវវ័យរបស់ពួកគេត្រូវបានដកពីកុមារទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែល័ក្ខខ័ណ្ឌការងាររបស់ពួកគេជានិច្ចកាលមានសភាពពុំល្អ និងពោរពេញដោយទុក្ខលំបាក។ ការធ្វើអង្កេតនេះបានបង្ហាញថា ការងារនិងការរស់នៅឆ្ងាយពីផ្ទះ និងគ្រួសារទាំងនៅក្មេងវ័យបានធ្វើឱ្យប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ពួកគេ ។ ជួនកាល ពួកគេត្រូវបានបង្ខំឱ្យធ្វើការរយៈពេលយូរច្រើនម៉ោង ដោយគ្មានពេលសំរាកគ្រប់គ្រាន់ ។ ពួកគេកំពុងប្រឈមមុខនឹងគ្រោះថ្នាក់នៃការបៀតបៀនខាងផ្លូវភេទ និងការរំលោភនានា រាប់បញ្ចូលទាំងការប្រមាថ និងការប្រើអំពើហឹង្សាលើរាងកាយផងដែរ។ ពួកគេបានទទួលកំរៃ ឬប្រាក់ឈ្នួលតិចតួច ឬក៏គ្មានសោះ។ ពួកគេមិនស្ថិតក្នុងតួនាទីណាមួយ ដើម្បីចរចាលើល័ក្ខខ័ណ្ឌនៃកិច្ចសន្យារបស់ខ្លួន ឬក៏ទទូចសុំការផ្តល់ជំនួយ ដូចជា ការធានារ៉ាប់រងផ្នែកសុខភាពនោះទេ។ ពួកគេគ្មានសេរីភាព សូម្បីតែចេញពីក្នុងផ្ទះដែលពួកគេស្នាក់នៅធ្វើការក៏ដោយ[២៩]។

[២៧] កិច្ចសម្ភាសន៍ជាមួយអាជ្ញាធរគ្រប់គ្រងកាកសំណល់នៅទីក្រុងភ្នំពេញ (PPNM)

[២៨] ក្រសួងផែនការ (NIS) និង ILO-IPEC ឆ្នាំ ២០០៤

[២៩] អង្គការ ILO ឆ្នាំ ២០០៤

អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនមានលទ្ធភាពទទួលបានការអប់រំក្នុងប្រព័ន្ធ ឬការបណ្តុះបណ្តាលនោះទេ។ ជំនាញរបស់ពួកគេ ជាទូទៅត្រូវបានបង្ហាត់បង្រៀនដោយសមាជិកគ្រួសារ។ ជំនាញ និងផលិតភាពរបស់ពួកគេមានកំរិតទាប ហើយចំណូលជាទូទៅគ្មានស្ថេរភាពទេ។ ជាមធ្យមពួកគេប្រហែលជារកបានចាប់ពី ១ ដុល្លារទៅ ២ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ដោយអាស្រ័យទៅតាមទីកន្លែង ឬមុខរបរ[៣០]។ ជំនាញមានកំរិតទាបបានធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពការងាររបស់ពួកគេ ពីព្រោះពួកគេគ្មានចំណេះដឹងគ្រប់គ្រាន់ក្នុងការប្រើប្រាស់នូវឧបករណ៍ ឬម៉ាស៊ីនមួយចំនួន។

ល័ក្ខខ័ណ្ឌការងារនៃអ្នកធ្វើការតាមផ្ទះ ក៏មានលក្ខណៈអន់ថយផងដែរ។ ការងារតាមផ្ទះនៅក្នុងប្រទេសកម្ពុជា រួមមានប្រភេទផ្សេងៗនៃសកម្មភាពផលិតទ្រង់ទ្រាយតូច ដូចជា ការកាត់ដេរសំលៀកបំពាក់ ត្បាញ សិប្បកម្ម គ្រឿងសង្ហារឹមធ្វើពីដែក និងឈើជាដើម។ សម្ភារៈ ឧបករណ៍ និងម៉ាស៊ីនដែលនាំចូលមកប្រើនៅក្នុងផ្ទះ ជួនកាលបង្កឱ្យមានជា គ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពកាងារទៅដល់អ្នកធ្វើការទាំងនោះ និងសមាជិកគ្រួសាររបស់ពួកគេទៀតផង។ ការធ្វើទស្សនកិច្ចមើលកន្លែងការងារតាមផ្ទះនាពេលថ្មីៗនេះ ដែលធ្វើឡើងដោយគំរោងសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់ ILO បានបង្ហាញថាកម្មករស្ទើរតែទាំងអស់មិនមានការយល់ដឹងពីហានិភ័យផ្នែកសុវត្ថិភាព និងអនាម័យការងារទេ។ ពួកគេទទួលបានពត៌មានតិចតួចស្តីពីសុវត្ថិភាពការងារ និងអំពីរបៀបការពារខ្លួនពីគ្រោះថ្នាក់ជាសក្តានុពលទាំងនេះ និងរបៀបធានាឱ្យមាននូវបរិយាកាសប្រកបដោយសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការតាមផ្ទះរបស់ខ្លួន។ ហានិភ័យទាំងនេះរួមមាន ប៉ុស្តឹការងារពិបាកៗ ការធ្វើការច្រើនម៉ោងពេក ការប្រើប្រាស់ម៉ាស៊ីនដែលគ្មានរបាំងការពារ ការប៉ះពាល់ផ្ទាល់ជាមួយជាតិគីមី ពន្លឺមិនគ្រប់គ្រាន់ និងគ្រោះថ្នាក់ដោយសារអគ្គីសនី និងអគ្គីភ័យ។ អ្នកធ្វើការតាមផ្ទះនៅក្នុងប្រទេសកម្ពុជាត្រូវការចាំបាច់នូវការគាំទ្រផ្នែកបច្ចេកទេសជាបន្ទាន់ និងការចាត់វិធានការជាក់ស្តែង ដើម្បីធ្វើឱ្យសុខភាព សុវត្ថិភាព និងល័ក្ខខ័ណ្ឌការងាររបស់ពួកគេបានប្រសើរឡើង[៣១]។

នៅក្នុងប្រទេសកម្ពុជា មេរោគអេដស៍ និងជំងឺអេដស៍ បានបង្កឱ្យមានទ្វេរគ្រោះដ៏ធ្ងន់ធ្ងរមួយទៀត ទាក់ទងទៅនឹងកង្វះការការពារខាងសង្គមកិច្ចសំរាប់អ្នកធ្វើការ។ កម្ពុជាមានអត្រាការឆ្លងមេរោគអេដស៍ (HIV) ខ្ពស់នៅក្នុងទ្វីបអាស៊ី។ មានអ្នកឆ្លងជំងឺថ្មី ចំនួន ២០ នាក់ ជារៀងរាល់ថ្ងៃ។ មានការប៉ាន់ប្រមាណថា មនុស្សជាង ១៦០.០០០ នាក់ អាចត្រូវបានឆ្លងមេរោគអេដស៍នៅត្រឹមឆ្នាំ ២០០៥[៣២]។ គ្មានពត៌មានណាច្បាស់លាស់ប្រាកដ ដើម្បីបង្ហាញឱ្យឃើញថា អត្រានៃការឆ្លងមេរោគអេដស៍នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធខ្ពស់ជាងនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធនោះទេ ។ ប៉ុន្តែចំនួនដ៏ច្រើននៃអ្នកធ្វើការក្នុងសេដ្ឋកិច្ច

[៣០] សមាគម CAID ឆ្នាំ ២០០៤ លទ្ធផលដែលបានរកឃើញពីរបាយការណ៍នៃការអង្កេតមួយ ដែលមានកំណត់ទៅមុខរបរ ចំនួនប្រាំគឺ : កសិករ អ្នកចាក់ ស៊ីក្លូ អ្នករត់ម៉ូតូឌុប ឬម៉ូតូកង់បី អ្នកលក់ដូរនៅក្នុងផ្សារ និងអ្នកលក់ដូរតាមដងផ្លូវ ។

[៣១] អង្គការ ILO ឆ្នាំ ២០០៤ b

[៣២] អង្គការ UNDP ឆ្នាំ២០០៣

ក្រៅប្រព័ន្ធ បើតាមស្ថិតិបញ្ជាក់ថា មានចំនួនអ្នកឆ្លងច្រើនជាងនេះទៀតក្នុងចំណោមអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ អត្រាដ៏ខ្ពស់នៃការឆ្លងពិតជាបង្កឱ្យមានជាបញ្ហាសុខមាលភាពសង្គមយ៉ាងខ្លាំង។ អ្នកឆ្លងជំងឺនេះ ជាទូទៅជួបប្រទះនឹងការរើសអើងពីសំណាក់អ្នកជិតខាង និងពីនិយោជករបស់ខ្លួន ហើយពេលខ្លះបាត់បង់ការងារទៀតផងនៅពេលស្ថានភាពជំងឺរបស់គេត្រូវបានគេដឹងគ្រប់ៗគ្នា។ ពួកគេត្រូវតែបង់ចំណាយសំរាប់ការថែទាំសុខភាពទាំងអស់ ឬភាគច្រើន។ នៅពេលដែលផលិតភាពរបស់ពួកគេធ្លាក់ចុះ ពេលនោះចំណូលក៏មិនមានស្ថេរភាពដែរ។ ប្រសិនបើ អ្នកឆ្លងមេរោគជាអ្នករកស៊ីចិញ្ចឹមគ្រួសារវិញ សាច់ញាតិរបស់គេ រាប់ទាំងកូន និងអ្នកចាស់ៗផង ចាំបាច់ត្រូវជួយរកប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់គ្រួសារ។ ដោយហេតុតែកត្តាទាំងនេះ កូនរបស់ពួកគេអាចនឹងបាត់បង់មធ្យោបាយ និងលទ្ធភាពទៅរៀននៅសាលា[៣៣] ។

វាច្បាស់ណាស់ថា អ្នកធ្វើការក្រៅប្រព័ន្ធទទួលរងនូវល័ក្ខខ័ណ្ឌការងារមិនល្អ អស្ថេរភាពនៃចំណូល និងហានិភ័យផ្នែកសុខភាព និងសុវត្ថិភាពការងារដ៏ធ្ងន់ធ្ងរ។ កុមារដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចជួបប្រទះនូវការគំរាមកំហែងផ្នែកផ្លូវចិត្ត និងផ្នែករាងកាយហើយទទួលរងនូវគ្រោះថ្នាក់សុខភាព មានឱកាសទទួលបានការអប់រំតិចតួច ឬក៏គ្មាន ព្រមទាំងធ្វើការនៅក្នុងល័ក្ខខ័ណ្ឌដែលគ្មានសុវត្ថិភាព ឬគ្មានអនាម័យ។ ស្ថិតក្នុងកាលៈទេសៈនេះ បុរស ស្ត្រី និងកុមារច្រើនរាប់មិនអស់ មិនទទួលបាននូវជីវិតដែលប្រកបទៅដោយសុខភាពល្អ និងផលិតភាពពលកម្មនោះទេ ដោយសារតែមានការអប់រំតិចតួច និងស្ថានភាពសុខភាពមិនល្អរបស់ពួកគេ។

## ៣.៤. ឱនភាពនៃភាពតំណាង

ក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ សេរីភាពក្នុងការបង្កើតជាសមាគម កំពុងតែមានការអភិវឌ្ឍកាន់តែប្រសើរឡើង ដោយស្ថិតនៅក្រោមកិច្ចការពាររបស់រដ្ឋធម្មនុញ្ញ និងច្បាប់ការងារកម្ពុជា។ ឧទាហរណ៍មានចំនួនសហជីពបានកើនសន្ទុះយ៉ាងច្រើន ដោយបានចុះបញ្ជីចាប់ពី ២០ សហជីពនៅឆ្នាំ ១៩៩៧ ទៅដល់ ២៤៥ សហជីពនៅខែ មករា ឆ្នាំ ២០០២ ។ សហព័ន្ធចំនួន ៤ និងសហជីពចំនួន ១០៨ បានចុះបញ្ជីនៅក្នុងអំឡុងឆ្នាំ ២០០១ តែមួយប៉ុណ្ណោះ ។ ជារួមសហព័ន្ធ និងសហជីពជាតិចំនួន ៩ ដែលបានចុះបញ្ជីហើយនោះមានសមាជិកប្រហែល ១៦០.០០០ នាក់ ។ សហជីពក្នុងវិស័យឧស្សាហកម្មតំណាងឱ្យ ២៥ ភាគរយនៃអ្នកធ្វើការទាំងមូល ។ មិនដូចវិស័យឧស្សាហកម្មទេ មានតែសហជីពចំនួន ២៧ ប៉ុណ្ណោះ ក្នុងចំណោម ២៤៥ ដែលបានចុះបញ្ជីហើយនោះ ស្ថិតនៅក្នុងវិស័យផ្សេងៗទៀត[៣៤] ។

[៣៣] អង្គការ ILO ឆ្នាំ ២០០៤ a

[៣៤] ក្រសួងការងារសហរដ្ឋអាមេរិក *et al* ឆ្នាំ ២០០៣

សិទ្ធិរបស់និយោជិតដើម្បីធ្វើកូដកម្មត្រូវបានគេបង្កើតឡើង និងកំពុងត្រូវបានគេប្រើដោយបានទទួលលទ្ធផលខ្លះៗ។ មានកូដកម្មចំនួន ៨០ ក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០១ ។ ការអនុវត្តសិទ្ធិ ដើម្បីរៀបចំបង្កើតសហជីព និងការចរចាធ្វើអនុសញ្ញារួម កំពុងត្រូវបានគេប្រើយ៉ាងច្រើនផងដែរ ។ អនុសញ្ញារួមចំនួន ២០ ត្រូវបានគេចុះបញ្ជីកាជាមួយនឹងរដ្ឋាភិបាលកម្ពុជា ទោះបីជាអនុសញ្ញារួមទាំងនេះគ្រាន់តែចង់បញ្ជាក់អះអាងឡើងវិញឱ្យបានច្បាស់បន្ថែមទៅលើសិទ្ធិ ដែលមានស្រាប់នៅក្នុងច្បាប់ការងាររបស់កម្ពុជាក្តី ។

ទោះបីជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជារឿងមួយផ្សេងទៀត ។ ប្រសិនបើមិនមានកិច្ចការពារពីច្បាប់ការងារនោះទេ អ្នកធ្វើការមានប្រាក់ឈ្នួល និងអ្នកប្រកបរបររកស៊ីដោយខ្លួនឯង ទំនងជាទទួលរងនូវល័ក្ខខ័ណ្ឌការងារមិនល្អ ។ អ្នកធ្វើការស៊ីប្រាក់ឈ្នួលក្រៅប្រព័ន្ធធ្វើការដោយមិនមានកិច្ចសន្យាការងារឡើយ ។ ការកាន់កាប់មុខតំណែង និងភារកិច្ចរបស់ពួកគេ គឺអាស្រ័យលើតែឆន្ទានុសិទ្ធិនៃនិយោជកររបស់ខ្លួន ។ ពួកគេមិនអាចធ្វើការចរចា និងធ្វើអនុសញ្ញារួមជាមួយនឹងនិយោជកររបស់ខ្លួន ក្នុងការទាមទារសិទ្ធិដែលគេត្រូវទទួលបាននោះទេ ។ ការខ្វះនូវអំណាចចរចាធ្វើអនុសញ្ញារួម ការភ័យខ្លាច ពីការធ្វើទុក្ខទោសដោយសារចូលរួមក្នុងអង្គការកម្មករនិយោជិតណាមួយនោះ បានធ្វើឱ្យពួកគេពឹងផ្អែកទៅលើក្តីប្រោសប្រណីនៃនិយោជកររបស់ពួកគេទាំងស្រុង ។ ពួកគេមិនមានសន្តិសុខការងារ និងអាចត្រូវបានគេបណ្តេញចេញនៅពេលណាក៏បាន ។ បន្ថែមទៅលើកត្តាទាំងនេះ អ្នកធ្វើការក្រៅប្រព័ន្ធមានជំនាញតិចតួច ឬគ្មានជំនាញសោះ ។ កត្តានេះនឹងធ្វើឱ្យគេគ្មានជំរើសណាក្រៅពីរកការងារដែលគេអាចធ្វើបាននៅក្នុងសហគ្រាសក្រៅប្រព័ន្ធនោះទេ ។

ដើម្បីឱ្យទទួលបានភាពស្មើគ្នា ផលប្រយោជន៍របស់ប្រតិបត្តិករនៃសហគ្រាសក្រៅប្រព័ន្ធ មិនគួរត្រូវបានគេមើលរំលងនោះទេ។ ពួកគេត្រូវដំណើរការនៅខាងក្រៅដែនអនុវត្តន៍និងវង្វង់ការពារនៃច្បាប់ពាណិជ្ជកម្ម ។ ពួកគេតស៊ូទប់ទល់ជាមួយនឹងបញ្ហាផ្សេងៗ ដូចជាលទ្ធភាពទទួលបានដោយមានកំរិតនូវហេដ្ឋារចនាសម្ព័ន្ធ សិទ្ធិកាន់កាប់អចលនទ្រព្យ ការបណ្តុះបណ្តាលក្នុងប្រព័ន្ធ មីក្រូឥណទាន និងទីផ្សារដែលមានការរៀបចំបានល្អ ។

សំលេងរបស់និយោជិតតែម្នាក់ មិនអាចមានឥទ្ធិពលដល់និយោជក ឬរដ្ឋាភិបាល និងអ្នកតាក់តែងគោលនយោបាយរដ្ឋបាលសាធារណៈបានទេ ។ ផ្ទុយទៅវិញ សាមគ្គីភាពក្នុងចំណោមអ្នកចូលរួមក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំងអស់អាចមានប្រសិទ្ធិភាព និងជួយពួកគេឱ្យមានសំលេងទល់នឹងរដ្ឋបាលគ្រប់គ្រង ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងភាពពិតជាក់ស្តែង អ្នកចូលរួមក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជារឿយៗមិនត្រូវបានគេរៀបចំចងក្រងជាសហជីព និងមិនមានសំលេងនោះទេ[៣៥] ហើយនៅទីណាដែលគេបានរៀបចំបង្កើតសមាគម ជានិច្ចកាលសមាគមរបស់ពួកគេមានភាពទន់ខ្សោយ ខ្វះការយកចិត្តទុកដាក់ ឬសមត្ថភាពផ្តល់សេវា

[៣៥] អង្គការ ILO ឆ្នាំ ២០០២ b

ដល់សមាជិករបស់ខ្លួន ដោយសារតែគ្មានបណ្តាញច្បាស់លាស់សំរាប់ការបញ្ចេញមតិ ឬសំលេងរបស់ពួកគេ ។ វាអាចមានការពិបាកដើម្បីបង្កើតជាអង្គការវិជ្ជាជីវៈប្រភេទនេះ ពីព្រោះសេដ្ឋកិច្ចក្រៅប្រព័ន្ធមានមុខរបរ និងសកម្មភាពផ្សេងៗគ្នាជាច្រើនដែលអ្នកចូលរួម អាចមានបញ្ហាក្នុងការទទួលស្គាល់ប្រយោជន៍រួមរបស់ខ្លួន ។ និយោជក និងអ្នកប្រកប ការងារដោយខ្លួនឯងអាចមានលក្ខណៈប្រសើរជាងបន្តិច ក្នុងការទទួលយកពេលវេលា និងឱកាសចូលរួមក្នុងសហជីព និងសមាគមនានា ប៉ុន្តែបើនិយាយជាទូទៅសំលេងជាតំណាង ក្នុងសង្គមរបស់អ្នកធ្វើការក្រៅប្រព័ន្ធមិនត្រូវបានគេដឹងឮឡើយ ។ ជាលទ្ធផល ផលប្រយោជន៍ នានារបស់ពួកគេ ដូចជា លទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ ល័ក្ខខ័ណ្ឌការងារ និង បរិយាកាសល្អប្រសើរ ព្រមទាំងការទទួលបានសេវាសន្តិសុខសង្គមផងនោះ មិនមែនជា គោលដៅនៃកិច្ចពិភាក្សានានារបស់តាក់តែងធ្វើគោលនយោបាយនោះទេ ។

## ប្រអប់លេខ ៣.១

## ភាពខុសគ្នាសំខាន់ៗមួយចំនួន : នរណាមិនត្រូវបានគេរាប់បញ្ចូលទៅក្នុងអ្វីមួយ?

វាមានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យបានច្បាស់ថាតើប្រភេទនៃការមិនរាប់បញ្ចូល ដែលជាប់ទាក់ទងទៅនឹងប្រភេទមួយណានៃអ្នកធ្វើការក្រៅប្រព័ន្ធ ថាតើជាសហគ្រាស ("អង្គភាពផលិតកម្ម") ឬជាអ្នកធ្វើការ ("និយោជិត") ។ សូមមើលតារាងខាងក្រោម ជាឧទាហរណ៍ :

| | **សហគ្រាសក្រៅប្រព័ន្ធ**<br>ជាធម្មតា មិនត្រូវបានគេរាប់បញ្ចូលទៅក្នុង: | **អ្នកប្រកបរបររកស៊ី ដោយខ្លួនឯង**<br>ជាធម្មតាមិនត្រូវ បានគេរាប់បញ្ចូលទៅក្នុង : | **អ្នកធ្វើការ**<br>(អ្នកធ្វើការតាមផ្ទះ អ្នកធ្វើការតាម កិច្ចសន្យា អ្នកធ្វើការទទួលប្រាក់បៀវត្ស ក្នុង សហគ្រាស និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ) ជាធម្មតា មិនត្រូវបានគេរាប់បញ្ចូល ទៅក្នុង : |
|---|---|---|---|
| (A) ស្ថិតិ | ស្ថិតិអាជីវកម្ម (ជំរឿន ឬការអង្កេតគ្រឹះស្ថាន) | | |
| | ស្ថិតិការងារ (ជា និយោជក) | ស្ថិតិការងារ (ជាអ្នកប្រកបរបរដោយ ខ្លួនឯង) | ស្ថិតិការងារ (ជាអ្នកធ្វើការ) |
| (B) ការចុះបញ្ជី | ការផ្តល់អាជ្ញាប័ណ្ណ និង ការចុះបញ្ជីអាជីវកម្ម សំរាប់គោលបំណងផ្សេងៗ (ឧទាហរណ៍ សំរាប់ប្រតិបត្តិការដឹកជញ្ជូន ការផលិតម្ហូបអាហារ សិទ្ធិវិនិយោគ និងនាំចេញ ជាដើម) | ការផ្តល់អាជ្ញាប័ណ្ណ និង ការចុះបញ្ជី អាជីវកម្ម | ការចុះបញ្ជីនៅក្រសួងការងារ និង សំរាប់សេវាសន្តិសុខសង្គម |
| (C) ការការពារពលកម្ម | | | ការអនុវត្តច្បាប់ការងារ និង ស្តង់ដារ អប្បបរមា នៃល័ក្ខខ័ណ្ឌការងារ (ឧទាហរណ៍ កិច្ចសន្យាការងារ ចិរវេលាធ្វើការ ប្រាក់ទ្រទ្រង់ជីវភាព ការឈប់សំរាកការការពារមាតុភាព) |
| (D) សន្តិសុខសង្គម | សេវាសន្តិសុខសង្គម | សេវាសន្តិសុខសង្គម | សេវាសន្តិសុខសង្គម |
| | ពតិមានអំពីសុវត្ថិភាព និងអនាម័យការងារ | ពតិមានអំពីសុវត្ថិភាព និងអនាម័យការងារ | ពតិមានអំពីសុវត្ថិភាព និងអនាម័យការងារ |
| (E) លទ្ធភាពទទួលបានធនធានប្រកបដោយផលិតភាព | លទ្ធភាពទទួលបានធនធានប្រកបដោយផលិតភាព (ឧទាហរណ៍ មីក្រូហិរញ្ញវត្ថុ ការពិគ្រោះយោបល់ ការបណ្តុះបណ្តាលជំនាញ) | លទ្ធភាពទទួលបានធនធានប្រកបដោយផលិតភាព (ឧទាហរណ៍ មីក្រូហិរញ្ញវត្ថុ ការពិគ្រោះយោបល់ ការបណ្តុះបណ្តាលជំនាញ) | លទ្ធភាពទទួលបាន ការបណ្តុះបណ្តាលជំនាញ |
| (F) សមាគម | សមាគមអាជីវកម្មធុនតូច | អាជីវកម្មធុនតូច សមាគមនិយោជិត និងសមាគមតាមវិស័យ | សហជីព និងទំរង់ដទៃទៀត នៃអង្គការកម្មករនិយោជិត |

**សំគាល់បន្ថែម :** ឱនភាពការងារសមរម្យអាចមើលឃើញតាមរយៈប្រភេទនៃការមិនរាប់បញ្ចូល ដូចមានរៀបរាប់ខាងលើ ពោលគឺ :

- ឱនភាពការងារ (A, B, E) : ខ្វះនូវបរិយាកាសអំណោយផលផ្នែកច្បាប់ និងគោលនយោបាយ (រួមទាំងការទទួលបានពតិមានសេដ្ឋកិច្ចជាស្ថិតិ ការចុះបញ្ជីពាណិជ្ជកម្ម) មានលទ្ធភាពតិចតួចទទួលបានធនធានប្រកបដោយផលិតភាព ។
- ឱនភាពនៃសិទ្ធិ (C) : ខ្វះនូវការការពារពលកម្ម
- ឱនភាពនៃការការពារខាងសង្គមកិច្ច (D) : ខ្វះនូវការទទួលបានសេវាសន្តិសុខសង្គម និងពតិមានស្តីពីសុវត្ថិភាព និងអនាម័យការងារ ។
- ឱនភាពនៃភាពតំណាង (F): មានឱកាសតិចតួច ឬឧបសគ្គដទៃទៀត ចំពោះសមាគម

*ប្រភព : អង្គការ ILO ឆ្នាំ ២០០៤ b*

# ២ គោលនយោបាយកម្ពុជា ចំពោះការងារសមរម្យ

ស្ថានភាពការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់កម្ពុជា ទាមទារឱ្យមានការយកចិត្តទុកដាក់ ។ ឱនភាពនៃការងារសមរម្យ មិនមែនកើតមានឡើងតែនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែក៏កើតមានឡើងនៅក្នុងប្រទេសដទៃទៀតផងដែរ ហើយបញ្ហានេះបានក្លាយទៅជាកង្វល់ដ៏ធំមួយរបស់អង្គការពលកម្មអន្តរជាតិ និងសមាជិករបស់ខ្លួនដែលរួមមាន រដ្ឋាភិបាល កម្មករនិយោជិត និងនិយោជកទូទាំងពិភពលោក ។ ការលុបបំបាត់នូវឱនភាពនៃការងារសមរម្យ គឺជាគោលដៅចំបងរបស់អង្គការពលកម្មអន្តរជាតិ[៣៦] ។ លោក Juan Somavia ជាអគ្គនាយករបស់អង្គការពលកម្មអន្តរជាតិ បានមានប្រសាសន៍ថា "គោលដៅចំបងរបស់អង្គការពលកម្មអន្តរជាតិសព្វថ្ងៃនេះ គឺដើម្បីបង្កើនឱកាសសំរាប់បុរស និងស្ត្រីឱ្យទទួលបានការងារសមរម្យ និងមានកំរៃក្នុងល័ក្ខខ័ណ្ឌនៃសេរីភាព សមធម៌ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស "[៣៧] ។ ទោះបីជាដូច្នេះក៏ដោយ អង្គការពលកម្មអន្តរជាតិមិនអាចដោះស្រាយបញ្ហានេះសំរាប់កម្ពុជាបានទេ ។ អង្គការនេះត្រូវការអន្តរាគមន៍សម្របសម្រួលរបស់រដ្ឋាភិបាលកម្ពុជា និយោជក កម្មករនិយោជិត និងភាគីពាក់ព័ន្ធដទៃទៀតក្នុងមូលដ្ឋាន ។

ដើម្បីពង្រឹងការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាគីពាក់ព័ន្ធនានាចាំបាច់ត្រូវបង្កើតគំរោង ដែលមានទិសដៅផ្តោតទៅលើសមាសភាគសំខាន់ៗបី នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជា មីក្រូសហគ្រាស អ្នកប្រកបរបររកស៊ីដោយខ្លួនឯង និងអ្នកធ្វើការមានប្រាក់ឈ្នួល ។ ភាគីពាក់ព័ន្ធ គឺសំដៅទៅលើស្ថាប័ននានា ដូចជា រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ក្រុមជួយខ្លួនឯង អង្គការតំណាង សហជីព និងអង្គការនិយោជក ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកស្ទួយការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ។

អ្នកធ្វើការក្រៅប្រព័ន្ធអាចមិនបានទទួលសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ដោយសារមូលហេតុជាច្រើន ។ ឯកសារនេះមានគោលបំណងដើម្បីបង្ហាញនូវមូលហេតុចំបងៗ និងដំណោះស្រាយនានា ដែលអាចធ្វើទៅបានសំរាប់អ្នកធ្វើការក្រៅប្រព័ន្ធ ដើម្បីទទួលបាននូវកិច្ចការពារពលកម្មជាមូលដ្ឋានមួយចំនួន ។ ឧទាហរណ៍ អ្នកធ្វើការក្រៅប្រព័ន្ធមាននៅក្រៅក្របខ័ណ្ឌច្បាប់កម្ពុជា ។ វាមានសារៈសំខាន់ណាស់ ដើម្បីបង្កើតនូវយុទ្ធសាស្ត្រប្រកបដោយ

[៣៦] អង្គការ ILO ឆ្នាំ ២០០២ a

[៣៧] អង្គការ ILO ធ្វើការលើកកំពស់ការងារសមរម្យតាមរយៈសកម្មភាពការងាររបស់ខ្លួនស្តីពីការងារ ការការពារសង្គមកិច្ច បទដ្ឋាន គោលការណ៍គ្រឹះ និង សិទ្ធិជាមូលដ្ឋានក្នុងការងារព្រមទាំងការសន្ទនាសង្គម ។ សូមមើលវិបសាយ : http://www.ilo.org/public/english/decent.htm.

ប្រសិទ្ធិភាពមួយសំរាប់បញ្ចូលអ្នកធ្វើការទាំងនេះទៅក្នុងក្របខ័ណ្ឌច្បាប់ និងការការពារ ដូចជា សន្តិសុខសង្គម និងដំណោះស្រាយវិវាទកិច្ចសន្យា ឬវិវាទការងារ ។ បញ្ហាសំខាន់ជាងនេះទៅទៀត គឺកង្វះនូវការងារធ្វើនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ពោលគឺប្រជាពលរដ្ឋមិនអាចរកការងារធ្វើបាននៅវិស័យក្នុងប្រព័ន្ធ ។ មានសំណូមពរមួយចំនួនដើម្បីបង្កើនការងារជាទូទៅក្នុងសេដ្ឋកិច្ចនេះ តាមរយៈការលើកកំពស់សហគ្រាសក្រៅប្រព័ន្ធ ។ ការគាំទ្រសហគ្រាសក្រៅប្រព័ន្ធ គឺជាវិធីមួយដើម្បីធានាឱ្យមានការងារសមរម្យ ប៉ុន្តែវាមិនមែនជាការឆ្លើយតបទៅនឹងបុព្វហេតុចំបងៗ នៃការកើតមានឡើងនូវសេដ្ឋកិច្ចក្រៅប្រព័ន្ធដ៏ធំមួយទេ ។

ជាការសំខាន់ណាស់ គឺការបណ្តុះបណ្តាលគួរតែត្រូវបានគេរៀបចំឡើង ដើម្បីបង្កើនជំនាញ និងផលិតភាពរបស់អ្នកធ្វើការក្រៅប្រព័ន្ធ ហើយការប៉ុនប៉ងទាំងឡាយគួរតែត្រូវបានគេធ្វើឡើង ដើម្បីដោះស្រាយបញ្ហានៃការការពារខាងសង្គមកិច្ចក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ជាងនេះទៅទៀត គឺមានសារៈសំខាន់បំផុតក្នុងការធ្វើឱ្យមានតំណាងរួមនៃអ្នកធ្វើការក្រៅប្រព័ន្ធ ដើម្បីអោយពួកគេមានលទ្ធភាពធ្វើការចរចាជាមួយភាគីពាក់ព័ន្ធនានា រួមទាំងប្រតិបត្តិករក្រៅប្រព័ន្ធ ។ អ្នកធ្វើការក្រៅប្រព័ន្ធនៅតែងាយរងគ្រោះ ដរាបណាសំលេង ឬការបញ្ចេញមតិរបស់ពួកគេមិនត្រូវបានគេដឹងឮ ហើយភាពតំណាងរបស់ខ្លួននៅក្នុងសង្គម មិនត្រូវបានគេយកចិត្តទុកដាក់ខ្លាំងក្លានោះទេ ។ ប្រតិបត្តិករនឹងនៅតែបន្តបោះបង់ចោលសិទ្ធិរបស់ខ្លួន ។ ឯកសារនេះនឹងធ្វើការសិក្សាស៊ីជំរៅចំពោះសកម្មភាពដែលស្នើឡើងទាំងនេះ ហើយដំណោះស្រាយជាមួយនឹងឧទាហរណ៍មួយចំនួននៃការផ្តួចផ្តើមគំនិត ដែលត្រូវបានណែនាំនៅក្នុងបរិបទនៃការងារសមរម្យសំរាប់អ្នកធ្វើការក្រៅប្រព័ន្ធនេះ ។

## ៤.១. ការបញ្ចូលសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងក្របខ័ណ្ឌច្បាប់

ដូចបានរៀបរាប់ពីខាងលើ អ្នកនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺងាយរងគ្រោះណាស់ ពីព្រោះពួកគេមិនត្រូវបានគេទទួលស្គាល់ ឬការពារដោយក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជាដែលមានស្រាប់នោះទេ ។ ជំហានដំបូងដើម្បីសំរេចបាននូវការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺត្រូវបង្កើតច្បាប់ និងយន្តការសមស្រប ដើម្បីពង្រីកនូវការការពារទៅដល់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

### ៤.១.១. ហេតុផលជាមូលដ្ឋានសំរាប់ការធ្វើសមាហរណកម្ម

មានហេតុផលមួយចំនួនសំរាប់ការធ្វើសមាហរណកម្ម ។ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាមិនបានចែងពីភាពខុសគ្នារវាងអ្នកធ្វើការក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធទេ ។ ជាងនេះទៅទៀត វាមិនសមហេតុផល ឬយុត្តិធម៌ទេ នៅពេលដែលអ្នកធ្វើការក្រៅប្រព័ន្ធមិនបានទទួលសិទ្ធិសេរីភាពរបស់ខ្លួន ដោយសារតែឋានៈរបស់គេនោះ ។ ជាងនេះទៅទៀត អនុសញ្ញាសំខាន់ៗ គឺជាមធ្យោបាយការពារអ្នកធ្វើការទាំងអស់ ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ។

### ទស្សនៈផ្សេងៗគ្នាចំពោះសេដ្ឋកិច្ចក្រៅប្រព័ន្ធ

មានទស្សនៈពីរផ្សេងគ្នា ចំពោះមធ្យោបាយដោះស្រាយបញ្ហាសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ទស្សនៈដែលប្រកាន់វិន័យចាស់ចង់បានវិធីតាមផ្លូវច្បាប់មួយ ដែលពេញចិត្តប្រើនីតិបញ្ញត្តិ និងច្បាប់ទំលាប់នានា ដើម្បីបញ្ចូលសកម្មភាពក្រៅប្រព័ន្ធទៅក្នុងដែនអនុវត្តន៍ច្បាប់របស់ប្រទេស ។ ទស្សនៈចាស់នេះក៏បានស្នើសុំថា រដ្ឋាភិបាលមិនចាំបាច់ធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធទេពីព្រោះវិស័យនេះនឹងធ្លាក់ចុះនៅពេលដែលសេដ្ឋកិច្ចក្នុងប្រព័ន្ធរីកដុះដាលឡើង ។ ចំពោះទស្សនៈប្រឆាំងវិញ គឺចង់ឱ្យមានការអភិវឌ្ឍន៍នូវវិធីសាស្ត្ររបស់ខ្លួន។ ទស្សនៈនេះបានចង្អុលបង្ហាញថា ច្បាប់ និងវិធីត្រួតពិនិត្យក្តីអាចនាំឱ្យអ្នកធ្វើការក្រៅប្រព័ន្ធប្រព្រឹត្តសកម្មភាពសេដ្ឋកិច្ចលួចលាក់បាន[៣៨] ។ ទស្សនៈប្រឆាំងនេះក៏បានគាំទ្រនូវវិធីទន់ភ្លន់មួយដែលនៅក្នុងនោះអាជ្ញាធររៀបចំគោលនយោបាយដើម្បីកែលំអលក្ខខ័ណ្ឌនានាក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ដើម្បីកែលំអលក្ខខ័ណ្ឌទាំងនេះនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺមិនមានការចែកឱ្យដាច់ស្រឡះពីគ្នានូវវិធីសាស្ត្រទាំងពីរនេះបានទេ ជាពិសេសប្រសិនបើ យន្តការការពារ និងយន្តការផ្អែកច្បាប់មានលក្ខណៈសមស្របឆ្លើយតបទៅនឹងតំរូវការ ហើយបង្កើនការរីកលូតលាស់ ។ ដោយសារលក្ខណៈសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជា មានភាពចំរុះខុសៗគ្នា ដូច្នេះទស្សនៈទាំងពីរនេះអាចយកមកអនុវត្តបាន ។

### ច្បាប់កំពូលរបស់ជាតិ

មាត្រាទី ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា កម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចបានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រាទី ២៣ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធមនុស្សទទួលស្គាល់ថា មនុស្សគ្រប់រូបមានសិទ្ធិដើម្បីធ្វើការងារ និងការពារទល់នឹងភាពគ្មានការងារធ្វើ ។

[៣៨] អង្គការ ILO ឆ្នាំ ២០០២ c

មាត្រាទី ២៣ ដដែលនេះ ក៏បានទទួលស្គាល់សិទ្ធិមនុស្សគ្រប់រូប ដើម្បីទទួលបានប្រាក់ឈ្នួលសមរម្យ ដោយគ្មានការរើសអើង រួមទាំងការការពារខាងសង្គមកិច្ច និងសិទ្ធិក្នុងការបង្កើត និងចូលរួមសហជីព ដើម្បីការពារផលប្រយោជន៍របស់កម្មករនិយោជិត ។

សិទ្ធិទាំងនេះដែលរួមមាន សិទ្ធិទទួលបានការងារ ប្រាក់ឈ្នួលស្មើគ្នា ដោយគ្មានការរើសអើង ការការពារខាងសង្គមកិច្ច និងការចរចាធ្វើអនុសញ្ញារួម គួរត្រូវបានគេផ្ដល់ឱ្យអ្នកធ្វើការកម្ពុជាគ្រប់រូប ។

ដោយមិនចាំបាច់យោងទៅដល់អនុសញ្ញាអន្តរជាតិ ប្រការចែងជាក់លាក់មួយចំនួននៃរដ្ឋធម្មនុញ្ញកម្ពុជាទទួលស្គាល់ផងដែរនូវសិទ្ធិស្មើគ្នារបស់មនុស្សគ្រប់រូបចំពោះមុខច្បាប់ដោយគ្មានការរើសអើងនូវពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ជាតិកំណើត ឋានៈសង្គម និងធនធាន (មាត្រាទី ៣១) ដូចជាសិទ្ធិដើម្បីចូលរួមក្នុងឆាកនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ (មាត្រាទី ៣៥) សិទ្ធិជ្រើសរើសការងារ សិទ្ធិទទួលបានប្រាក់ឈ្នួលស្មើគ្នាចំពោះការងារដូចគ្នា សិទ្ធិទទួលបានសន្តិសុខសង្គម និងសិទ្ធិចូលជាបានសមាជិកសហជីព (មាត្រាទី ៣៦) ។

រដ្ឋធម្មនុញ្ញក៏បានចែងផងដែរនូវកាតព្វកិច្ច ដើម្បីបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ និងនៅតំបន់ដាច់ស្រយាលទាំងអស់ ជាពិសេស ក្នុងវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ដែលផ្ដោតទៅលើគោលនយោបាយទឹក អគ្គិសនី ផ្លូវថ្នល់ និងមធ្យោបាយដឹកជញ្ជូន (បច្ចេកវិទ្យាទំនើប និងប្រព័ន្ធឥណទាន) (មាត្រាទី ៦១) ។ ចំណែកឯមាត្រាទី ៦២ វិញ តម្រូវឱ្យរដ្ឋជួយដោះស្រាយបញ្ហាផលិតកម្ម និងការពារតំលៃផលិតផលសំរាប់កសិករ និងសិប្បករ និងស្វែងរកទីផ្សារសំរាប់ពួកគេដើម្បីលក់ផលិតផល ។ ការទទួលខុសត្រូវរបស់រដ្ឋមួយទៀត គឺធានាឱ្យមានកំរិតជីវភាពប្រសើរឡើងសំរាប់ប្រជាពលរដ្ឋ (មាត្រាទី ៦៣) ។

កំរងសិទ្ធិសំខាន់ៗដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា គឺជាឧករណ៍មួយយ៉ាងសំខាន់ដែលនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលកម្ពុជាធ្វើអន្តរាគមន៍ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីធានាឱ្យមាននីតិរដ្ឋក្នុងប្រទេសកម្ពុជា ។ យោងទៅតាមរដ្ឋធម្មនុញ្ញ អ្នកធ្វើការក្រៅប្រព័ន្ធមិនគួរត្រូវបានគេចាត់ទុកថាផ្សេងពីអ្នកធ្វើការក្នុងប្រព័ន្ធទេ ។ សហគ្រិនក្រៅប្រព័ន្ធមិនគួរត្រូវបានគេមិនរវីរវល់ និងមិនយកចិត្តទុកដាក់ចំពោះការលំបាករបស់ពួកគេឡើយ ។ ពួកគេគួរតែទទួលបានសិទ្ធិស្មើគ្នា ដូចប្រតិបត្តិករ និងអ្នកធ្វើការដទៃទៀតដែរ ។

## ការប្តេជ្ញាក្រោមអនុសញ្ញាអន្តរជាតិ

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាទទួលបានសមាជិកភាពក្នុងអង្គការក្នុងតំបន់ និងអន្តរជាតិជាច្រើន រួមទាំងអង្គការពលកម្មអន្តរជាតិផងដែរ ។ ប្រទេសកម្ពុជាបានបង្ហាញនូវចំណាប់អារម្មណ៍របស់ខ្លួនក្នុងបទដ្ឋានការងារ ដោយផ្តល់សច្ចាប័នដល់អនុញ្ញាសំខាន់ៗរបស់អង្គការពលកម្មអន្តរជាតិ ដូចជា អនុសញ្ញាស្តីពីការងារដោយបង្ខំ (លេខ ២៩) អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ (លេខ ១០៥) អនុសញ្ញាស្តីពីសេរីភាពក្នុងការបង្កើតជាសមាគម និងការការពារសិទ្ធិក្នុងការបង្កើតជាអង្គការវិជ្ជាជីវៈ (លេខ ៨៧) អនុសញ្ញាស្តីពីសិទ្ធិបង្កើតជាអង្គការវិជ្ជាជីវៈ និងការចរចាធ្វើអនុសញ្ញារួម (លេខ ៩៨) អនុសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នា (លេខ ១០០) អនុសញ្ញាស្តីពីការរើសអើង (លេខ ១១១) និងអនុសញ្ញាស្តីពីអាយុអប្បបរមា (លេខ ១៣៨) ។ ថ្មីៗនេះកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (អនុសញ្ញាលេខ ១៨២) ។

### តារាងលេខ ៤.១: អនុសញ្ញាសំខាន់ៗរបស់អង្គការពលកម្មអន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័ន

| ឈ្មោះអនុសញ្ញា | លេខអនុសញ្ញា |
|---|---|
| អនុសញ្ញាស្តីពីការងារដោយបង្ខំ | ២៩ |
| អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ | ១០៥ |
| អនុសញ្ញាស្តីពីសេរីភាពក្នុងការបង្កើតជាសមាគម និងការការពារសិទ្ធិ ក្នុងការបង្កើតជាអង្គការវិជ្ជាជីវៈ | ៨៧ |
| អនុសញ្ញាស្តីពីសិទ្ធិបង្កើតជាអង្គការវិជ្ជាជីវៈ និងការចរចាធ្វើអនុសញ្ញារួម | ៩៨ |
| អនុសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នា | ១០០ |
| អនុសញ្ញាស្តីពីការរើសអើង (ក្នុងមុខរបរ និងការងារ) | ១១១ |
| អនុសញ្ញាស្តីពីអាយុអប្បបរមា | ១៣៨ |
| អនុសញ្ញាស្តីពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ | ១៨២ |

*ប្រភព : អង្គការពលកម្មអន្តរជាតិ (ILO) ឆ្នាំ ២០០១*

របាយការណ៍របស់អង្គការពលកម្មអន្តរជាតិ លេខ VI ស្តីពីការងារសមរម្យ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធបង្ហាញថា សេចក្តីថ្លែងការណ៍របស់អង្គការពលកម្មអន្តរជាតិ ស្តីពីគោលការណ៍គ្រឹះ និងសិទ្ធិការងារជាមូលដ្ឋាន និងសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់របស់ខ្លួនផ្សេងៗទៀត អនុវត្តចំពោះអ្នកធ្វើការទាំងអស់ដោយមិនគិតអំពីទំនាក់ទំនងការងារ ឬទំរង់ការនៃឋានៈការងារទេ[៣៩] ។ អនុសញ្ញាខាងលើនេះ ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានោះ គឺជាផ្នែកមួយនៃសេចក្តីថ្លែងការណ៍របស់អង្គការពលកម្មអន្តរជាតិ ។ ដូចគ្នានេះដែរ អ្នកធ្វើការក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជាគួរតែត្រូវបានគេផ្តល់សិទ្ធិជាមូលដ្ឋានដូចបានប្រកាសនៅក្នុងអនុសញ្ញាទាំងនេះ ក្នុងលក្ខណៈដូចគ្នានឹងអ្នកធ្វើការក្នុងប្រព័ន្ធដែរ ។ មានគំលាតរវាងការផ្តល់សិទ្ធិដែលគេបានប្រកាសហើយនោះ និងស្ថានភាពជាក់ស្តែងរបស់អ្នកធ្វើការក្រៅប្រព័ន្ធ ។ គោលនយោបាយនានាគួរតែត្រូវបានគេអនុម័ត ដែលអាចឱ្យគេប្រែក្លាយគោលបំណងទាំងនេះទៅជាការពិត ដូចជា សេរីភាពក្នុងការបង្កើតជាសហគម សិទ្ធិចំពោះការចរចាធ្វើអនុសញ្ញារួម និងការលុបបំបាត់គ្រប់ទំរង់ទាំងអស់នៃការងារដោយបង្ខំ និងការរើសអើងដោយមូលហេតុនៃការងារ និងមុខងារ ។

### ៤.១.២ ការពង្រីក និងការបង្កើតនិយាមសំរាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ច្បាប់ស្តីពីពាណិជ្ជកម្ម និងច្បាប់ស្តីពីការងារ

អ្នកធ្វើការក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជាមិនបានទទួលកិច្ចការពារពីប្រព័ន្ធច្បាប់ទេ ។ ទីមួយ ពួកគេមិនត្រូវបានរាប់បញ្ចូលនៅក្នុងច្បាប់ការងារឆ្នាំ ១៩៩៧ ទេ។ មាត្រាទី ១ នៃច្បាប់នេះកំណត់ដែនអនុវត្តន៍ច្បាប់ចំពោះតែទំនាក់ទំនងជានិយោជិត និងនិយោជកដែលត្រូវបានគេបង្កើតឡើងតាមកិច្ចសន្យាការងារ ។ បច្ចេកស័ព្ទ "ទំនាក់ទំនងជានិយោជិត និងនិយោជក" និង "កិច្ចសន្យាការងារ" ច្រានចោលអ្នកធ្វើការក្រៅប្រព័ន្ធ ដែលធម្មតាមិនធ្វើការនៅក្រោមកិច្ចសន្យាណាមួយ និងដែលមិនមានទំនាក់ទំនងជានិយោជិត និងនិយោជកត្រឹមត្រូវតាមច្បាប់ ។ ជាងនេះទៅទៀត ច្បាប់ការងារមិនបានរួមបញ្ចូលមុខរបរជាក់លាក់មួយចំនួននៅក្រោមបទប្បញ្ញត្តិរបស់ខ្លួននោះទេ ។ ច្បាប់នេះមិនបានរួមបញ្ចូលនូវអ្នកបំរើតាមផ្ទះ នៅក្រោមបទប្បញ្ញត្តិរបស់ខ្លួនទេ ទោះបីជាពួកគេត្រូវបានផ្តល់សិទ្ធិចំពោះសេរីភាពសហជីពក៏ដោយ។ ក្នុងវិស័យកសិកម្មជំពូកទី ៧ នៃច្បាប់នេះផ្តល់នូវការការពារពិសេសជាក់លាក់ចំពោះនិយោជិតផ្នែកកសិកម្ម ដូចជា ថិរវេលាធ្វើការ ការឧបត្ថម្ភជាសំភារៈ វិភាជន៍គ្រួសារ កន្លែងស្នាក់នៅ ប្រាក់ឧបត្ថម្ភថ្លៃផ្ទះ និងទឹក។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់នេះ[៤០] មានការលើកលែងមួយចំនួនចំពោះសេដ្ឋកិច្ចគ្រួសារ ឬផលិតករខ្នាតតូច ដែលទំនងជាស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

[៣៩] អង្គការ ILO ឆ្នាំ ២០០២ a

[៤០] មាត្រាទី ១៩៣ កថាខ័ណ្ឌទី ២ នៃច្បាប់ការងារឆ្នាំ ១៩៩៧ : ក្នុងផ្នែកនេះមិនបានអនុវត្តចំពោះសហគ្រាសគ្រួសារ ឬ ចំការតូចៗទេ ដែលផលិតសំរាប់តែទីផ្សារក្នុងស្រុក និងជាធម្មតាមិនជួលកម្មករដែលមានប្រាក់ឈ្នួលជាប់លាប់នោះទេ ។"

ទាក់ទងទៅនឹងច្បាប់ពាណិជ្ជកម្ម បច្ចុប្បន្ននេះមានច្បាប់តែមួយគត់ដែលចែងពីសហគ្រាសពាណិជ្ជកម្ម គឺច្បាប់ឆ្នាំ ១៩៩៥ ដែលជាប់ទាក់ទងទៅនឹងបទប្បញ្ញត្តិពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម ។

ច្បាប់នេះតម្រូវឱ្យអាជីវកម្មក្នុងប្រទេសកម្ពុជាចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម លើកលែងតែអាជីវកម្មណាដែលរួចពីការបង់ពន្ធលើប្រាក់ចំណេញ ។ ទោះបីជាយ៉ាងណាក៏ដោយ សិប្បករដែលសកម្មភាពរបស់ខ្លួនមានលក្ខណៈគ្រួសារ មិនត្រូវបានគេចាត់ទុកជាអាជីវកម្មជាប់ពន្ធទេ (មាត្រាទី ៤)។ ក្រសួងពាណិជ្ជកម្មកំណត់ថាអាជីវកម្មមួយជាសហគ្រាសជាប់ពន្ធ ប្រសិនបើមានចំណូលប្រចាំឆ្នាំច្រើនជាង ៦.០០០.០០០ រៀល ប្រហែល (១.៥០០ ដុល្លារអាមេរិក)។ ប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ៧៨ តម្រូវឱ្យសហគ្រាសដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ទទួលបានអាជ្ញាប័ណ្ណពីក្រសួងដើម្បីប្រកបអាជីវកម្មរបស់ខ្លួន[៤១] ។ ដូច្នេះមិនមានច្បាប់ណាតម្រូវឱ្យសិប្បករជាលក្ខណៈគ្រួសារដែលមានប្រាក់ចំណេញប្រចាំឆ្នាំតិចជាង ១.៥០០ ដុល្លារអាមេរិក ត្រូវទៅចុះបញ្ជីនោះទេ ។

## ការកែលំអច្បាប់ និងការអនុវត្តច្បាប់

វិធីមួយដើម្បីកែលំអក្របខ័ណ្ឌច្បាប់ ដោយមិនចាំបាច់មានច្បាប់ថ្មី គឺគ្រាន់តែពង្រីកការបកស្រាយច្បាប់ការងារឱ្យទូលំទូលាយ ដើម្បីឱ្យអ្នកធ្វើការក្រៅប្រព័ន្ធអាចប្រើច្បាប់នេះ ការពារសិទ្ធិរបស់ខ្លួន ។ មួយវិញទៀត បទប្បញ្ញត្តិថ្មីៗគប្បីរៀបចំឡើងសំរាប់ច្បាប់ការងារ ដោយភ្ជាប់ទៅនឹងបទប្បញ្ញត្តិពាណិជ្ជកម្មថ្មី ដើម្បីពង្រីកទៅដល់អ្នកធ្វើការ និងសហគ្រិនក្រៅប្រព័ន្ធ ។

មធ្យោបាយរបស់រដ្ឋាភិបាលដើម្បីបង្កើតច្បាប់ថ្មី ឬបកស្រាយឡើងវិញនូវច្បាប់ដែលមានស្រាប់នឹងមិនគ្រប់គ្រាន់នោះទេ ប៉ុន្តែចាំបាច់ត្រូវតែបំពេញបន្ថែមជាមួយការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព ។ រូបមន្តថ្មីត្រូវតែបង្កើតឡើងដើម្បីគ្របដណ្តប់ទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ វិធានការបន្ថែមអាចមានរួមបញ្ចូល យុទ្ធនាការដើម្បីអប់រំដល់ភាគីពាក់ព័ន្ធនានាអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ ។

តាមពិតទៅ រដ្ឋាភិបាលបានយកចិត្តទុកដាក់ជាច្រើនដែរ ចំពោះការពង្រឹងការអនុវត្តច្បាប់ការងារ ចំពោះសេដ្ឋកិច្ចក្នុងប្រព័ន្ធក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ។ ឧទាហរណ៍ ចំនួនការធ្វើអធិការកិច្ចបានកើនឡើង ហើយការចុះបញ្ជីអង្គការនិយោជក និងអង្គការកម្មករនិយោជិត ក៏បានកើនឡើងផងដែរ (សូមមើលប្រអប់លេខ ៤.១)។

[៤១] ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (MIME) ឆ្នាំ ២០០៣

**ប្រអប់លេខ ៤.១**

**ការធ្វើអធិការកិច្ចការងារពីឆ្នាំ ១៩៩៨-២០០៣**

នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានធ្វើអធិការកិច្ចការងារក្នុងសហគ្រាសចំនួន ៥.៤៩៥ ក្នុងរយៈពេល ៥ ឆ្នាំ ។ អធិការកិច្ចដទៃទៀតក៏បានធ្វើឡើងដែរ ដូចជា ការធ្វើអធិការកិច្ចការងារធម្មតាទៅលើរោងចក្រសហគ្រាសចំនួន ៣.៦៤៦ និងការធ្វើអធិការកិច្ចពិសេស ទៅលើរោងចក្រសហគ្រាសចំនួន ១.៨៤៩ ការព្រមាន ឬដាក់កំហិតចំនួន ៣.២៤៩ ករណី ការផាកពិន័យសហគ្រាស ចំនួន ៤៤០ ករណី និងការដាក់ពាក្យបណ្តឹងទៅតុលាការចំនួន ១៣២ ករណី ប្តឹងជំទាស់នឹងសហគ្រាសមួយចំនួន ។

សកម្មភាពអធិការកិច្ចការងារផ្សេងៗទៀត រួមមាន អាជ្ញាប័ណ្ណពាណិជ្ជកម្មសំរាប់សហគ្រាសចំនួន ៩៧២ ការចុះបញ្ជីសហគ្រាស ៥១៤ សំរាប់ការផ្តល់ទិដ្ឋាការ ការផ្តល់ការអនុញ្ញាតឱ្យប្រើប្រព័ន្ធបើកប្រាក់បៀវត្សអេឡិចត្រូនិក ដល់សហគ្រាសចំនួន ៨១ ការអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោងដល់សហគ្រាសចំនួន ៤៩៣ លិខិតទទួលស្គាល់ និងចុះបញ្ជី ប្រតិភូបុគ្គលិកចេញឱ្យសហគ្រាសចំនួន ៧០២ ការចុះបញ្ជីអនុសញ្ញារួមសំរាប់សហគ្រាសចំនួន ៣ ការចុះបញ្ជីសម្ព័ន្ធ សហជីពចំនួន ៧ និងសមាគមនិយោជក ១ ហើយអង្គការវិជ្ជាជីវៈចំនួន ៣៧៧ ត្រូវបានទទួលស្គាល់ជាផ្លូវការ ។

*ប្រភព : ការបូកសរុបលទ្ធផលរយៈពេល ៥ឆ្នាំ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឆ្នាំ១៩៩៨-២០០៣ ទំព័រ ១៧-១៨។*

បទប្បញ្ញត្តិពាណិជ្ជកម្ម គឺជាផ្នែកមួយទៀតដែលច្បាប់អាចបង្ហាញពីភាពមាន ប្រយោជន៍ ។ អ្នកប្រតិបត្តិករក្រៅប្រព័ន្ធមានភាពស្ទាក់ស្ទើរ ក្នុងការប្រឈមមុខ ដោះស្រាយចំពោះការលំបាកទាំងឡាយនៃនីតិវិធីចុះបញ្ជីដែលតម្រូវឱ្យមានលិខិតស្នាម ច្រើន ស៊ីពេលវេលាយូរ និងមានតំលៃថ្លៃ ។ ការធ្វើឱ្យមាននីតិវិធីចុះបញ្ជីទាំងនេះមានភាព ងាយស្រួល និងការកាត់បន្ថយការចំណាយ និងពេលវេលា គឺមានសារៈសំខាន់ណាស់ ក្នុងការលើកទឹកចិត្តដល់សមាជិកទាំងអស់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសមីក្រូសហគ្រាស សហគ្រាសធនតូច និងមធ្យម (MSMEs) ដើម្បីធ្វើឱ្យសហគ្រាសទាំងនេះមានលក្ខណៈ ផ្លូវការ និងចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

វិស័យឯកជនក្នុងប្រទេសកម្ពុជា តាមរយៈសេដ្ឋកិច្ចក្នុងប្រព័ន្ធ ត្រូវបានគេលើក ស្ទួយ តាមរយៈការលើកទឹកចិត្តនានា ដូចជាការលើកលែងពន្ធជាដើម ។ អ្នកប្រកបអាជីវកម្ម ក្រៅប្រព័ន្ធមិនដែលបានទទួលការលើកទឹកចិត្តដូចនេះទេ ។

ការផ្តល់នូវការលើកទឹកចិត្តនានាចំពោះសេដ្ឋកិច្ចក្រៅប្រព័ន្ធ កំពុងតែស្ថិតនៅក្នុង របៀបវារៈរបស់រដ្ឋាភិបាលកម្ពុជា។ ដើម្បីពង្រីកនូវនីតិបញ្ញត្តិឱ្យគ្របដណ្តប់លើសហគ្រាស ធុនតូច និងមធ្យម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានធ្វើសេចក្តីព្រាងច្បាប់មួយ សំរាប់គ្រប់គ្រងការបង្កើតសហគ្រាស នៅក្រោមការជួយឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)[42] ។

[៤២] របាយការណ៍ប្រចាំឆ្នាំ របស់ក្រសួងពាណិជ្ជកម្មសំរាប់ឆ្នាំ ២០០៣

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងដើម្បីគ្រប់គ្រងគ្រឹះស្ថានឧស្សាហកម្ម និងអាជីវកម្មផ្នែកសិប្បកម្មទាំងអស់ ដែលស្ថិតនៅក្រោមយុត្តាធិការត្រួតពិនិត្យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ សេចក្តីព្រាងច្បាប់នេះកំណត់និយមន័យគ្រឹះស្ថានឧស្សាហកម្មថា ជារោងចក្រ បើចំនួនកម្មករនិយោជិតនៃរោងចក្រនេះលើសពី ៥០នាក់ ។ គ្រឹះស្ថានឧស្សាហកម្ម ដែលមានជួលកម្មករនិយោជិតចាប់ពី ១១ នាក់ ទៅដល់ ៤៩ នាក់ ត្រូវបានចាត់ទុកថាជាប្រភេទសិប្បកម្ម ។ សេចក្តីព្រាងច្បាប់តំរូវឱ្យមានការជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ ឬសង្កាត់ និងចុះបញ្ជីជាមួយមន្ទីរឧស្សាហកម្មខេត្តក្រុង ក្នុងរយៈពេល ៧ថ្ងៃ ដើម្បីបង្កើតជាអាជីវកម្ម ។ សេចក្តីព្រាងនោះមានលើកឡើងអំពីបញ្ហាសុវត្ថិភាពទាក់ទងនឹងអគ្គិភ័យ ការគ្រប់គ្រងកាកសំណល់ ឧបករណ៍ គ្រឿងម៉ាស៊ីន និងសារធាតុគីមី គ្រោះថ្នាក់ ឬជាតិផ្ទុះ ។ សេចក្តីព្រាងក៏មានបញ្ជាក់ពីលទ្ធភាពនៃការលើកទឹកចិត្តមួយចំនួន ដែលត្រូវកំណត់ដោយអនុក្រិតរបស់នាយករដ្ឋមន្ត្រី និងវិធានការត្រួតពិនិត្យមួយចំនួនធ្វើឡើងដោយក្រសួង ព្រមទាំងទោសទណ្ឌក្នុងករណីរំលោភលើបទប្បញ្ញត្តិណាមួយដែលតម្រូវឱ្យគោរពតាម រួមទាំងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីផងដែរ ។ ថ្វីបើមានខចែងអំពីការលើកទឹកចិត្តមួយចំនួន ដែលគេបានគ្រោងឡើងសំរាប់សហគ្រាសខ្នាតតូច និងមធ្យមក្តី ក៏បន្ទុកនៃការតម្រូវអោយចុះបញ្ជីអាជីវកម្មដ៏ស្មុគ្រស្មាញ ដែលមានស្រាប់រួចទៅហើយនោះ នឹងរារាំងដល់ដំណើរការអាជីវកម្ម ។ លើសពីនេះទៀត សេចក្តីព្រាងច្បាប់នេះនឹងដាក់សហគ្រាសក្រៅប្រព័ន្ធដែលប្រឈមនឹងការដាក់បន្ទុកធ្ងន់នៃការចុះបញ្ជី និងថ្លៃចុះបញ្ជីអោយនៅក្រៅវង្វង់ក្របខ័ណ្ឌច្បាប់ ។

## ៤.២. ការអភិវឌ្ឍន៍សហគ្រាស ដើម្បីបង្កើនផលិតភាព និងគុណភាពការងារ

ដោយមានអត្រាអ្នកគ្មានការងារធ្វើជាផ្លូវការតិចជាង ០.៥ ភាគរយ[៤៣] ប្រទេសកម្ពុជាហាក់ដូចជាមិនមានបញ្ហាលើអ្នកអត់មានការងារធ្វើទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ផលិតភាពរបស់អ្នកធ្វើការ (បង្ហាញក្នុងតារាងលេខ ៤.២) ក៏នៅមានកំរិតទាបដូចគ្នាដែរ ។ យោងទៅតាមការសិក្សាមួយរបស់ធនាគារពិភពលោកនាពេលថ្មីៗនេះ ទៅលើបរិយាកាសវិនិយោគក្នុងតំបន់ ក្រុមហ៊ុន និងកម្មករនិយោជិតកម្ពុជា គឺមានផលិតភាពទាបជាងសហភាគីរបស់ខ្លួន ក្នុងប្រទេសចិន ឥណ្ឌា ប៉ាគីស្ថាន ឬបង់ក្លាដេស[៤៤] ។

[៤៣] អត្រាជាផ្លូវការដែលចេញដោយវិទ្យាស្ថានជាតិស្ថិតិ ។

[៤៤] ធនាគារពិភពលោក ឆ្នាំ ២០០៤

## តារាងលេខ ៤.២: ផលិតភាពរបស់កម្មករនិយោជិត (តំលៃជាដុល្លារអាមេរិក ឆ្នាំ ២០០០)

| | ២000 | ២00១ | ២00២ | ២00៣ (រំពឹងទុក) |
|---|---|---|---|---|
| កសិកម្ម | ៣៣២ | ៣២៨ | ៣២៧ | ៣៤៥ |
| ឧស្សាហកម្ម | ១.៧២៦ | ១.៨៣៤ | ១.៩២៥ | ២.0២១ |
| សេវាឯកជន (*) | ២.0៦២ | ២.១១៩ | ២.២២៩ | ២.២៤១ |

*ប្រភព: វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) ឆ្នាំ ២00៤*

*(*) មិនរួមបញ្ចូលរដ្ឋបាលសាធារណៈទេ*

ដូច្នេះ បញ្ហានឹងបណ្តាលឱ្យកំរិតភាពគ្មានការងារធ្វើគ្រប់គ្រាន់កាន់តែខ្ពស់ឡើង ។ ក្នុងន័យនេះ កម្ពុជាត្រូវប្រឈមមុខនឹងផលិតភាព និងចំណូលទាប ជាពិសេសនៅតំបន់ជនបទ ។ រដ្ឋាភិបាលចាំបាច់ត្រូវតែផ្តោតយកចិត្តទុកដាក់លើការពង្រឹងផលិតភាពនៃកំលាំងពលកម្ម និងចំណូលក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលកំលាំងពលកម្មភាគច្រើនត្រូវបានគេប្រើប្រាស់ ។ ប្រសិនបើទទួលជោគជ័យ ការកើនឡើងនូវផលិតភាព និងចំណូលនឹងនាំទៅដល់ការរីកលូតលាស់សេដ្ឋកិច្ច ហើយដោយរួមផ្សំជាមួយគោលនយោបាយសមរម្យដទៃទៀត ការរីកលូតលាស់នេះអាចមាននិរន្តរភាពក្នុងសេដ្ឋកិច្ចទាំងមូលផងដែរ ។

សហគ្រាសធុនតូច និងមធ្យម មានសារៈសំខាន់ណាស់សំរាប់ភាពមានការងារធ្វើនៅក្នុងវិស័យសេដ្ឋកិច្ច ។ មានការជាប់ទាក់ទងគ្នាយ៉ាងច្បាស់រវាងសហគ្រាសធុនតូច និងមធ្យមទៅនឹងល័ក្ខខ័ណ្ឌការងារ ។ ដោយប្រឈមមុខនឹងឧបស័គ្គធំៗចំពោះការចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ សហគ្រាសធុនតូច និងមធ្យម ទំនងជាជួលសមាជិកគ្រួសារជាកំលាំងពលកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ ការជំរុញសហគ្រាសក្រៅប្រព័ន្ធមិនបានន័យថាជាការបរាជ័យមួយ ក្នុងការជំរុញការងារសមរម្យនោះទេ ប៉ុន្តែអាចជាផ្នែកមួយនៃដំណោះស្រាយចំពោះឱនភាពការងារ និងកង្វះនូវការងារសមរម្យ[៤៥] ។ ចំពោះសំណូមពរដែលស្នើឱ្យគេលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ដើម្បីបង្កើនការងារ និងចំណូលនោះក៏មានចង្អុលបង្ហាញក្នុងអនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ លេខ ១៨៩ ដែរ គឺ "អនុសាសន៍សំរាប់ការបង្កើតការងារ ក្នុងសហគ្រាសធុនតូច និងមធ្យម"[៤៦] ។ អនុសាសន៍នេះបានកត់សំគាល់ពីភាពសំខាន់របស់សហគ្រាសធុនតូច និងមធ្យម ចំពោះការបង្កើតការងារ

[៤៥] អង្គការ ILO ឆ្នាំ ២00២ a

[៤៦] សំរាប់អត្ថបទទាំងមូលស្តីពី អនុសាសន៍នេះ សូមមើលវិបសាយរបស់អង្គការពលកម្មអន្តរជាតិ (ILO) http://www.ilo.org.ilolex/english/recdisp1.htm .

និងការរីកលូតលាស់សេដ្ឋកិច្ច ក៏ដូចជា ការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងសក្តានុពលនៃសហគ្រាសធុនតូច និងមធ្យម សំរាប់ឱ្យក្រុមស្ត្រី និងក្រុមជនខ្សត់ខ្សោយដទៃទៀត មានលទ្ធភាពទទួលបានការងារធ្វើប្រកបដោយគុណភាព និងចីរភាព ។ អនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ ដាក់ចេញនូវសកម្មភាពជាច្រើន ទាក់ទងទៅនឹងការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ដូចជា ការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលនាំទៅដល់ការរីកលូតលាស់ និងការអភិវឌ្ឍវិស័យនេះ ការបង្កើតវប្បធម៌សហគ្រាស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាកម្មប្រកបដោយប្រសិទ្ធិភាព និងតួនាទីផ្សេងៗគ្នារបស់អង្គការនិយោជក និងអង្គការកម្មករនិយោជិត សំរាប់អនុវត្ត និងក្នុងការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ។ អនុសាសន៍នេះមិនបានរើសអើងប្រឆាំងនឹងសហគ្រាសដែលមានទំហំតូចៗនោះទេ ឬប្រភេទនៃអាជីវកម្មណាមួយឡើយ ពីព្រោះអនុសាសន៍នេះបានចង្អុលបង្ហាញយ៉ាងច្បាស់នូវខថែងនានារបស់វា ដែលមិនត្រឹមតែអនុវត្តចំពោះសហគ្រាសធុនតូច និងមធ្យមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តចំពោះផ្នែកនានានៃសកម្មភាពសេដ្ឋកិច្ច រួមទាំងមីក្រូសហគ្រាស និងសហគ្រាសធុនតូច សហគ្រាសគ្រួសារផងដែរ ។

ដើម្បីឱ្យទៅដល់ក្រុមអ្នកក្រីក្រជាងគេ និងក្រុមខ្សត់ខ្សោយផ្សេងទៀត គោលនយោបាយ ដែលបង្កើតឡើងដោយរដ្ឋាភិបាលសំរាប់ការបង្កើនប្រាក់ចំណូល គួរតែផ្តោតការយកចិត្តទុកដាក់ទៅលើមីក្រូសហគ្រាស និងសហគ្រាសធុនតូចផងដែរ ។ រដ្ឋាភិបាលចាំបាច់ត្រូវតែលុបបំបាត់កត្តាមួយចំនួន ដែលរារាំងដល់ការរីកលូតលាស់សហគ្រាសក្រៅប្រព័ន្ធទាំងនេះ ។ ការសិក្សាមួយទៅលើការអភិវឌ្ឍមីក្រូសហគ្រាស និងសហគ្រាសធុនតូចក្នុងប្រទេសកម្ពុជា បានបង្ហាញនូវឧបសគ្គនានាចំពោះការរីកលូតលាស់រួមទាំង ការប្រកួតប្រជែងជាមួយទំនិញនាំចូល គុណភាពផលិតផលអន់ខ្សោយ អានុភាពនៃការទិញនៅទាបថ្លៃដើមខ្ពស់ និងលទ្ធភាពរកបានថាមពលនៅមានកំរិត ការយកប្រាក់តាមផ្លូវមានច្រើន ការខ្វះទុនបង្វិល ការអប់រំ និងជំនាញបច្ចេកទេសនៅមានកំរិតទាប ផ្លូវនានាក្នុងមូលដ្ឋាន និងក្នុងប្រទេសទាំងមូលមានសភាពមិនល្អ និងកង្វះនូវពតិមានល្អៗអំពីទីផ្សារ[៤៧] ។

ទោះបីជាយ៉ាងណាក៏ដោយ គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជានៅមិនទាន់បានដោះស្រាយពីបញ្ហាមីក្រូសហគ្រាសនៅឡើយទេ ។

## ៤.២.១. គោលនយោបាយរបស់រដ្ឋាភិបាល

គោលនយោបាយរដ្ឋាភិបាលបានផ្តោតជាសំខាន់ទៅលើសហគ្រាសធុនតូច និងមធ្យម (SME) ជាជាងទៅលើមីក្រូសហគ្រាស និងសហគ្រាសធុនតូច (MSE) ។ សហគ្រាសធុនតូច និងមធ្យម ត្រូវបានគេចាត់ទុកថា ជាសមាសភាពដ៏ចំបងមួយនៃការ

[៤៧] អង្គការ ILO ឆ្នាំ ២០០០

អភិវឌ្ឍសេដ្ឋកិច្ច មានចំនួនប្រហែល ៩០ ភាគរយ នៃវិស័យឯកជនកម្ពុជា ដែលបង្កើតដោយសហគ្រាសធុនតូច និងមធ្យម ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងស្ថានភាពជាក់ស្តែង សហគ្រាសធុនតូច និងមធ្យមជាច្រើនរបស់កម្ពុជា គឺមានទំហំជាខ្នាតមីក្រូ ហើយស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ទាំងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់រដ្ឋាភិបាល ឆ្នាំ ១៩៩៦-២០០០ និងឆ្នាំ ២០០១-២០០៥ និងយុទ្ធសាស្ត្រចតុកោណថ្មី ទាំងអស់នេះបានបង្ហាញពីលក្ខណៈលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមឆ្នាំ ១៩៩៦-២០០០ បានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើន សំរាប់កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាល[៤៨] ។ ក្នុងចំណោមសមាសភាគនៃផែនការអភិវឌ្ឍន៍ដំបូង មានកម្មវិធីមួយ ដែលយោងទៅរកការលើកស្ទួយសហគ្រាសធុនតូច ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការបង្កើតការងារ *"ការបង្កើតការងារតាមរយៈផលិតកម្មអតិពលកម្មសំរាប់ការនាំចេញ ការលើកស្ទួយសហគ្រាសធុនតូច និងវិស័យក្រៅប្រព័ន្ធនៅទីក្រុង និងការអភិវឌ្ឍវិស័យទេសចរណ៍"* ។ នៅក្នុងផ្នែកស្តីពី "ការបង្កើតឱ្យមានការងារតាមរយៈវិស័យឯកជន" ផែនការនេះបានចាត់ទុកសហគ្រាសគ្រួសារជនបទ និងកសិករ ជាផ្នែកមួយនៃវិស័យឯកជនផងដែរ ទន្ទឹមពេលដែលគាំទ្រលើកស្ទួយសហគ្រាសធុនតូច និងធុនធំ ។ ផែនការនេះក៏បានទទួលស្គាល់ពីតំរូវការដើម្បីបង្កើនចំណូលនៅតាមតំបន់ជនបទ និងអនុភាពនៃការទិញ ដើម្បីបង្កើតឱកាសសំរាប់អភិវឌ្ឍន៍សហគ្រាសធុនតូច ។

ផែនការទីពីរ ឆ្នាំ ២០០១-២០០៥ ដែលរៀបរាប់ពីភាពចាំបាច់នៃការអភិវឌ្ឍវិស័យឯកជនក្នុងការកាត់បន្ថយភាពក្រីក្រ[៤៩] ។ ផែនការនេះអំពាវនាវឱ្យមានការបង្កើតនូវបរិយាកាសអាជីវកម្មដែលអាចទាយទុកជាមុនបាន និងប្រកបដោយភាពវិជ្ជមានច្រើន ដើម្បីធ្វើឱ្យសំរេចគោលដៅអភិវឌ្ឍន៍ជាតិ ។ ផែនការនេះក៏បានផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយចាត់ទុកសហគ្រាសទាំងនេះជាម៉ាស៊ីនសំរាប់បង្កើនការវិនិយោគ ចំណូល និងភាពមានការងារធ្វើច្រើនឡើងជាងមុន ។

សហគ្រាសធុនតូច និងមធ្យមនៅតែជាចំណុចផ្តោតរបស់រដ្ឋាភិបាលកម្ពុជា ។ ផែនការថ្មីរបស់រដ្ឋាភិបាលបានរួមបញ្ចូលគោលនយោបាយសំរាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ទៅក្នុង "យុទ្ធសាស្ត្រចតុកោណសំរាប់ការរីកលូតលាស់ ភាពមានការងារ សមធម៌ និងប្រសិទ្ធិភាព" របស់ខ្លួន ។ គោលនយោបាយទាំងនេះស្វះស្វែងឱ្យមានការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈវិធានការមួយចំនួនដូចជា : ការផ្តល់ហិរញ្ញវត្ថុ ការទប់ស្កាត់អំពើរត់ពន្ធ ការកាត់បន្ថយនូវបន្ទុកសាំញ៉ាំនៃនីតិវិធីចុះបញ្ជីពាណិជ្ជកម្ម ការជួយសំរួលនូវបែបបទនាំចេញ-នាំចូល រួមទាំង ការផ្តល់អាជ្ញាប័ណ្ណ ការគាំទ្រដល់សហគ្រាសដែលទើបតែបង្កើតថ្មី ការបង្កើនទំនាក់ទំនងរវាងសហគ្រាសធុនតូច មធ្យម និងធុនធំ ការបង្កើតមជ្ឈមណ្ឌលជាតិសំរាប់កែលំអផលិតភាព និងកាត់បន្ថយ

[៤៨] ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទីមួយ ១៩៩៦-២០០០ ក្រសួងផែនការ ។

[៤៩] ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម លើកទី២ ២០០១-២០០៥ ក្រសួងផែនការ ។

ថ្លៃដើមផលិតកម្ម ការបង្កើតនូវវិទ្យាស្ថានជាតិកំណត់ស្តង់ដារ ដោយមានបំពាក់មន្ទីរពិសោធន៍ ដើម្បីធានាថា ផលិតផលមានស្តង់ដារត្រឹមត្រូវ និងគុណភាពល្អ ការពារកម្មសិទ្ធិបញ្ញា ការបង្កើនការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ និងការពង្រឹងនូវក្របខ័ណ្ឌច្បាប់សំរាប់សហគ្រាសធុនតូច និងមធ្យម ។

គោលនយោបាយនានារបស់រដ្ឋាភិបាល ដោយរួមផ្សំនឹងការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម គឺមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ ។ ទោះបីជាយ៉ាងណាក៏ដោយលទ្ធផលនៃការអនុវត្តគោលនយោបាយទាំងនេះ គឺពឹងផ្អែកទៅលើសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីប្រែក្លាយផែនការសកម្មភាពទាំងនេះឱ្យទៅជាសកម្មភាពជាក់ស្តែង។ ដោយយល់ឃើញថា សហគ្រាសក្រៅប្រព័ន្ធ រួមទាំងវិស័យឯកជនទាំងមូលបានប្រឈមមុខជាមួយនឹងបញ្ហាជាច្រើន ទាំងរដ្ឋអំណាចមូលដ្ឋាន និងរដ្ឋាភិបាលជាតិទាំងមូលអាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងសេវារបស់ខ្លួន ដោយកាត់បន្ថយនូវថ្លៃដើមអាជីវកម្ម (ដូចជា ការយកប្រាក់តាមផ្លូវ និងថ្លៃចុះបញ្ជីដ៏ខ្ពស់) ហើយផ្តល់ឱ្យប្រតិបត្តិករអាជីវកម្មក្រៅប្រព័ន្ធនូវការិយាធិបតេយ្យរបស់រដ្ឋាភិបាលដែលមានភាពស័ក្តិសិទ្ធិប្រសិទ្ធិភាពខ្ពស់ ។

## ៤.២.២. គំនិតផ្តួចផ្តើមសំរាប់អភិវឌ្ឍន៍សហគ្រាសក្នុងប្រទេសកម្ពុជា

កម្មវិធីជំនួយចំរុះក្នុងតំបន់មួយដែលត្រូវបានគេស្គាល់ថា ជាកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ បានផ្តល់ជាយាន្តមួយសំរាប់សហគ្រាសធុនតូច និងមធ្យម ក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ ដើម្បីទទួលបានឱកាសពង្រឹងដំណើរការអាជីវកម្មរបស់ខ្លួន ស្វែងរកការវិនិយោគ ពង្រឹងសមត្ថភាព និងផ្តល់នូវជំរើសហិរញ្ញវត្ថុផ្សេងៗ[៥០] ។ គំរោងនេះនាំទៅដល់ការបង្កើតការងារប្រហែល ២.៦០០ កន្លែង ។ ជាងនេះទៅទៀត កម្មវិធីបណ្តុះបណ្តាលអ្នកគ្រប់គ្រងបានផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកគ្រប់គ្រង និងម្ចាស់សហគ្រាសធុនតូច និងមធ្យម ចំនួន ១.៦០០ នាក់[៥១] ។ រវាងឆ្នាំ ២០០២ និង ២០០៣ ក្នុងបរិបទកម្មវិធីអភិវឌ្ឍន៍អាជីវកម្ម សៀវភៅអនុវត្តន៍ស្តីពីទីផ្សារចំនួន ៦.៤០០ ក្បាល និងសៀវភៅអនុវត្តន៍ស្តីពីការគ្រប់គ្រងធនធានមនុស្សប្រហែល ៣០០ ក្បាល ត្រូវបានគេលក់អស់ ។

កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ បានជួយបង្កើតសមាគមសហគ្រាស ដូចជា សមាគមសណ្ឋាគារ និងផ្ទះសំណាក់ អង្គរសៀមរាប និងបង្កើតកម្មវិធីពាណិជ្ជកម្មមួយសំរាប់សមាគមនេះ ដើម្បីផ្សព្វផ្សាយ ឬបង្កើតទីផ្សារអាជីវកម្មរបស់ពួកគេ

[៥០] MPDF របាយការណ៍ប្រចាំឆ្នាំ ២០០២/៣ ។

[៥១] MPDF របាយការណ៍ប្រចាំឆ្នាំ ២០០១

តាមរយៈប្រព័ន្ធអ៊ិនធឺណែត ។ ការផ្តល់ប្រឹក្សាអំពីការបង្កើតគេហទំព័រដល់សមាគមមួយចំនួន ដូចជា សមាគមសណ្ឋាគារភ្នំពេញ និងសមាគមសិប្បករកម្ពុជាជាដើម ។ ជាងនេះទៅទៀត ការវាយតំលៃពីតំរូវការ និងការបណ្តុះបណ្តាលបុគ្គលិក ក្នុងជំនាញធនាគារ ត្រូវបានគេធ្វើឡើងសំរាប់សមាគមធនាគារនៅកម្ពុជា ។

កិច្ចខិតខំប្រឹងប្រែងផ្នែកការអប់រំ បានបញ្ចូលនូវការផ្សព្វផ្សាយផលិតផល រយៈពេលកន្លះម៉ោងជារៀងរាល់សប្តាហ៍តាមរយៈកម្មវិធីទូរទស្សន៍ ដែលត្រូវបានគេហៅថា "អាជីវកម្មឈានមុខ" ដែលបង្ហាញពីបទពិសោធន៍របស់សហគ្រិននៃសហគ្រាសធុនតូច និងមធ្យមនានា ដែលទទួលបានជោគជ័យក្នុងអាជីវកម្មរបស់ខ្លួន ។ កម្មវិធីនេះក៏បានផ្តល់ផងដែរនូវគន្លឹះនៃការគ្រប់គ្រងអាជីវកម្ម និងយោបល់ណែនាំដល់សហគ្រិននៃសហគ្រាសធុនតូច និងមធ្យម និងកិច្ចពិភាក្សាអំពីបញ្ហាអាជីវកម្មសំខាន់ៗ ។

កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ ក៏បានផ្តល់នូវកម្មវិធីបណ្តុះបណ្តាលធនាគារផងដែរ ។ ជំនួយពិសេសត្រូវបានគេផ្តល់ឱ្យធនាគាកាណាឌីយ៉ា និងអេស៊ីលីដា ដែលរួមចំណែកផ្តល់កំចីដល់សហគ្រាសធុនតូច និងមធ្យម ។ ការសិក្សាជាច្រើនទៀតត្រូវបានគេធ្វើឡើង ស្តីពីការកំរិតកំណត់កំចីសំរាប់សហគ្រាសធុនតូច និងមធ្យម ។ កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គក៏បានផ្តល់នូវកម្មវិធីផ្សេងៗទៀតផងដែរ ដូចជា ការបណ្តុះបណ្តាលជំនួយបច្ចេកទេស ការពង្រឹងសមត្ថភាពនៃអ្នកខ្ចីប្រាក់ ការវិភាគគោលនយោបាយ និងឧបសគ្គផ្នែកច្បាប់បញ្ញត្តិ និងការធ្វើសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។ កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ ក៏បានគាំទ្រដល់ការងាររបស់អង្គការក្រៅរដ្ឋាភិបាល ចំពោះគំរោងបង្កើតការងារ និងប្រាក់ចំណូល ជាពិសេសអង្គការ Hagar Design and Hagar Soya អង្គការប្រព័ន្ធទិន្នន័យកម្ពុជា និង Joom Noon ។

កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនដែលគួឱ្យកត់សំគាល់មួយទៀត គឺកម្មវិធីការតាំងទីលំនៅថ្មី និងទីតិសម្បទាកម្ពុជា (CARERE/UNDP) ។ គំរោងនេះត្រូវបានគេប្រែក្លាយឱ្យទៅជាអង្គការក្រៅរដ្ឋាភិបាលមួយដែលហៅថា កម្ពុជាអភិវឌ្ឍន៏សហគ្រាស (EDC) ក្នុងឆ្នាំ ១៩៩៩[៥២] ។ ដោយមានការគាំទ្រពីម្ចាស់ជំនួយជាច្រើន ដូចជា ទីភ្នាក់ងារអភិវឌ្ឍន៏អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) មូលនិធិអាស៊ី គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP) របស់អង្គការសហប្រជាជាតិ កម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ (UNDP) និងកម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ គំរោងនេះត្រូវបានគេអនុវត្តក្នុងភាគពាយ័ព្យ និងភាគឦសាន្តនៃប្រទេសកម្ពុជា ដោយផ្តោតជាសំខាន់ទៅលើវិស័យកសិកម្ម ក្នុងបរិបទអភិវឌ្ឍន៏វិស័យឯកជន[៥៣] ។ គំរោងកម្មវិធីកម្ពុជាអភិវឌ្ឍន៏សហគ្រាស ផ្តល់នូវសេវាអភិវឌ្ឍន៏អាជីវកម្មដល់ម៉ាស៊ីនកិនស្រូវ ផលិតកម្ម

[៥២] សូមមើលកម្មភាពគំរោងនៃសហគ្រាសធុញតូច និងមធ្យម របស់កម្ពុជា : http:// www.smecambodia.org .

[៥៣] Acharya, *et al* ឆ្នាំ២០០៣

ឥដ្ឋ និងក្បឿង វិស័យកសិពាណិជ្ជកម្ម និងអគ្គិសនីជនបទ ។ ជាផ្នែកមួយនៃគំរោងនេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ត្រូវបានគេបង្កើតឡើងក្នុងទីក្រុងភ្នំពេញ ដើម្បីផ្តោតទៅលើប្រព័ន្ធគណនេយ្យ រដ្ឋបាល សេវាអភិវឌ្ឍន៍អាជីវកម្ម សេវាហិរញ្ញវត្ថុ និងវិនិយោគ សេវាបច្ចេកវិទ្យាពត៌មាន និងសំភារៈឧបទ្ទេសសំរាប់សន្និសីទ និងវគ្គបណ្តុះបណ្តាល។ ស្ថិតនៅក្រោមគំរោងកម្ពុជាអភិវឌ្ឍន៍សហគ្រាស សមាគមអាជីវកម្មមួយចំនួន ដូចជាសមាគមអ្នកកិនស្រូវកម្ពុជា ត្រូវបានគេបង្កើតឡើង ។

## ៤.៣. មីក្រូហិរញ្ញវត្ថុ និងការសន្សំប្រាក់ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ចលនាសាច់ប្រាក់គឺមានលក្ខណៈពិបាកសំរាប់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម ជាពិសេសនៅពេលការសងប្រាក់ពីអតិថិជនយឺតយ៉ាវមិនទាន់ពេលវេលា ។ មីក្រូហិរញ្ញវត្ថុគឺត្រូវការជាចាំបាច់ មិនគ្រាន់តែសំរាប់ចលនាសាច់ប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីការពង្រីកបន្ថែមផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ របាំង និងឧបសគ្គដ៏ចំបងមួយចំពោះការរីកលូតលាស់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម ក្នុងប្រទេសកម្ពុជា គឺការខ្វះលទ្ធភាពរកបានមូលធនហិរញ្ញវត្ថុ ។ ការសិក្សាមួយដែលធ្វើឡើងដោយកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គបានបង្ហាញថា ស្ថាប័នហិរញ្ញវត្ថុ និងធនាគារ គឺមានការស្ទាក់ស្ទើរក្នុងការផ្តល់ផ្តល់កំចីរយៈពេលវែងដល់សហគ្រាសធុនតូច និងមធ្យម ដោយមានអត្រាការប្រាក់មួយដែលអាចទទួលយកបាន[៥៤] ។ យើងអាចសន្ទត់ថា ស្ថានភាពហិរញ្ញវត្ថុ គឺមានសភាពពុំល្អទេសំរាប់មីក្រូសហគ្រាស និងសហគ្រាសធុនតូច។ ជាលទ្ធផលសហគ្រាសធុនតូចទាំងនេះត្រូវខ្ចីប្រាក់ពីសមាជិកគ្រួសារ ឬពីប្រភពក្រៅផ្លូវការ ដែលជាទូទៅមានអត្រាការប្រាក់ខ្ពស់ ។

ទោះបីជាមានបញ្ហាទាំងនេះក៏ដោយ អង្គការក្រៅរដ្ឋាភិបាល និងសមាជិករបស់សហគមហិរញ្ញវត្ថុអន្តរជាតិមួយចំនួន បានផ្តល់ហិរញ្ញប្បទានជាច្រើនដល់សហគ្រាសធុនតូច និងមធ្យម ។ ធនាគារអេស៊ីលីដា ដែលពីមុនបានចុះបញ្ជីជាអង្គការក្រៅរដ្ឋាភិបាលមួយ ដើម្បីផ្តល់ប្រឹក្សាយោបល់ដល់ស្ត្រីក្រីក្រ និងមានប្រាក់ចំណូលទាប ដែលចង់បណ្តុះគំនិតក្នុងការបង្កើតអាជីវកម្មធុនតូចនោះ បានប្រែក្លាយខ្លួនទៅជាម្ចាស់កំចីឥណទានដ៏ធំមួយក្នុងប្រទេសកម្ពុជាទៅវិញ ដោយមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ ដូចជា SIDA USAID និង KfW ។ ស្ថាប័នហិរញ្ញវត្ថុមួយនេះមានផលប័ត្រកំចីដុលសរុប (gross loan portfolio) ចំនួន ៤៧,៤ លានដុល្លារអាមេរិក និងប្រាក់បញ្ញើចំនួន ១៧,៨ លានដុល្លារអាមេរិក ។ ធនាគារនេះបានផ្តល់កំចីដល់អតិថិជនតូចតាច ហើយមានសាខាចំនួន ១១០ កន្លែងនៅពាសពេញផ្ទៃប្រទេស ។ កម្មវិធីមីក្រូឥណទានដែលគេបានបង្កើតឡើងថ្មីៗនេះ ដែលមាន

[៥៤] IFC និង MPDF : ឆ្នាំ២០០៣ ។

ទឹកប្រាក់ចំនួន ២,៥ លានយូរ៉ូ ទទួលបានពីធនាគារអភិវឌ្ឍន៍ KfW ត្រូវបានគេផ្តល់ឱ្យធនាគារក្នុងស្រុកមួយទៀត គឺធនាគារកាណាឌីយ៉ា ដើម្បីបង្កើនមីក្រូហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម[៥៥] ។ ទោះបីជាមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិក៏ដោយ មីក្រូហិរញ្ញប្បទាន គឺនៅតែមិនត្រូវបានទទួលយកដោយការពេញចិត្តថ្លើមពីសំណាក់ធនាគារកម្ពុជានានានោះទេ ។ ទោះបីជាអត្រាការប្រាក់ ដែលយកដោយស្ថាប័នហិរញ្ញវត្ថុខាងលើ មានចំនួនទាបជាងអ្នកចងការប្រាក់ក្រៅប្រព័ន្ធក្តី អ្នកនយោបាយខ្លះរិះគន់ស្ថាប័នទាំងនេះ ថាយកអត្រាការប្រាក់ខ្ពស់ ដែលអ្នកក្រីក្រមិនមានលទ្ធភាពអាចបង់បាន[៥៦] ។

ក្នុងគំរោងមួយផ្សេងទៀត (ដែលមានការចូលរួមពីរដ្ឋាភិបាលកម្ពុជា) អង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយមនុស្សធម៌ ដែលបានផ្តល់កំចីដ៏ច្រើនដល់ប្រជាជនក្រីក្រសំរាប់ការសង់ទីលំនៅ ការបង្កើនប្រាក់ចំណូល ការធ្វើឱ្យបរិស្ថានមានភាពប្រសើរ ការផលិតម្ហូបអាហារ និងតំរូវការចាំបាច់នានា ។ អង្គការនេះត្រូវបានគេហៅថា "មូលនិធិអភិវឌ្ឍន៍ប្រជាជនក្រីក្រនៅទីក្រុង" ដំណើរការជាមួយនឹងមូលនិធិយ៉ាងច្រើនរហូតដល់ ៣៨៤.000 ដុល្លារអាមេរិក ដែលទឹកប្រាក់នេះទទួលបានពីជំនួយឥតសំណងនិងអ្នកបរិច្ចាកមកពីប្រភពនានា រួមមាន សាលាក្រុង គណៈកម្មាការផ្សារក្រុងភ្នំពេញ លោកនាយករដ្ឋមន្ត្រី និងភ្នាក់ងារមូលនិធិផ្សេងៗទៀត ដូចជា Selavip អង្គការជនគ្មានលំនៅដ្ឋានអន្តរជាតិ (HI) អង្គការ Misereor Rausing សម្ព័ន្ធអាស៊ីដើម្បីសិទ្ធិលំនៅដ្ឋាន (ACHR) ជាដើម។ មូលនិធិនេះបានផ្តល់អត្ថប្រយោជន៍ដល់គ្រួសារចំនួន ២.៨៩២ ក្នុងសហគមន៍អ្នកក្រីក្រនៅទីក្រុង។

ប្រតិបត្តិការមួយក្នុងចំណោមប្រតិបត្តិការអាជីវកម្មធុនតូចនានា ដែលបានផ្តល់មូលនិធិដោយគំរោងនេះ គឺការផលិតត្រីផ្អាប់ដែលខ្មែរហៅថា "ប្រហុក" ។ ក្នុងកំឡុងពេលបីឆ្នាំ គ្រួសារចំនួន ១.០៦៤ ក្នុងសហគមន៍តាមដងទន្លេចំនួន ២៤ កន្លែង បានទទួលកំចីដើម្បីទិញត្រីស្តុកទុក និងសំភារៈចាំបាច់ផ្សេងៗ សំរាប់ចាប់ផ្តើមការផលិតប្រហុក ។ ការផលិតនេះ មានរយៈពេលពី ៦ ទៅដល់ ៨ ខែ ដើម្បីអាចលក់ប្រហុកទាំងនោះនៅលើទីផ្សារបាន ។ ក្នុងអំឡុងពេលប៉ុន្មានខែនេះ គ្រួសារទាំងនោះបង់តែការប្រាក់ទៅឱ្យម្ចាស់កំចីតែប៉ុណ្ណោះ ។ មីក្រូឥណទានសំរាប់អាជីវកម្មប្រភេទនេះត្រូវបានគេកត់ត្រាទុកថាទទួលបានជោគជ័យ ១០០ ភាគរយ ដោយប្រាក់កំចីត្រូវបានគេសងមកវិញទាំងអស់[៥៧] ។ ស្ថាប័នហិរញ្ញវត្ថុទាំងនេះ ទាមទារឱ្យមានការគាំទ្រ និងការជួយឧបត្ថម្ភ[៥៨] ។ កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គបានធ្វើកិច្ចការនេះ ដោយផ្តល់នូវវគ្គសិក្សា និងជំនួយបច្ចេកទេសជាច្រើនដល់ស្ថាប័ន មីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ដូចជា ធនាគារអេស៊ីលីដា និងធនាគារកាណាឌីយ៉ា ។

[៥៥] "ចំពោះអ្នកក្រកម្ពុជា មីក្រូហិរញ្ញវត្ថុ គឺជាពរជ័យមួយ មិនមែនជាបណ្តាសារទេ" ក្នុងសារពត៌មាន The Cambodia Daily ចុះផ្សាយនៅថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០០៥

[៥៦] ព្រឹទ្ធសមាជិកបាននិយាយថា " ការអនុវត្តកម្មវិធីមីក្រូហិរញ្ញវត្ថុ មិនបានជួយដល់អ្នកក្រទេ" ក្នុងសារពត៌មាន The Cambodia Daily ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០២ ។

[៥៧] កូនសៀវភៅពត៌មានរបស់ UPDF ។

[៥៨] ILO ឆ្នាំ ២០០ a

ពេលខ្លះមីក្រូហិរញ្ញវត្ថុត្រូវបានគេរិះគន់ចំពោះការគ្រប់គ្រងមិនល្អ និងអត្រាការប្រាក់ដ៏ខ្ពស់របស់វា ។ គំរោងមីក្រូហិរញ្ញវត្ថុមួយចំនួនមិនទទួលបានជោគជ័យឡើយ ប៉ុន្តែកាន់តែធ្វើឱ្យប្រជាជនក្រីក្រជំពាក់បំណុលកាន់តែច្រើនឡើង ដោយសារតែកង្វះនូវការអនុវត្តន៍ល្អក្នុងការផ្តល់កំចី ការកំណត់អត្តសញ្ញាណអតិថិជនដែលមានសក្តានុពល ពុំមានលក្ខណៈសមស្រប និងបរិយាកាសអាជីវកម្មមិនល្អ[៥៩] ។ ក្នុងប្រទេសកម្ពុជា ប្រព័ន្ធច្បាប់ និងការអនុវត្តច្បាប់ ហាក់បីដូចជាមិនមានប្រសិទ្ធិភាព និងមិនគ្រប់គ្រាន់នៅឡើយទេ ។ ជានិច្ចកាល ដី និងអចលនទ្រព្យ ត្រូវបានគេដាក់ជារបស់បញ្ចាំដើម្បីធានាថា អតិថិជននឹងសងប្រាក់កំចីរបស់គេវិញ ។ ក្នុងន័យនេះ ការធានាដល់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ សំរាប់សហគ្រាសក្រៅប្រព័ន្ធ គឺជាមធ្យោបាយមួយទៀតនៃការបង្កើនឱកាសដល់ពួកគេ ដើម្បីទទួលបានហិរញ្ញវត្ថុ ។

ក្នុងបរិបទដូចគ្នានេះ ប្រព័ន្ធមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជានៅតែប្រឈមមុខនឹងបញ្ហាជាច្រើន ។ ជានិច្ចកាល អចលទ្រព្យរបស់អតិថិជនត្រូវបានគេឱ្យតំលៃទាប ពីព្រោះហានិភ័យក្នុងការផ្តល់ប្រាក់កំចីមានកំរិតខ្ពស់ ដោយសារតែប្រព័ន្ធច្បាប់មិនមានប្រសិទ្ធិភាព ។ ជាលទ្ធផល អតិថិជនអាចទទួលបានឥណទានក្នុងចំនួនកំណត់មួយតែប៉ុណ្ណោះ ។ មូលនិធិធានារ៉ាប់រង ដែលជួយធានាដល់ប្រាក់កំចីនោះ ចាំបាច់ត្រូវបង្កើតឡើង ដើម្បីផ្តល់ឱកាសកាន់តែច្រើនឡើងដល់អតិថិជនមីក្រូហិរញ្ញវត្ថុ ដើម្បីអាចទទួលបាននូវកំចីឱ្យបានច្រើនជាងនេះ ។

## ៤.៤. ការបណ្តុះបណ្តាលដើម្បីភាពបង្កើនផលិតភាព និងឱកាសរកបានការងារធ្វើ

ការបណ្តុះបណ្តាល គឺជាមធ្យោបាយមួយ សំរាប់អ្នកធ្វើការក្រៅប្រព័ន្ធដើម្បីស្វែងរកការងារដ៏សមរម្យនៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។ ចំណេះដឹង និងជំនាញដែលមានកំរិតរបស់អ្នកធ្វើការក្រៅប្រព័ន្ធបានកំណត់ព្រំដែនសំរាប់ពួកគាត់ឱ្យស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ដោយមានជំនាញល្អប្រសើរ អ្នកធ្វើការក្រៅប្រព័ន្ធអាចបង្កើនផលិតភាពដែលធ្វើឱ្យចំណូលមានការកើនឡើង[៦០] ។ វាច្បាស់ណាស់ថា គុណភាព និងបរិមាណនៃការបណ្តុះបណ្តាលសំរាប់អ្នកធ្វើការក្រៅប្រព័ន្ធ មានសារៈសំខាន់ដើម្បីឱ្យអ្នកធ្វើការក្រៅប្រព័ន្ធរៀបចំខ្លួនឱ្យចេញផុតពីល័ក្ខខ័ណ្ឌដែលងាយរងគ្រោះ ។

ការបណ្តុះបណ្តាលនៅក្នុងប្រទេសកម្ពុជា នៅមានកំរិតនៅឡើយ ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីរបស់រដ្ឋ តាមរយៈក្រសួងអប់រំ យុវជន និងកីឡា (MEYS) (ហើយបច្ចុប្បន្ននេះឋិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាល

[៥៩] កិច្ចពិភាក្សាក្នុងសិក្ខាសាលាពិនិត្យសុពលភាពទិន្នន័យស្តីពីការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលរៀបចំដោយអង្គការពលកម្មអន្តរជាតិ និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៥ ដើម្បីពង្រឹងគុណភាពនៃវិវេចនាទិពន្ធនេះ ។

[៦០] ILO ឆ្នាំ ២000 a

វិជ្ជាជីវៈ) រួមជាមួយម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ។ ជាទូទៅ ក្រៅពីការបង្រៀនអក្ខរកម្មជាមូលដ្ឋាន ជំនាញជាមូលដ្ឋានត្រូវបានផ្តល់ឱ្យស្ត្រី រួមមាន ជំនាញកាត់ដេរ អ៊ុតសក់ ប៉ាក់ ត្បាញ និងជំនាញផ្នែកសិប្បកម្មផ្សេងៗទៀត ។ មានជំនាញផ្សេងៗ សំរាប់បុរស មានដូចជា ជំនាញជួសជុលវិទ្យុ និងទូរទស្សន៍ ជួសជុលម៉ូតូ ការចិញ្ចឹមសត្វ ជំនាញផ្នែកមេកានិចធុនតូច ផ្សារដែក អគ្គិសនី និងជំនាញសិប្បកម្ម ។ ប្រអប់លេខ ៤.២ សង្ខេបអំពីសកម្មភាពបណ្តុះបណ្តាលរបស់ក្រសួងអប់រំនៅក្នុងឆ្នាំ ២០០២ និង ២០០៣ :

**ប្រអប់លេខ ៤.២**

**ការបណ្តុះបណ្តាលដែលធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយអង្គការក្រៅរដ្ឋាភិបាល នៅឆ្នាំ ២០០២-២០០៣**

ក្រសួងអប់រំ យុវជន និង កីឡា រួមជាមួយអង្គការក្រៅរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធីបណ្តុះបណ្តាល ដូចជា ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាដើម ។ នៅចន្លោះឆ្នាំ ២០០២ និង ២០០៣ កម្មវិធីបង្កើតប្រាក់ចំណូលមួយត្រូវបានបង្កើតឡើង ដែលរួមមានអនុកម្មវិធីពីរ (ការបណ្តុះបណ្តាលជំនាញ រួមជាមួយនឹងអក្ខរកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈសុទ្ធ) ។ អនុកម្មវិធីទី ១ ដែលផ្តល់ចំពោះមនុស្សចំនួន ៣៩៥ នាក់ (ក្នុងនោះមាន ៣៣១ ជាស្ត្រី) នៅក្នុងខេត្តចំនួន៥ លើជំនាញផ្សេងៗ ដូចជា កាត់ដេរ អ៊ុតសក់ ប៉ាក់ ត្បាញ និងសិប្បកម្ម ត្រូវបានគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជា អង្គការជួយខ្មែរ (Help Khmer) គំរោងអភិវឌ្ឍន៍ជនបទ (RDP) អង្គការថែទាំយុវជនខ្មែរ (CYK) និងអង្គការឃែរ (Care International) ។ ជំនាញផ្សេងៗទៀតដែលបានបង្រៀន មានដូចជា ការជួសជុលវិទ្យុ ទូរទស្សន៍ ការចិញ្ចឹម សត្វ កុំព្យូទ័រ អគ្គិសនី សំណង់ គំនូរ បោះពុម្ព ផ្សារដែក និងមុខរបរតូចៗមួយចំនួនទៀត ។ ជំនាញទាំងនេះបានផ្តល់ដល់មនុស្ស ចំនួន ១.៨៤៦ នាក់ ក្នុងនោះមាន ៩៧០ នាក់ជាស្ត្រី។ នៅថ្នាក់សហគមន៍ ក្រសួងអប់រំ យុវជន និងកីឡា រួមសហការជាមួយអង្គការយូណេស្កូ (UNESCO) និងកម្មវិធីសកម្មភាពអាទិភាព (PAP) បានបើកបង្រៀនចំនួន ៤០ ថ្នាក់ ដែលរួមមាន ៩ មុខវិជ្ជាជីវៈ ដល់មនុស្សគោលដៅចំនួន ៨៣៧ នាក់ (ក្នុងនោះមាន ៦៣៨ នាក់ជាស្ត្រី ) ។

សាលាឯកជននានាបានចូលរួមចំណែកក្នុងការបង្កើតជំនាញវិជ្ជាជីវៈ ដូចជា ភាសា កុំព្យូទ័រ កាត់ដេរ គ្រឿងអេឡិចត្រូនិច ជួសជុលទូរទស្សន៍ វិទ្យុ ។ល។ ជាសរុបមានចំនួន ៥.៣៤៩ នាក់ (ស្ត្រី ៤.៤៧០ នាក់) ត្រូវបានគេបណ្តុះបណ្តាល ។

*ប្រភព : របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់ឆ្នាំ ២០០២-២០០៣*

សាលាបណ្តុះបណ្តាលនានា ដែលគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក៏ត្រូវបានបង្កើតផងដែរ ដើម្បីផ្តល់ជំនាញដល់អ្នកធ្វើការក្រៅប្រព័ន្ធ និងសហគ្រិនក្រៅប្រព័ន្ធ ។ ជាឧទាហរណ៍ សាលាបច្ចេកទេស Don Bosco[៦១] ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩១ បានផ្តល់ការបណ្តុះបណ្តាលជំនាញផ្សេងៗ ខាងផ្នែកអេឡិចត្រូនិច អគ្គិសនី ជួសជុលរថយន្ត លេខាធិការ ចំណីអាហារ កសិកម្ម សំលៀកបំពាក់ និងបោះពុម្ព។ សកម្មភាពទាំងអស់នេះបានអនុវត្តនៅទីក្រុង និងខេត្តមួយចំនួន រួមមាន ទីក្រុងភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តកំពង់ចាម ក្រុងព្រះសីហនុ និងក្រុងកែប ។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានផ្តល់ការបណ្តុះបណ្តាលជំនាញសហគ្រិនភាពក្នុងគោលបំណងជួយអ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីឱ្យទទួលបាននូវផលិតភាពខ្ពស់ជាងមុន ។ គំរោងជាដៃគូដែលមានឈ្មោះថា កិច្ចសហប្រតិបត្តិការផ្នែកសិប្បកម្មកម្ពុជា (CCC)[៦២] ដែលបានទទួលជំនួយហិរញ្ញវត្ថុពីក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច របស់សហព័ន្ធអាឡឺម៉ង់ បានផ្តល់នូវសេវាផ្សេងៗខាងផ្នែកការបណ្តុះបណ្តាលវិជ្ជាជីវៈជាមូលដ្ឋានទៅដល់សមាជិករបស់ខ្លួន ដែលធ្វើការនៅក្នុងការងារសិប្បកម្ម។ គំរោងនេះបានផ្តល់នូវវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងរយៈពេលវែង មេរៀនស្តីពីទីផ្សារ និងគណនេយ្យ និងប្រធានបទដែលទាក់ទងនឹងពាណិជ្ជកម្ម និងសេវាកម្មទីផ្សារ ទៅដល់សមាជិករបស់ខ្លួនដែលភាគច្រើនជាសហគ្រាសលក្ខណៈគ្រួសារ ។ បន្ថែមពីលើនេះទៀត ទស្សនកិច្ចសិក្សាទៅបរទេសត្រូវបានគេផ្តល់ជូនចំពោះសមាជិករបស់ CCC ។

ដូចគ្នានេះដែរ សមាគមសិប្បករកម្ពុជា (AAC) ដែលជាអង្គការតំណាងមួយបានធ្វើសកម្មភាពស្រដៀងគ្នាទៅនឹង CCC ដោយមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខមាលភាពសេដ្ឋកិច្ចសង្គមរបស់សិប្បករពិការ និងអ្នកផ្សេងៗទៀត។ សមាគមសិប្បករកម្ពុជាព្យាយាមពង្រីកសកម្មភាពបង្កើនប្រាក់ចំណូលរបស់សមាជិកខ្លួន បង្កើនគុណភាពផលិតផលរបស់សិប្បករ តាមរយៈការអភិវឌ្ឍផ្នែកវិជ្ជាជីវៈ បង្កើនការលក់និងទីផ្សារនាំចេញ ដឹកនាំការចរចាជាក្រុមដើម្បីកាត់បន្ថយចំណាយផលិតកម្ម និងចំណាយលើការនាំចេញ និងធ្វើជាអ្នកតស៊ូមតិទាំងជាលក្ខណៈជាតិ និងអន្តរជាតិ ជាពិសេសពាក់ព័ន្ធទៅនឹងផលិតកម្ម និងការលក់ផលិតផល ដើម្បីមានលទ្ធភាពទទួលបានសម្ភារៈ វត្ថុធាតុដើម និងទីផ្សារល្អជាងមុន ។ សមាគមសិប្បករកម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០១ ដោយមានការជួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) ដែលគ្រប់គ្រងដោយមូលនិធិស្តារនីតិសម្បទាពិភពលោក (WRF)[៦៣]។ នាពេលថ្មីៗនេះ អង្គការពលកម្មអន្តរជាតិ ក៏បានចូលរួមក្នុងការផ្តល់ហិរញ្ញវត្ថុដល់សមាគមផងដែរ ។ សមាគមសិប្បករកម្ពុជាបានធ្វើការបណ្តុះបណ្តាលជាច្រើនដល់សមាជិករបស់ខ្លួន រហូតមកដល់បច្ចុប្បន្ន AAC

៦១ កិច្ចសម្ភាសន៍ជាមួយលោក ស៊ុយ ឆេង នាយកសាលា Don Bosco,

៦២ ពត៌មានលំអិតអំពីគំរោង សូមមើល http://www.online.com.kh/users/Cambodian-craft/pages/ccc.html ។

៦៣ សៀវភៅផ្សព្វផ្សាយរបស់សមាគមសិប្បករកម្ពុជា (AAC) ។

មានសមាជិកចំនួន ២៥ ក្រុម ឬសហគ្រាស។ សមាគមសិប្បករកម្ពុជាបានបើកវគ្គបណ្តុះបណ្តាលជាច្រើន ដោយផ្តោតសំខាន់ជាពិសេសទៅលើទ្រឹស្តីនៃការប្រើពណ៌ ការបង្កើតម៉ាក់ផលិតកម្ម ការគ្រប់គ្រងការលក់ ការរចនាម៉ូត ការគ្រប់គ្រងការដឹកជញ្ជូន ថ្លៃដើម ការកំណត់តំលៃលក់ ការរកទីផ្សារសំរាប់ផលិតផលសិប្បកម្ម និងអភិបាលកិច្ចល្អផ្នែកជំនួញ ។ សមាគមសិប្បករកម្ពុជាបានធ្វើការកត់សំគាល់ថា បន្ទាប់ពីមានវគ្គបណ្តុះបណ្តាលជាច្រើនមក អង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលធ្វើការផលិតផលិតផលសិប្បកម្មបានដាក់តាំងបង្ហាញនូវផលិតផលរបស់ខ្លួន ដែលធ្វើឱ្យមានការចាប់អារម្មណ៍ច្រើនពីសំណាក់អតិថិជន ។ ជាលទ្ធផល សមាជិកជាច្រើនមានដូចជា អង្គការសន្តិភាពផលិតវត្ថុអនុស្សាវរីយ៍ (Peace Handicrafts and Silks) និងមជ្ឈមណ្ឌលជាតិនៃជនពិការ (NCDP) បានធ្វើឱ្យមានការកើនឡើងនូវប្រាក់ចំណូលគួរឱ្យកត់សំគាល់ រហូតដល់ទៅ ១៥០ ភាគរយ លើសពីឆ្នាំមុន[៦៤] ។

## ៤.៥. ការលើកកំពស់ការការពារខាងសង្គមកិច្ច

### ៤.៥.១. ការពង្រីកការការពារខាងសង្គមកិច្ច ទៅដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ

ដូចដែលបានធ្វើការកត់សំគាល់ពីមុនរួចមកហើយ ច្បាប់ស្តីពីរបបសន្តិសុខសង្គមរបស់ប្រទេសកម្ពុជា ដែលមានចែងយ៉ាងច្បាស់ មិនបញ្ចូលអ្នកធ្វើការក្រៅប្រព័ន្ធ ក្នុងការអនុវត្តនៃច្បាប់នេះទេ ។ ច្បាប់នេះអនុវត្តចំពោះតែបុគ្គលទាំងឡាយណាដែលគ្របដណ្តប់ដោយច្បាប់ការងារតែប៉ុណ្ណោះ ។ ជំហានដំបូងក្នុងការកាត់បន្ថយឱនភាពនៃការការពារខាងសង្គមកិច្ច គួរតែធ្វើការពង្រីកច្បាប់នេះឱ្យគ្របដណ្តប់លើអ្នកធ្វើការក្រៅប្រព័ន្ធ ។ ស្ថានភាពផ្នែកច្បាប់នេះនឹងផ្តល់នូវការទទួលស្គាល់ជាផ្លូវការថា អ្នកធ្វើការក្រៅប្រព័ន្ធមានសិទ្ធិ និងត្រូវតែបានគេប្រព្រឹត្តិចំពោះខ្លួនដោយស្មើភាពគ្នា។

វាពិតជាអាចយល់បានថា បន្ទាប់ពីសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនទសវត្សមក ធនធានមនុស្សរបស់ប្រទេសកម្ពុជាមានចំនួនតិចតួចណាស់ ។ ជំនួយត្រូវការជាចាំបាច់ ដើម្បីពង្រឹងសមត្ថភាព ធនធានមនុស្សរបស់ប្រទេសនេះ ជាពិសេសមន្ត្រីរាជការស៊ីវិលនៃក្រសួងពាក់ព័ន្ធ ដែលមានការទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការរៀបចំនូវការធានារ៉ាប់រងសង្គម។

បើទោះបីជាពុំមានការធានារ៉ាប់រងសង្គមជាផ្លូវការពីសំណាក់រដ្ឋាភិបាលក៏ដោយ ក៏អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានផ្តល់នូវការថែទាំសុខភាពជូនដល់អ្នកធ្វើការក្រៅប្រព័ន្ធ។ កម្មវិធីតាមសហគមន៍គួរឱ្យចាប់អារម្មណ៍មួយ ដែលកំពុងប្រតិបត្តិការនៅក្នុងទីក្រុងភ្នំពេញ បានផ្តល់ការជួយឧបត្ថម្ភដល់ក្រុមអ្នកធាក់ស៊ីក្លូដែលជីវភាព និងប្រាក់ចំណូល

[៦៤] កិច្ចសម្ភាសន៍ជាមួយលោក លន់ យ៉េង អ្នកសម្របសម្រួលនៃសមាគមសិប្បករកម្ពុជា ។

របស់ពួកគាត់មានការធ្លាក់ចុះយ៉ាងឆាប់រហ័ស ចាប់តាំងពីមានការពេញនិយមក្នុងការប្រើប្រាស់ម៉ូតូឌុបជាមធ្យោបាយធ្វើដំណើរកាន់តែច្រើនឡើងមក ។ មជ្ឈមណ្ឌលស៊ីក្លូ[៦៥] មានគំរោងប្រាក់សន្សំមួយ ដែលក្រោមគំរោងនេះ អ្នកធាក់ស៊ីក្លូមានឱកាសក្នុងការសន្សំប្រាក់ចំណូលមួយចំនួន។ លើសពីនេះទៀត អ្នកធាក់ស៊ីក្លូ និងគ្រួសាររបស់ពួកគាត់ ត្រូវទទួលបាននូវការពិនិត្យសុខភាព និងការអប់រំសុខភាពដោយឥតគិតថ្លៃ ដែលផ្តល់ដោយគិលានុបដ្ឋាយិកា ២ រូប នៅឯមជ្ឈមណ្ឌល និងទទួលបាននូវការកាត់សក់ដោយឥតគិតថ្លៃចំនួនពីរដងក្នុងមួយខែ ដែលកាត់ដោយសិស្សដែលកំពុងស្ថិតក្នុងការបណ្តុះបណ្តាល ។ មជ្ឈមណ្ឌលនេះក៏បានផ្តល់ផងដែរនូវការបង្ហាត់បង្រៀនភាសាអង់គ្លេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ តាមរយៈមជ្ឈមណ្ឌលស៊ីក្លូ អ្នកធ្វើការក្រៅប្រព័ន្ធអាចចូលរួមផ្តល់ពតិមាន អាចចរចាជាមួយរដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋអំណាចមូលដ្ឋាន និងអាចចូលរួមក្នុងកម្មវិធីពិសេសៗ ដូចជា "កម្មវិធីស៊ីក្លូគ្មានផ្សែងបារី" ដែលផ្តល់ដល់មជ្ឈមណ្ឌល ដោយអង្គការសុខភាពពិភពលោក ដើម្បីប្រយុទ្ធប្រឆាំងនឹងការជក់បារី ។

មានគំរោងធានារ៉ាប់រងសុខភាពតិចតួចនៅក្នុងប្រទេសកម្ពុជា។ គំរោងសន្តិសុខសង្គមតាមសហគមន៍ដែលមានស្រាប់មួយនៅក្នុងប្រទេសកម្ពុជាត្រូវបានផ្តួចផ្តើមឡើងដោយ "ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា (GRET) " ។ បន្ទាប់ពីទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហាមីក្រូហិរញ្ញវត្ថុនៅក្នុងឆ្នាំ ១៩៩៨ GRET បានសំរេចចិត្តពង្រីកសកម្មភាពរបស់ខ្លួនឱ្យមានការធានារ៉ាប់រងសុខភាពដោយមានគោលបំណងការពារប្រាក់ចំណូលគ្រួសារនៅតាមជនបទ កុំឱ្យមានការចំណាយច្រើនទៅលើការថែទាំសុខភាព ។ គំរោងធានាសុខភាពរបស់ GRET ត្រូវបានធ្វើឡើងនៅក្នុងខេត្តពីរ គឺខេត្តកណ្តាល និងខេត្តតាកែវ ។ គំរោងរបស់ GRET បានបង្ហាញនូវវឌ្ឍនភាពជាច្រើន ក្រោមការជួយឧបត្ថម្ភរបស់សហគមន៍អឺរ៉ុប រដ្ឋាភិបាលប្រទេសបារាំង ធនាគារពិភពលោក និងក្រសួងសុខាភិបាល។ ក្រោមគំរោងរបស់ GRET ភាពជាដៃគូជាមួយនឹងមណ្ឌលសុខភាព និងមន្ទីរពេទ្យស្រុកនៃក្រសួងសុខាភិបាលនៅថ្នាក់ឃុំ និងថ្នាក់ស្រុកត្រូវបានបង្កើតឡើង ហើយប្រព័ន្ធចុះឈ្មោះមួយត្រូវបានបង្កើតឡើងដើម្បីឱ្យជនក្រីក្រនៅតាមជនបទទទួលបានការថែទាំសុខភាពងាយស្រួលជាងមុន។ គំរោងនេះមានប្រព័ន្ធមួយដែលធ្វើការបង់ថ្លៃឱ្យមណ្ឌលសុខភាពតាមចំនួនកំណត់ជាមុន (ឬបង់អាស្រ័យទៅតាមចំនួនមនុស្សដែលជាអ្នកត្រូវទទួលសេវា) ប្រមាណ ៥00 រៀល សំរាប់ការពិនិត្យ ឬព្យាបាល ។ ក្នុងករណីដែលត្រូវការការព្យាបាលជំងឺនៅមន្ទីរពេទ្យខេត្ត សមាជិកធ្វើការចំណាយផ្ទាល់លើការព្យាបាល និងទទួលបានសំណងវិញនៅពេលបន្ទាប់ តាមអត្រាថ្លៃព្យាបាលដែលចេញដោយក្រសួងសុខាភិបាល ។

[៦៥] គំរោងនៃកម្មវិធីនេះសូមមើលតាមរយៈគេហទំព័រ : www.cyclo.org.uk

ការសហការរបស់ GRET ជាមួយនឹងមណ្ឌលសុខភាពដែលពាក់ព័ន្ធ និងការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះសមាជិកបាននាំមកនូវលទ្ធផលជាវិជ្ជមាន ។ កម្មវិធីធានារ៉ាប់រងតូចនេះបានពង្រីកនូវសមាជិកភាពរបស់ខ្លួនដោយជោគជ័យរហូតដល់ចំនួន ១.១៦៦ នាក់ (៤៧៣ នាក់ នៅក្នុងខេត្តកណ្តាល និង ៦៩៣ នាក់ នៅក្នុងខេត្តតាកែវ) ត្រឹមខែមករា ឆ្នាំ ២០០៤ ។ តាមបទពិសោធន៍របស់ GRET បានបង្ហាញថា គ្រួសារនៅតាមជនបទមិនទាន់យល់ដឹងច្បាស់អំពីសេវាធានារ៉ាប់រងនេះនៅឡើយទេ ហើយពតិមានផ្នែកអប់រំត្រូវតែធ្វើការផ្សព្វផ្សាយជាមុន ។ គំរោងនេះប្រើវិធីផ្សព្វផ្សាយ ដូចជា ការអង្កេត និងតាមរយៈភ្នាក់ងារដែលរស់នៅក្នុងតំបន់គោលដៅ ដែលមានតួនាទីត្រូវធ្វើការជូនដំណឹងដល់អ្នកភូមិអំពីការធានារ៉ាប់រងនេះ[៦៦] ។ នរណាដែលមានបំណងចូលរួមនៅក្នុងគំរោងនេះ ចាំបាច់ត្រូវបង់ប្រាក់វិភាគទានប្រចាំឆ្នាំចំនួន ២,៥០ ដុល្លារអាមេរិក ។ ប្រព័ន្ធនេះទទួលតែសមាជិកភាពជាគ្រួសារតែប៉ុណ្ណោះ ។ ជាទូទៅសមាជិកគ្រួសារម្នាក់ចូលរួមវិភាគទានដល់ប្រព័ន្ធនេះចំនួន ១០០០ រៀល ក្នុងមួយខែ ។ បើទោះបីចំនួនវិភាគទាននេះមានចំនួនតិចតួចក៏ដោយ ក៏មានតែគ្រួសារដែលមានកំរិតជីវភាពមធ្យមប៉ុណ្ណោះ ដែលអាចចូលរួមក្នុងគំរោងនេះបាន[៦៧] ។ គំរោងនេះនឹងធ្វើការពង្រីកឱ្យទៅដល់បណ្តាខេត្តដទៃទៀត ដូចជា ខេត្តកំពត និងខេត្តកំពង់ធំ ដែលអង្គការសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ (GTZ) កំពុងធ្វើការពិនិត្យសិក្សា និងពង្រីកទៅតំបន់ប្រជុំជនធំៗ ដទៃទៀតដូចជា ទីក្រុងភ្នំពេញ កំពង់ចាម ក្រុងព្រះសីហនុ និងក្រុងសៀមរាប ដោយមានការគាំទ្រពីក្រសួងការបរទេសបារាំង ។ លើសពីនេះទៀត ក៏មានការពិចារណាអំពីផែនការបង្កើត និងផ្លាស់ប្តូរគំរោងឱ្យទៅជាការស្ថាប័នសន្តិសុខសង្គមមួយ ដែលអាចនៅស្ថិតស្ថេរបានយូរ ។

ទោះបីជាទទួលបានជោគជ័យគួរឱ្យកត់សំគាល់ក៏ដោយ គំរោង GRET នៅតែគ្របដណ្តប់បានតែមួយក្តាប់តូចនៃប្រជាជនក្រីក្រកម្ពុជាតែប៉ុណ្ណោះ ។ គំរោងសន្តិសុខសង្គមដែលមានមូលដ្ឋាននៅតាមសហគមន៍បែបនេះ គួរត្រូវបានទទួលការលើកទឹកចិត្ត និងជំរុញដើម្បីធានាឱ្យបាននូវចីរភាព និងភាពរឹងប៉ឹងរបស់វា ។ ការពង្រីកភូមិសាស្ត្រ និងការបង្កើនសមាជិកភាពនៅក្នុងគំរោងនេះមានសារៈសំខាន់ណាស់ ដើម្បីឈានដល់កំរិតមួយដែលនឹងផ្តល់សារៈប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រ ដែលមិនអាចរ៉ាប់រងការចំណាយលើការព្យាបាលបាន ។ ចំណាយប្រចាំឆ្នាំជាមធ្យមនៃសមាជិកភាព ក្នុងម្នាក់ៗគឺ ២,៥០ ដុល្លារអាមេរិក សំរាប់ការថែទាំសុខភាពទាំងអស់ ប៉ុន្តែការចំណាយប្រចាំឆ្នាំជាមធ្យមសំរាប់អ្នកដែលមិនមែនជាសមាជិកនៃការធានារ៉ាប់រងនោះទេ មានតំលៃលើសពី ២២ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។ នេះបង្ហាញឱ្យឃើញថា ប្រព័ន្ធធានារ៉ាប់រងបែបនេះ គឺពិតជាមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយចំណាយលើការថែទាំសុខភាព ។

៦៦ សេចក្តីសង្ខេបនៃគំរោងធានារ៉ាប់រងសុខភាពរបស់ GRET ។

៦៧ កិច្ចសម្ភាសន៍ជាមួយ Claire-Lise BELLANGER ទីប្រឹក្សាបច្ចេកទេសនៃគំរោងធានារ៉ាប់រងសុខភាពរបស់ GRER ។

### ៤.៥.២. សុវត្ថិភាព និងអនាម័យការងារ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

អ្នកធ្វើការក្រៅប្រព័ន្ធ ដែលមានការអប់រំទាប ជំនាញតិចតួច និងផលិតភាពទាប កំពុងតែប្រឈមនឹងហានិភ័យបញ្ហាសុខភាពជាច្រើន ដែលបណ្តាលមកពីកត្តាពីរ។ ទីមួយ គឺល័ក្ខខ័ណ្ឌនៃជីវភាពរស់នៅដ៏ទន់ខ្សោយរបស់ពួកគាត់ និងកង្វះការទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ដូចជា ទឹកស្អាត និងអនាម័យជាដើម ។ កត្តាមួយទៀតគឺ សុវត្ថិភាពការងារ និងគ្រោះថ្នាក់ផ្នែកសុខភាពនៅកន្លែងការងារ។ មិនត្រឹមតែអ្នកធ្វើការប៉ុណ្ណោះទេ ដែលទទួលផលប៉ះពាល់ដោយសារការកើតមានគ្រោះក៏រិតខ្ពស់ និងដោយសារជំងឺ តែថែមទាំងសមាជិកគ្រួសាររបស់ពួកគាត់ផងដែរ ជាពិសេស អ្នកធ្វើការនៅតាមផ្ទះ។

ការបណ្តុះបណ្តាលមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ នៅកន្លែងការងារ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងធ្វើឱ្យប្រសើរឡើងនូវសុខភាព និងសុវត្ថិភាពរបស់អ្នកធ្វើការក្រៅប្រព័ន្ធ ដែលងាយរងគ្រោះ[៦៨] ។ ក្នុងបញ្ហានេះ ភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗបានដើរតួនាទីយ៉ាងសំខាន់ ទាំងក្នុងការផ្តល់ការបណ្តុះបណ្តាលដល់អ្នកធ្វើការក្រៅប្រព័ន្ធ ដើម្បីធ្វើឱ្យល័ក្ខខ័ណ្ឌការងារបានប្រសើរឡើង ហើយជៀសវាងបានពីគ្រោះថ្នាក់ការងារ និងក្នុងការផ្តល់ជូននូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដល់អ្នកធ្វើការក្រៅប្រព័ន្ធទាំងឡាយ ដែលមិនអាចទទួលបានសេវាសាធារណៈទាំងឡាយពីមុនមក (សូមមើលឧទាហរណ៍ក្នុងប្រអប់លេខ ៤.៣) ។

ជាចុងក្រោយ ការធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធគួរតែជាការងាររបស់ប្រជាពលរដ្ឋកម្ពុជា ហើយមានកិច្ចខិតខំប្រឹងប្រែងដើម្បីផ្សារភ្ជាប់សហគមន៍មូលដ្ឋានទៅនឹងអាជ្ញាធរ និងដើម្បីកាត់ផ្តាច់ពីការពឹងផ្អែកទាំងស្រុងទៅលើគំរោងសហគមន៍ដែលទទួលជំនួយពីអន្តរជាតិ[៦៩] ។ គោលការណ៍នៃការពឹងខ្លួនឯងនេះត្រូវបានដាក់បញ្ចូលក្នុងគំរោងមួយ ដែលបង្កើតដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងមូលនិធិប្រទេសជប៉ុនសំរាប់កាត់បន្ថយភាពក្រីក្រ (JFPR) ដោយរួមសហការជាមួយសាលាក្រុងភ្នំពេញ ដោយមានគំរោងមានគោលបំណងបង្កើនប្រាក់ចំណូលដល់អ្នកក្រីក្រតាមរយៈការកែលំអបរិស្ថានសហគមន៍ និងការគាំទ្រសាលាក្រុងក្នុងកិច្ចខិតខំផ្តល់ឱ្យមាននូវទឹកស្អាត និងប្រព័ន្ធបង្ហូរទឹកស្អុយ ដើម្បីឱ្យមានអនាម័យល្អប្រសើរ ។ នៅខណៈដែលបញ្ចុះបញ្ចូលសហគមន៍ឱ្យជួយបង់ប្រាក់ដល់គំរោង វាជាបញ្ហាប្រឈមដ៏ធំមួយក្នុងរយៈពេលខ្លី វាពិតជាមានសារៈសំខាន់ក្នុងការជំរុញឱ្យសហគមន៍ដែលមានចំណូលទាប ចូលរួមក្នុងកិច្ចខិតខំធ្វើឱ្យស្ថានភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើង ។ ការចូលរួមបែបនេះជំរុញឱ្យមានការសន្ទនាគ្នារវាងតួអង្គទាំងបីគឺ : រដ្ឋអំណាចមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងសមាជិកសហគមន៍មូលដ្ឋាន។ សារៈសំខាន់នៃគំរោងនេះគឺថា វាគឺជា

[៦៨] អង្គការ ILO ឆ្នាំ២០០២ a

[៦៩] កិច្ចសម្ភាសន៍ជាមួយលោក Wan Maung ទីប្រឹក្សានៃគំរោង ADB/JFPR CAM

**ប្រអប់លេខ ៤.៣**

**អង្គការក្រៅរដ្ឋាភិបាល និងការបង្កើនប្រាក់ចំណូលសំរាប់ជនក្រីក្រ តាមរយៈការកែលំអបរិស្ថានសហគមន៍**

អង្គការកែច្នៃ និងអនាម័យសហគមន៍ (CSARO) មានសកម្មភាពធំៗចំនួនបីគឺ : ការរៀបចំសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ ការយល់ដឹងពីអនាម័យបរិស្ថាន និងការអភិវឌ្ឍន៍សំរាប់អ្នករើសសំរាម (WPD) ។ នៅក្នុងកម្មវិធីអភិវឌ្ឍន៍សំរាប់អ្នករើសសំរាម អង្គការ CSARO មានបំណងធ្វើទំនាក់ទំនងឱ្យបានជាប់ជាមួយនឹងអ្នករើសសំរាមនៅក្នុងទីក្រុងភ្នំពេញ ។

ដោយមានគោលបំណងបង្កើតមជ្ឈមណ្ឌលមួយសំរាប់ផ្តល់សេវាថែទាំសុខភាពបឋម ទៅដល់អ្នករើសសំរាម អង្គការ CSARO បានទទួលជោគជ័យក្នុងការបញ្ចុះបញ្ចូលសាលាក្រុងឱ្យអនុញ្ញាតឱ្យអង្គការប្រើប្រាស់ដីមួយភាគតូច ។ នៅឆ្នាំ ១៩៩៩ "មជ្ឈមណ្ឌលអភិវឌ្ឍន៍សំរាប់អ្នករើសសំរាម" ត្រូវបានបើកសម្ពោធជាផ្លូវការ ដើម្បីផ្តល់ការថែទាំសុខភាពបឋមដល់អ្នករើសសំរាម ដូចជា ការងូតទឹកសំអាតខ្លួន ការធ្វើអនាម័យ ការជួយសង្គ្រោះបឋមជាដើម ។ មជ្ឈមណ្ឌលផ្តល់ការអប់រំក្រៅប្រព័ន្ធដល់ក្មេងរើសសំរាម ដែលមានអាយុក្រោម ១៥ ឆ្នាំ ដោយមានការគាំទ្រពីអង្គការហាហ្គា (Hagar) ។

ក្រៅពីការអប់រំជាមូលដ្ឋានដូចជា ការអាន ការសរសេរ គណិតវិទ្យា និងវប្បធម៌កម្ពុជា កុមារមានឱកាសដើម្បីរៀនបន្ថែមទៀតអំពីបញ្ហាសង្គម រួមមាន សុខភាព អនាម័យ សិទ្ធិកុមារ មេរោគអេដស៍ និងជំងឺអេដស៍ ការលេងល្បែងកំសាន្ត និងលេងកីឡា ។ ក្រុមជួយខ្លួនឯង (SHG) ក៏ជាដៃគូរបស់ CSARO ដែរ ។ ក្រុមទាំងពីរនេះបានរៀនសូត្រពីគ្នាទៅវិញទៅមក ហើយក្រុមជួយខ្លួនឯងមានឱកាសបណ្តុះបណ្តាលអំពីសកម្មភាពបង្កើនប្រាក់ចំណូលមួយចំនួន ហើយបង្កើតទៅជាក្រុមសន្សំប្រាក់តូចៗ ។ អង្គការ CSARO បានធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ដូចជាសមាគមគ្រូពេទ្យអាស៊ី (AMDA) អង្គការមិត្តសំឡាញ់ (Friends) អង្គការ ADRA អង្គការ Helen Keller អង្គការ KHANA និងអង្គការផ្សេងទៀត ដើម្បីបន្តសេវាថែទាំសុខភាព ។ សំភារៈចំបាច់មួយចំនួនសំរាប់ការពារការឆ្លងមេរោគ ដូចជាសំលៀកបំពាក់ការពារ ប្រដាប់រុំស្បែកជើង ម៉ាស់ អៀបដៃវែង និងស្រោមដៃ ត្រូវបានផ្តល់ទៅឱ្យអ្នករើសសំរាម ។CSARO ក៏បានជួយបង្កើនប្រាក់ចំណូលសំរាប់អ្នករើសសំរាមផងដែរ តាមរយៈការផ្តល់ឱ្យពួកគេនូវរទេះរុញ ដើម្បីអាចយកគ្រឿងរបស់របរដែលអាចកែច្នៃបាន ទៅលក់នៅកន្លែងដែលទទួលបានតំលៃខ្ពស់ ។ នេះជាឧទាហរណ៍ស្តីពីភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈដែលបង្កើតឱ្យមានមីក្រូសហគ្រាសបែបនេះនៅក្នុងសហគមន៍ ។

*ប្រភព : ព្រឹត្តិប័ត្រប្រចាំឆ្នាំរបស់ CSARO ឆ្នាំ ១៩៩៩-២000*

**ប្រអប់លេខ ៤.៤**

**កម្មវិធីបណ្តុះបណ្តាលដើម្បីឱ្យមានសុវត្ថិភាព សុខភាព និងល័ក្ខខ័ណ្ឌការងារប្រសើរជាងមុន ដែលរៀបចំឡើងដោយអង្គការពលកម្មអន្តរជាតិ និងផ្តល់មូលនិធិដោយ DFID**

កម្មវិធីមួយដែលមានឈ្មោះថា "ការកែលំអការងារដើម្បីសុវត្ថិភាពអ្នកធ្វើការតាមផ្ទះ (WISH)" ដែលបង្កើតឡើងដោយអង្គការពលកម្មអន្តរជាតិ មានគោលបំណងផ្តល់ការបណ្តុះបណ្តាលដើម្បីឱ្យសុខភាព និងល័ក្ខខ័ណ្ឌការងារបានល្អប្រសើរ និងមានសុវត្ថិភាពជាងមុន សំរាប់សហគមន៍អ្នកធ្វើការនៅតាមផ្ទះដែលកំពុងតែកើនឡើងនៅក្នុងប្រទេសកម្ពុជា។ ការចំណាយទៅលើវគ្គនេះ គឺជាផ្នែកមួយនៃគំរោងដែលមានទឹកប្រាក់ចំនួន ១,៩ លានដុល្លារអាមេរិក ដែលផ្តល់មូលនិធិដោយក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID) មានគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រទេសចំនួនបី គឺប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសម៉ុងហ្គោលី។ ជំហានទីមួយនៃវគ្គបណ្តុះបណ្តាលនេះមានក្រុមគោលដៅជាស្ត្រី និងបុរសចំនួន ៣៥ នាក់ ដែលជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល។ បន្ទាប់ពីចប់វគ្គសិក្សានេះ គ្រូបង្គោលទាំងនេះនឹងផ្តល់នូវការបណ្តុះបណ្តាលទៅដល់សមាជិកដទៃទៀត នៃសហគមន៍នៅក្នុងទីក្រុងភ្នំពេញ ដើម្បីឱ្យពួកគាត់អាចទទួលបាននូវសុវត្ថិភាព និងសុខភាពល្អផ្ទាល់របស់ខ្លួន ។

អ្នកចូលរួមមានមន្ត្រីរដ្ឋាភិបាល អ្នកតំណាងមកពីសហជីព និយោជក និងអ្នកធ្វើការតាមផ្ទះ។ វិស័យការងារតាមផ្ទះនៅក្នុងប្រទេសកម្ពុជាភាគច្រើនធ្វើដោយស្ត្រី ។ពួកគាត់មិនទទួលបានការពារពីច្បាប់ការងារឡើយ ។ មុខរបររបស់ពួកគាត់ស្ថិតនៅក្នុងវិស័យផលិតកម្មខ្នាតតូច ដូចជា ការផលិតសំលៀកបំពាក់ ត្បាញ សិប្បកម្ម គ្រឿងអលង្ការ គ្រឿងធ្វើអំពីប្រាក់ជាដើម គឺសំរាប់អ្នកធ្វើការ ឬអ្នកប្រកបរបរតាមផ្ទះជាស្ត្រី ហើយការធ្វើជាជាងឈើ ឬជាសិប្បករសំរាប់អ្នកធ្វើការ ឬប្រកបរបរនៅតាមផ្ទះជាបុរស។ ចំណូលរបស់ពួកគាត់មានចាប់ពី ២៥ ដុល្លារអាមេរិក រហូតដល់ ១០០ ដុល្លារអាមេរិក ។ មានសេចក្តីត្រូវការចំពោះការបណ្តុះបណ្តាលបែបនេះ ដោយសារការសិក្សារបស់អង្គការពលកម្មអន្តរជាតិបង្ហាញថា មានអ្នកធ្វើការតិចតួចប៉ុណ្ណោះដែលដឹងពីគ្រោះថ្នាក់នៅកន្លែងការងាររបស់ខ្លួន ដូចជាការប៉ះពាល់ជាមួយនឹងជាតិគីមី ការប្រើប្រាស់ម៉ាស៊ីនគ្មានសុវត្ថិភាព ពន្លឺមិនគ្រប់គ្រាន់ គ្រោះថ្នាក់ដោយសារអគ្គិសនី និងអគ្គិភ័យ ការធ្វើការច្រើនម៉ោង និងឥរិយាបទបំពេញការងារពិបាកៗ ។ គ្រោះថ្នាក់ទាំងអស់នេះមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកធ្វើការផ្ទាល់ប៉ុណ្ណោះទេ តែថែមទាំងប៉ះពាល់ដល់សុខភាពរបស់កូន និងសមាជិកគ្រួសាររបស់ពួកគាត់ទៀតផង ។ អង្គការពលកម្មអន្តរជាតិបានជួយដល់វគ្គបណ្តុះបណ្តាល ដោយផ្តល់ឱ្យមាននូវអ្នកជំនាញខាងអនាម័យ និងសុវត្ថិភាពការងារ។

*ប្រភព : ការបោះពុម្ពផ្សាយរបស់ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០០៤ ។*

*សំរាប់របាយការណ៍ស្តីពីការបណ្តុះបណ្តាលអាចរកបាននៅអាស័យដ្ឋាន :*

*http://www.ilo.org/public/english/region/asro/bangkok/public/releases/yr2004/pr04_26.htm*

ផ្នែកដែលរួមបញ្ចូលគ្នាមួយរបស់សាលាក្រុង។ ជំហានទីមួយៗនៃដំណើរការធ្វើផែនការដែលមានលក្ខណៈជាការចូលរួមនេះ រាប់បញ្ចូលទាំងការពិភាក្សា ការសម្របសម្រួលការអនុវត្តន៍ ការត្រួតពិនិត្យ និងការធ្វើការសំរេច បានធ្វើឱ្យមានការផ្សារភ្ជាប់គ្នារវាងថ្នាក់គ្រប់គ្រងសាលាក្រុងជាមួយនឹងជំនួយរបស់អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ។ គំរោងនេះបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន[៧០] និងបានធ្វើការជាបន្តបន្ទាប់ដោយខ្លួនឯងជាមួយសហគមន៍ ក្រោមការជួយឧបត្ថម្ភរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិប្រទេសជប៉ុនសំរាប់កាត់បន្ថយភាពក្រីក្រ។

ក្រោមការប្តេជ្ញាចិត្តដើម្បីធ្វើឱ្យល័ក្ខខ័ណ្ឌការងាររបស់អ្នក ធ្វើការក្រៅប្រព័ន្ធនៅក្នុងតំបន់អាស៊ីបូព៌ាមានភាពល្អប្រសើរ អង្គការពលកម្មអន្តរជាតិបានចូលរួមចំណែកក្នុងកម្មវិធីបណ្តុះបណ្តាលដើម្បីកែលំអល័ក្ខខ័ណ្ឌការងារ និងសុខភាពរបស់អ្នកធ្វើការក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជាអោយកាន់តែល្អប្រសើរ ( សូមមើលប្រអប់លេខ ៤.៤) ។

## ៤.៦. ការពង្រឹងនូវសំលេង ឬការបញ្ចេញមតិ របស់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ដូចបានសិក្សានៅក្នុងចំនុច ៤.១.១ ខាងលើ តំលៃនៃសិទ្ធិបង្កើតជាសមាគមដែលធានាដោយរដ្ឋធម្មនុញ្ញ គួរតែផ្តល់ផលប្រយោជន៍ដល់មនុស្សគ្រប់រូប ដោយគ្មានការរើសអើង ។ នៅក្នុងសង្គមប្រជាធិបតេយ្យចាំបាច់ត្រូវបង្កើត និងអនុវត្តនូវនីតិរដ្ឋហើយសិទ្ធិឱ្យមានភាពតំណាងចាំបាច់ត្រូវចាត់ចូលជាធរមាន។

នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ អ្នកធ្វើការជួបប្រទះនូវរបាំងឧបសគ្គផ្សេងៗក្នុងការមាននូវភាពតំណាង។ សិទ្ធិរបស់ពួកគាត់ត្រូវបានគេរំលោភ និងមិនត្រូវគោរពតាមដោយនិយោជករបស់ពួកគាត់ឡើយ។ ប្រតិបត្តិករមួយចំនួនប្រឈមមុខនឹងបញ្ហា និងឧបសគ្គផ្សេងៗក្នុងអាជីវកម្មរបស់ខ្លួន ។ ភាគីទាំងសងខាងចាំបាច់ត្រូវរួបរួមគ្នាដើម្បីផលប្រយោជន៍ទៅវិញទៅមក។ ជាឧទាហរណ៍ ការចរចាធ្វើអនុសញ្ញារួម មានប្រយោជន៍សំរាប់ទាំងនិយោជិត និងនិយោជក ។ សំលេងសាមគ្គីរួមគ្នារបស់ពួកគាត់ ក៏នឹងធ្វើឱ្យពួកគាត់ទាំងអស់គ្នាចូលរួមទៅជាវេទិកាមួយ ដែលអាចឱ្យពួកគាត់ដាក់ឥទ្ធិពលទៅលើរដ្ឋបាលសាធារណៈ និងលើកឡើងអំពីបណ្តឹងសារទុក្ខរវាងនិយោជក និងអ្នកធ្វើការក្រៅប្រព័ន្ធ ។ គំរូនៃអន្តរាគមន៍ទាំងនេះនឹងត្រូវធ្វើការពិភាក្សានៅក្នុងផ្នែកខាងក្រោម។ ទោះជាយ៉ាងណាក្តី រដ្ឋាភិបាលបានដើរតួយ៉ាងសំខាន់បំផុតនៅក្នុងការជួយលើកកំពស់សំលេងតំណាងរបស់អ្នកធ្វើការ ។ ការជំរុញឱ្យមានសំលេងតំណាងនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយការគាំទ្ររបស់រដ្ឋាភិបាលពិតជាមានភាពសំខាន់ ក្នុងការលើកកំពស់សំលេងតំណាងនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ផ្នែក

[៧០] សេចក្តីព្រាងនៃគំរោងរបស់ ADB/JFPR ។

បន្ទាប់នេះនឹងពិភាក្សាអំពីតួនាទីរបស់រដ្ឋាភិបាល សង្គមស៊ីវិល និយោជិត និងនិយោជក ដែលពាក់ព័ន្ធទៅនឹងការលើកកំពស់សំលេងតំណាង។

### ៤.៦.១. តួនាទីរបស់រដ្ឋាភិបាលថ្នាក់ជាតិ និង រដ្ឋអំណាចមូលដ្ឋាន

អ្នកតាក់តែងគោលនយោបាយរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋអំណាចមូលដ្ឋាន ត្រូវតែបង្កើតបរិយាកាសមួយ ដែលនៅក្នុងនោះសិទ្ធិបង្កើតជាអង្គការវិជ្ជាជីវៈ និងសិទ្ធិមានតំណាងនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានការពារ និងគោរព។ វាមានសារៈសំខាន់ណាស់ដែលមានច្បាប់ និងគោលនយោបាយ ដែលជំរុញឱ្យមានការចូលរួមយ៉ាងសកម្មរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅក្នុងការសន្ទនាសង្គម ជាមួយសមភាគីរបស់ខ្លួន ពោលគឺរដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋអំណាចមូលដ្ឋាន និយោជក កម្មករនិយោជិតក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ សហជីព និងសមាគម។

រដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋអំណាចមូលដ្ឋានគួរតែធានាឱ្យប្រាកដថា សេដ្ឋកិច្ចក្រៅប្រព័ន្ធមានសំលេងមួយនៅក្នុងការពិគ្រោះយោបល់ត្រីភាគី ជួយសំរួលដល់ការបង្កើតអង្គការវិជ្ជាជីវៈ និងភាពតំណាង តាមរយៈការបន្ធូរបន្ថយបទប្បញ្ញត្តិ និងបន្ថយការចំណាយផ្នែករដ្ឋបាល ចំពោះការចុះបញ្ជីសមាគម និងផ្តល់ឱ្យមានយន្តការសំរាប់ការមានតំណាង និងការពិគ្រោះយោបល់លើគោលនយោបាយដើម្បីធ្វើជាបណ្តាញសំរាប់ជួបប្រជុំដើម្បីទទួលបាន "សំលេង" នៃអ្នកតំណាង។

នៅក្នុងប្រទេសកម្ពុជា ការប្រើប្រាស់សេរីភាពក្នុងការជួបប្រជុំ និងការបង្កើតជាសមាគមដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ជាញឹកញាប់ត្រូវបានបកស្រាយដោយរដ្ឋអំណាចសាធារណៈ ថាជាសកម្មភាពប្រឆាំងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ និងផលប្រយោជន៍ជាតិ ។ ការដាក់កំរិតចំពោះសិទ្ធិក្នុងការរៀបចំជាអង្គការវិជ្ជាជីវៈ រាប់បញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិផង គឺជាបញ្ហាដែលមានយូរមកហើយ[៧១] ។ ការសំរេចចិត្តមួយចំនួនដែលធ្វើដោយរដ្ឋបាលសាធារណៈ ដែលធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ អាចជាការមិនសមហេតុសមផល ប្រសិនបើការសំរេចចិត្តនោះត្រូវធ្វើឡើងដោយមិនបានស្តាប់សំលេងរួមរបស់អ្នកដែលចូលរួមនៅក្នុងវិស័យក្រៅប្រព័ន្ធ ។ ដូច្នេះល័ក្ខខ័ណ្ឌចាំបាច់ជាមុនក្នុងការធ្វើឱ្យមានការពិគ្រោះយោបល់ និងការចូលរួមពិតៗគឺជាប្រការសំខាន់ចាំបាច់។

បើទោះបីជាការសន្ទនាសង្គមជាទៀងទាត់រវាងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងអាជ្ញាធរសាធារណៈមុនពេលធ្វើការសំរេចចិត្ត គឺមកទល់នឹងពេលឥឡូវនេះពុំមែនជាក្រិត្យក្រមដែលត្រូវធ្វើតាមក៏ដោយ ក៏ជួនកាលសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធបានចូលរួមម្តងម្កាលនៅក្នុងការធ្វើផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលមួយចំនួនដែរ។ ជាឧទាហរណ៍នៅក្នុងឆ្នាំ

[៧១] ស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCR) ឆ្នាំ ២០០១

១៩៩៨ សិក្ខាសាលាស្តីពីផែនការជាយុទ្ធសាស្ត្រ ត្រូវបានរៀបចំឡើងដោយសហគមន៍ជនក្រីក្រនៅទីក្រុងភ្នំពេញ និងគំរោងអភិវឌ្ឍន៍ទីក្រុង ដែលមានការចូលរួមពីអ្នកដែលពាក់ព័ន្ធជាច្រើន រួមមាន ជនក្រីក្រដែលរស់នៅក្នុងទីក្រុងផងដែរ ។ ក្រោមប្រធានបទ "ហេតុអ្វីបានជាយើងក្រ និងថាតើយើងអាចចេញផុតពីភាពក្រីក្រដោយរបៀបណា" សិក្ខាសាលាបានសំរេចនូវលទ្ធផល ដោយកំណត់ចេញនូវមូលហេតុជាមូលដ្ឋាននៃភាពក្រីក្រមួយចំនួន ដូចជា កង្វះលទ្ធភាពទទួលបាននូវសេវាជាមូលដ្ឋាន (ជម្រក សេវាផ្គត់ផ្គង់នានា អនាម័យ សេវាថែទាំសុខភាព ការអប់រំ) និងល័ក្ខខ័ណ្ឌសេដ្ឋកិច្ចមួយចំនួន (ចំណូលទាប កង្វះការងារ កង្វះការអប់រំ និងការបណ្តុះបណ្តាល និងកង្វះលទ្ធភាពទទួលបានឥណទាន) ។ សិក្ខាសាលាក៏បានពិនត្យឡើងវិញផងដែរអំពីដំណោះស្រាយទៅលើការកាត់បន្ថយភាពក្រីក្រ ដូចជា : ការបង្កើនលទ្ធភាពក្នុងការទទួលបានសេវាជាមូលដ្ឋាន ការបង្កើនប្រាក់ចំណូល និងការបង្កើនអភិបាលកិច្ចតាមមូលដ្ឋាន[៧២] ។

សេវាឧបត្ថម្ភ និងកម្មវិធីជាច្រើនដែលបានផ្តល់មូលនិធិដោយអ្នកផ្តល់ជំនួយផ្សេងៗ បានធ្វើឱ្យមានកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរសាធារណៈ ចំពោះជនក្រីក្រនៅតាមទីក្រុង ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ឧទាហរណ៍ចំនួនពីរគឺ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅទីក្រុង សំរាប់សាលាក្រុងភ្នំពេញ។ ការងារនេះប្រហែលជាមិនត្រូវបានគេបង្កើតឡើងជាពិសេសដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចក្រៅប្រព័ន្ធនោះទេ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រនេះបានផ្តល់ផលប្រយោជន៍ដល់អ្នកធ្វើការក្រៅប្រព័ន្ធ។ ឧទាហរណ៍ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅទីក្រុងបានផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈមួយចំនួន ដើម្បីឱ្យជនក្រីក្រអាចស្វែងរកការងារនៅក្នុងសហគ្រាសធុនតូច និងមធ្យម ឬអាចចាប់ផ្តើមបើកអាជីវកម្មដោយខ្លួនឯងផ្ទាល់ និងជួយសហគ្រាសធុនតូច ក្នុងការដោះស្រាយបញ្ហា ដូចជា ស្វែងរកទីកន្លែងសំរាប់ធ្វើអាជីវកម្ម[៧៣] ។

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល មានសារៈសំខាន់ក្នុងការផ្តល់នូវបរិយាកាសមួយដែលធ្វើឱ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចប្រើប្រាស់នូវសិទ្ធិក្នុងការបង្កើតជាអង្គការវិជ្ជាជីវៈ ជួនកាលបានទទួលជោគជ័យក្នុងបញ្ហានេះដោយមានអ្នកតំណាងនិយាយបញ្ចេញមតិ ហើយអាជ្ញាធរសាធារណៈជាអ្នកឆ្លើយតប។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២00៤ ក្រសួងអប់រំ យុវជន និងកីឡា បានដកការប៉ុនប៉ងរបស់ខ្លួន ក្នុងការបណ្តេញសហគមន៍ដែលមានចំនួន ១.៧៧៦ គ្រួសារ កំពុងរស់នៅក្នុងអាគារបូរីកីឡាដែលជាកម្មសិទ្ធិរបស់រដ្ឋ ដែលជាផ្នែកមួយនៃមណ្ឌលអាគារកីឡា ។ ប្រឈមមុខនឹងការតវ៉ាប្រឆាំងយ៉ាងខ្លាំងក្លាពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅទីនោះ ក្រសួងបានធ្វើការផ្តល់ជូនជាពិសេសសំរាប់ពួកគាត់នូវចំណែកដីចំនួន

[៧២] សាលាក្រុងភ្នំពេញ ឆ្នាំ ១៩៩៩

[៧៣] គណៈកម្មការសំរបសំរួលអភិវឌ្ឍន៍ទីក្រុង (USG)

៤,៦ ហិកតា ដែលមានចំនួនប្រហែលជា ៣១,៥ ភាគរយ នៃមណ្ឌលអាគារទាំងមូល។ ចំណែកមួយនៃដំណោះស្រាយនេះគឺក្រុមហ៊ុនឯកជនមួយដែលត្រូវបានអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍន៍លំនៅដ្ឋានត្រូវតំរូវឱ្យធ្វើការសាងសង់អាគារមួយសំរាប់គ្រួសារទាំងនោះ[៧៤] ។

វដ្ឋអំណាចមូលដ្ឋានត្រូវតែផ្តល់ឱកាសសំរាប់អ្នកធ្វើការក្រៅប្រព័ន្ធ ដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្តីសំរេចទាំងឡាយណាដែលអាចប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់។ ឧទាហរណ៍មួយគឺគោលនយោបាយសាធារណៈ ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ផ្លូវដើរ និងទីកន្លែងសាធារណៈផ្សេងទៀត។ អ្នកធ្វើការក្រៅប្រព័ន្ធជាច្រើនបានបង្កើតរបររកស៊ីរបស់ខ្លួននៅលើដងផ្លូវ និងពឹងផ្អែកលើការប្រើប្រាស់ទីកន្លែងទាំងនេះ សំរាប់ប្រកបរបររកស៊ីរបស់ពួកគាត់។

លទ្ធភាពក្នុងការផ្តល់អភិបាលកិច្ចបែបនេះ ដែលឆ្លើយតបទៅតាមតំរូវការនៃអ្នកធ្វើការក្រៅប្រព័ន្ធគឺពឹងផ្អែកលើសមត្ថភាពរបស់រដ្ឋាភិបាល។ ប្រសិនបើរដ្ឋបាលសាធារណៈនៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់នោះ ការផ្តល់សេវារបស់ខ្លួននឹងមិនបំរើផលប្រយោជន៍ប្រសើរបំផុតរបស់ប្រជាពលរដ្ឋនោះឡើយ។ កម្មវិធីសិលាដែលមានន័យថា ("ថ្ម") របស់រដ្ឋាភិបាល បានចាប់ផ្តើមឡើងជាច្រើនឆ្នាំមកហើយ ដែលមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ជាច្រើន ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងតាមមូលដ្ឋានគឺជាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។ នៅត្រឹមដំណាច់ឆ្នាំ ២០០០ កម្មវិធីសិលាត្រូវបានអនុវត្តនៅក្នុងឃុំ-សង្កាត់ចំនួន ២២០ នៅក្នុងខេត្ត ក្រុងចំនួន ៦ គឺ : ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ សៀមរាប ឧត្តមានជ័យ រតនគីរី និងក្រុងប៉ៃលិន ។ នាពេលថ្មីៗនេះ កម្មវិធីសិលាបានពង្រីកកម្មវិធីរបស់ខ្លួនទៅដល់ខេត្តមួយចំនួនទៀត ។ កម្មវិធីសិលា ដែលទទួលបានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ពីសហគមន៍ផ្តល់ជំនួយមួយចំនួន និងរដ្ឋាភិបាល គឺជាគំរូមួយដែលត្រូវគេប្រើដើម្បីសាកល្បងសិក្សា និងធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រដើម្បីពង្រឹងសមត្ថភាព និងគណនេយ្យភាពនៃស្ថាប័នតាមឃុំ សង្កាត់ និងតាមខេត្តក្រុង។ កម្មវិធីនេះបានជួយរដ្ឋាភិបាល ក្នុងការកសាងសមត្ថភាពរបស់រដ្ឋអំណាចមូលដ្ឋាន និងជួយដោះស្រាយនូវបញ្ហាកង្វះលទ្ធភាពរបស់រដ្ឋអំណាចមូលដ្ឋានក្នុងការផ្តល់សេវានានា ដោយសារតែកង្វះមូលនិធិ[៧៥] ។

## ៤.៦.២. តួនាទីរបស់សង្គមស៊ីវិល

អង្គការក្រៅរដ្ឋាភិបាលក៏បានដើរតួនាទីផងដែរ នៅក្នុងការជំរុញសង្គមស៊ីវិល ដោយផ្តល់នូវការតស៊ូមតិសំរាប់ជនក្រីក្រ ជាមួយនឹងអាជ្ញាធរសាធារណៈ។ ឧទាហរណ៍ដែលទទួលបានជោគជ័យមួយនៃគំរោងរួមគ្នាមួយរវាងមូលនិធិអភិវឌ្ឍន៍ជនក្រីក្រនៅទីក្រុង (UPDF) និងសាមគ្គីភាពសំរាប់សហព័ន្ធជនក្រីក្រនៅតាមទីក្រុង (SUPF) គឺជាសក្ខីភាពដ៏មានតំលៃ ។ សិទ្ធិរបស់អ្នកធ្វើការក្រៅប្រព័ន្ធដែលរស់នៅក្នុងតំបន់ក្រីក្រ

៧៤ របាយការណ៍របស់ UPDF ខែឧសភា ឆ្នាំ២០០៤ ។

៧៥ ឯកសារកម្មវិធីសិលា ឆ្នាំ ២០០១-២០០៥

ដើម្បីទទួលបាននូវការកាន់កាប់ដីធ្លីនៅក្នុងតំបន់នេះ មិនត្រូវបានការពារតាមផ្លូវច្បាប់ឡើយ ហើយការកាន់កាប់ដីរបស់ពួកគាត់ ជាញឹកញាប់ត្រូវបានរំខានដោយរដ្ឋអំណាចមូលដ្ឋាន។ មានប្រជាពលរដ្ឋរាប់ពាន់គ្រួសារត្រូវបានបណ្តេញចេញ និងបានតាំងទីលំនៅថ្មីនៅក្រៅទីក្រុងភ្នំពេញជាទីដែលបរិយាកាសសេដ្ឋកិច្ចសង្គម និងគ្រឿងសំរួលជីវភាពរស់នៅចាំបាច់មិនទាន់ត្រូវបានគេរៀបចំដើម្បីបំពេញតាមតំរូវការរបស់ពួកគាត់ឡើយ ។ UPDF និង SUPF បានជួយប្រជាពលរដ្ឋរាប់ពាន់នាក់ ដើម្បីរក្សាទីលំនៅរបស់ពួកគាត់ឱ្យនៅដដែលដោយជោគជ័យ ។ នៅឯពិធីប្រារព្ធខួបលើកទី៥ របស់ UPDF ដៃគូរួមគ្នារវាងអង្គការទាំងពីរនេះបានបរិយាយអំពីលទ្ធផលនៃការងារដ៏លំបាករបស់ខ្លួន ដែលបានផ្តល់នូវផលប្រយោជន៏ដល់សមាជិកសហគមន៏ជនក្រីក្រចំនួន ៥000 ពាសពេញទីក្រុង។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានទទួលស្វាគមន៏ដោយសាធារណៈជន ដែលនៅក្នុងការឆ្លើយតបទៅនឹងការអំពាវនាវរបស់ប្រជាពលរដ្ឋ សុំឱ្យមានការជួយឧបត្ថម្ភរបស់រដ្ឋាភិបាលលើគំរោងផែនការអភិវឌ្ឍន៏របស់ខ្លួននោះ នាយករដ្ឋមន្ត្រីបានយល់ព្រមផ្តល់នូវសិទ្ធិរស់នៅលើដីដដែល និងការឧបត្ថម្ភសំរាប់ជួយអភិវឌ្ឍន៏សហគមន៏ជនក្រីក្រនៅទីក្រុងចំនួន ១00 នៅក្នុងឆ្នាំនីមួយៗ[៧៦] ។

សិទ្ធិរបស់អ្នកធ្វើការ ឬប្រតិបត្តិករក្រៅប្រព័ន្ធ ក្នុងការរៀបចំបង្កើតជាអង្គការវិជ្ជាជីវៈត្រូវបានរៀបចំឡើងប្រកបដោយជោគជ័យ ដោយអង្គការក្រៅរដ្ឋាភិបាលឈ្មោះថា គណៈកម្មការសំរបសំរួលអភិវឌ្ឍន៏ទីក្រុង (USG) ដែលបានជួយក្រុមអាជីវករលក់ដូរនៅក្នុងទីផ្សារចំនួនពីរនៅក្នុងក្រុងទីភ្នំពេញឱ្យពួកគាត់រៀបចំជាសមាគម ។ ជាងនេះទៅទៀត USG បានផ្តល់នូវការបណ្តុះបណ្តាលជំនាញផ្នែកចរចា និងតស៊ូមតិដែលជួយសមាជិក ក្នុងការតបតនឹងការយាយីរំខានពីអាជ្ញាធរផ្សារ[៧៧] ។

ការតស៊ូមតិសំរាប់ជនក្រីក្របំផុត គឺជាបេសកម្មរបស់កិច្ចសហប្រតិបត្តិការអន្តរជាតិសំរាប់ការអភិវឌ្ឍន៏ និងសាមគ្គីភាពនៅកម្ពុជា (CIDSE) ដែលបានរួមសហការនិងគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាលជាច្រើន នៅតាមបណ្តាខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជា។ CIDSE កម្ពុជា បានបង្កើតកម្មវិធីប្រើប្រាស់ដីព្រៃឈើសហគមន៏មួយសំរាប់ប្រជាពលរដ្ឋទីទ័លក្រដែលរស់នៅក្នុងខេត្តរតនគីរី ភាគឦសាននៃប្រទេសកម្ពុជា។ កម្មវិធីនេះសំខាន់ណាស់ក្នុងការធានានូវការទទួលបានដី និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាព[៧៨] ។ ការចាប់កាន់កាប់ដីធ្លី គឺជាបញ្ហារុញច្រានដែលស្ថិតនៅពីក្រោយគំរោងនេះ។ មានសេចក្តីរាយការណ៏ថា មានការកើតឡើងនូវការចាប់កាន់កាប់ដីធ្លីដោយជនដែលមានទ្រព្យសម្បត្តិច្រើនដែលដឹងជាមុនអំពីគំរោងស្ថាបនាផ្លូវក្នុងតំបន់ ដែលនឹងធ្វើឱ្យតំលៃដីកើនឡើង និងដោយជនឆឱកាសដែលស្វែងរកទិញដី (អ្នកគួកដេដី)។ CIDSE កម្ពុជា គាំទ្រនិងធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋក្នុងការអនុវត្តន៏ការវាយ

[៧៦] ពតិមានសហគមន៏ (Community News) ឆ្នាំ ២00៣ ។

[៧៧] Kusakabe, *et al* 2001

[៧៨] របាយការណ៏ប្រចាំ ឆ្នាំ ២00៣ របស់ CIDSE កម្ពុជា

តំលៃលើការគ្រប់គ្រងការប្រើប្រាស់ដីធ្លី ការរៀបចំផែនទីសំរាប់ការប្រើប្រាស់ដី និងការធ្វើសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីការប្រើប្រាស់ដី ។ លទ្ធផលចុងក្រោយ គឺជាលក្ខន្តិកៈប្រើប្រាស់ដីសំរាប់ភូមិ ដែលត្រូវបានសំរេចយល់ព្រមដោយអភិបាលខេត្ត និងមន្ទីរដែលពាក់ព័ន្ធទាំងឡាយ ។

ការតស៊ូមតិស្រដៀងគ្នានេះដែរបានផ្តល់ឱ្យប្រជាពលរដ្ឋនៅក្នុងឃុំផ្តៅជុំ ខេត្តកំពង់ចាម ។ ក្នុងករណីនេះ ដីដែលប្រជាពលរដ្ឋប្រើសំរាប់ការបូមទឹកស្រោចស្រប់ស្រូវក្នុងរដូវប្រាំងត្រូវគេគ្រោងលក់ទៅឱ្យអ្នកមកពីខាងក្រៅ ។ CIDSE កម្ពុជា ដោយមានជំនួយរបស់បណ្តាញតស៊ូមតិខេត្ត និងស្តារកម្ពុជា (Star Kampuchea ជាអង្គការក្រៅរដ្ឋាភិបាល) បានជួយសហគមន៍ដើម្បីរួមគ្នានាំយកបញ្ហានេះទៅដល់ក្រុមប្រឹក្សាឃុំ ។ របាយការណ៍ឆ្នាំ ២០០៣ របស់ CIDSE កម្ពុជា ថាការចរចារវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំបានកំពុងតែបន្តធ្វើនៅឡើយ ប៉ុន្តែសមាជិករបស់ឃុំ នៅតែឃ្លាំមើលដោយប្រុងប្រយ័ត្នអំពីស្ថានភាពដី និងធានាថា គ្មានការហូរច្រោះដី ។

ក្រៅពីប្រភេទនៃការតស៊ូមតិទាំងនេះ CIDSE កម្ពុជា ក៏បានធ្វើការដើម្បីកសាងសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ។ នៅក្នុងឆ្នាំ ២០០៣ សិក្ខាសាលាមួយស្តីអំពីការតស៊ូមតិត្រូវបានធ្វើឡើង ដោយមានការចូលរួមពីសំណាក់អ្នកជំនាញផ្សេងៗ ពីដៃគូអង្គការក្រៅរដ្ឋាភិបាល ដោយផ្តោតជាសំខាន់ទៅលើបញ្ហាជាច្រើនដូចជាការនេសាទ ព្រៃឈើ សិទ្ធិកាន់កាប់ដីធ្លី និងការចងបណ្តាញ ។ សមាជិកអង្គការក្រៅរដ្ឋាភិបាល មកពីអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ត្រូវបានអញ្ជើញឱ្យចូលរួមធ្វើទស្សនៈកិច្ចនិងរៀនសូត្រពីគំរោង CIDSE នៅក្នុងបណ្តាខេត្តនានា ។

CIDSE កម្ពុជា ក៏បានស្វែងរកមធ្យោបាយដើម្បីជំរុញទំនាក់ទំនងជាសហប្រតិបត្តិការរវាងរដ្ឋអំណាចមូលដ្ឋាន និងអ្នកតំណាងសង្គមស៊ីវិល ពោលគឺ អង្គការក្រៅរដ្ឋាភិបាល ។ CIDSE បានជួយឧបត្ថម្ភដល់អ្នកតំណាងចំនួន ៣ រូប ដែលមកពីក្រុមប្រឹក្សាឃុំជ្រោយស្តៅក្នុងខេត្តបាត់ដំបង និងអ្នកតំណាង ៣ រូបទៀត មកពីអង្គការក្រៅរដ្ឋាភិបាលមួយដែលធ្វើការនៅក្នុងឃុំនោះ គឺសមាគមអភិវឌ្ឍន៍ជនបទ (RDA) ដើម្បីឱ្យចូលរួមក្នុងសិក្ខាសាលាមួយដែលមានឈ្មោះថា " សិក្ខាសាលាស្តីអំពីវិមជ្ឈការ : ទស្សនៈវិស័យចំពោះភាពជាដៃគូ" ។ ដោយធ្វើការពិភាក្សារួមគ្នា ក្រុមប្រឹក្សាឃុំ និងអង្គការក្រៅរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាពជាដៃគូ ដែលពាក់ព័ន្ធទៅនឹងការការពារធនធានមច្ឆជាតិ ។ បន្ទាប់ពីសិក្ខាសាលារួចមកទាំង RDA និងក្រុមប្រឹក្សាឃុំបានធ្វើការរៀបចំកិច្ចប្រជុំជាមួយអ្នកភូមិ និងមន្ត្រីគ្រប់គ្រងនេសាទដើម្បីធ្វើការតស៊ូមតិប្រឆាំងទៅនឹងសកម្មភាពនេសាទខុសច្បាប់ ។ ក្រុមមន្ត្រីបានធ្វើការប្តេជ្ញាចិត្ត ដើម្បីកាត់បន្ថយការសូកប៉ាន់ និងធ្វើការរឹបអូសយកឧបករណ៍នេសាទខុសច្បាប់ ហើយចំពោះអ្នកភូមិខ្លះបានសន្យាឈប់បន្តសកម្មភាព

នៃសាទខុសច្បាប់តទៅទៀត។ ចាប់ពីមានបទពិសោធន៍នោះមក CIDSE កម្ពុជា បានអញ្ជើញដៃគូអង្គការក្រៅរដ្ឋាភិបាលចំនួន ១៥ ឱ្យចូលរួមក្នុងសិក្ខាសាលាមួយផ្សេងទៀត។ សិក្ខាសាលានេះរៀបចំឡើង ដើម្បីជួយបង្កើតនូវផែនការសកម្មភាពសំរាប់ធ្វើការជាមួយក្រុមប្រឹក្សាឃុំរៀងៗខ្លួន ។ ដៃគូអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានបញ្ចប់ផែនការជាមួយក្រុមប្រឹក្សាឃុំរបស់ខ្លួន និងមួយចំនួនទៀតនៅកំពុងបន្តធ្វើបង្ហើយ ។

### ៤.៦.៣. តួនាទីរបស់អង្គការកម្មករនិយោជិត និងសមាគមតាមសហគមន៍

យោងទៅតាមអង្គការពលកម្មអន្តរជាតិ គេសង្កេតឃើញថាកម្ពុជាមានការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សិទ្ធិសេរីភាព ក្នុងការបង្កើតជាសមាគម បើទោះបីជាមានការរើសអើងប្រឆាំងទៅនឹងសហជីព និងការរំលោភលើសេរីភាពនេះក៏ដោយ ។ ចំនួនសហជីពបានកើនឡើងយ៉ាងខ្លាំង នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយសមត្ថភាពរបស់កម្មករនិយោជិត ក្នុងការចរចាជាមួយនិយោជកក៏មានការរីកចំរើនដែរ។ សហជីពមួយចំនួនមិនត្រឹមតែបើកចំហចំពោះកម្មករនិយោជិតក្នុងប្រព័ន្ធប៉ុណ្ណោះទេ តែថែមទាំងបានពង្រីកសមាជិកភាពរបស់ខ្លួនឱ្យទៅដល់អ្នកធ្វើការក្រៅប្រព័ន្ធផងដែរ ។សហភាពសហព័ន្ធសហជីពជាតិកម្ពុជា (CCTU)[៧៩] ដែលជាសហភាពមួយក្នុងចំណោមសហភាពសហព័ន្ធសហជីពដែលបានចុះបញ្ជីជាមួយក្រសួងការងារបានចូលរួមពង្រីកសមាជិកភាពរបស់ខ្លួន ឱ្យដល់អ្នកធ្វើការក្រៅប្រព័ន្ធដែលរួមមានទាំងអ្នកប្រកបការងារដោយខ្លួនឯង និងកម្មករដែលធ្វើការយកប្រាក់ខែ។ សហជីពមានការបែងចែកជាផ្នែកៗដោយយោងទៅតាមមុខរបរផ្សេងៗគ្នា។ មុខរបរជាច្រើនប្រភេទដែលមានតំណាងសហជីពកំពុងតែមានការកើនឡើង ។ មានអាជីវករចំនួនជាង ១០០ នាក់ នៅក្នុងផ្សារចំនួនពីរ (ផ្សារអូរឡាំពិក និងផ្សារអូរឫស្សី) នៅក្នុងទីក្រុងភ្នំពេញ និងអ្នកបើករថយន្តតាក់ស៊ី ជាង ២០ នាក់ បានក្លាយជាសមាជិកនៃសហជីព។ ចំនួនអ្នកធ្វើការក្រៅប្រព័ន្ធមកពីសហគ្រាសឡឥដ្ឋ សហគ្រាសសំណង់ និងសហគ្រាសផលិតអំបិលបានកើនឡើងគួរឱ្យកត់សំគាល់។ មានសមាជិករហូតដល់ទៅ ២០៥ នាក់ មកពីសហគ្រាស សំណង់ និង ៥០០ នាក់ មកពីសហគ្រាសផលិតអំបិល។ តំលៃចូលជាសមាជិកគឺ ១០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយខែ។

បើទោះបីជាមានការកើនឡើងនូវសមាជិកភាពសហជីព ក៏អ្នកធ្វើការក្រៅប្រព័ន្ធភាគច្រើនមិនចាប់អារម្មណ៍ចូលជាសហជីពឡើយ ដោយសារតែពួកគាត់មិនបានយល់ច្បាស់អំពីសិទ្ធិ និងអត្ថប្រយោជន៍ដែលពួកគាត់ទទួលបានពីការចូលជាសមាជិកនៅក្នុងសហជីព។

[៧៩] កិច្ចសម្ភាសន៍ជាមួយលោក សយ សំអុន ជាសមាជិកក្រុមប្រឹក្សានៃ CCTU ។

ដូច្នេះការផ្សព្វផ្សាយពតិមានទៅដល់អ្នកធ្វើការក្រៅប្រព័ន្ធ ស្តីអំពីសហជីពគឺមានសារៈសំខាន់។ ការឱ្យពួកគាត់យល់ដឹងអំពីកិច្ចខិតខំប្រឹងប្រែង ដែលទទួលបានជោគជ័យក្នុងការការពារផលប្រយោជន៍របស់ខ្លួន និងការផ្តល់ជូននូវអត្ថប្រយោជន៍ពិត១ ដូចជាការបណ្តុះបណ្តាលជំនាញជាដើម នឹងក្លាយជាឧបករណ៍ដ៏មានប្រយោជន៍ក្នុងការជួយអ្នកធ្វើការក្រៅប្រព័ន្ធឱ្យយល់ដឹងពីអត្ថប្រយោជន៍ពិត១ ដែលពួកគាត់អាចទទួលបានពីសមាជិកភាពសហជីព។ ជាឧទាហរណ៍ សមាជិករបស់ CCTU ត្រូវបានផ្តល់នូវការបណ្តុះបណ្តាលស្តីពីច្បាប់ការងារ ពលកម្មលើកុមារ សុខភាព និងសុវត្ថិភាពការងារ រួមទាំងមេរោគអេដស៍ និងជំងឺអេដស៍ (HIV/AIDS) និងត្រូវបានផ្តល់នូវការតស៊ូមតិ និងការការពារនៅពេលកើតមានបញ្ហា ដោយអាស្រ័យទៅតាមច្បាប់ការងារ។

តួនាទីរបស់សហជីព មិនក៏រិតត្រឹមតែការផ្តល់នូវការបណ្តុះបណ្តាល និងការការពារផ្នែកច្បាប់ចំពោះអ្នកធ្វើការក្រៅប្រព័ន្ធនោះទេ។ សហជីពនៅក្នុងប្រទេសជាច្រើនបានជួយអ្នកធ្វើការក្រៅប្រព័ន្ធ ក្នុងការចរចាអំពីអនុសញ្ញារួម និងការបង្កើតសហជីពផ្ទាល់របស់អ្នកធ្វើការក្រៅប្រព័ន្ធ។ ជួនកាល អ្នកធ្វើការក្រៅប្រព័ន្ធអាចប្រមូលគ្នាចងក្រងជាសមាគមជាជាងសហជីព ដោយសារសមាគមក៏ដើរតួនាទីដូចគ្នាដែរ គឺធ្វើជាអ្នកការពារផលប្រយោជន៍របស់សមាជិករបស់ខ្លួន។ ទោះជាអង្គភាពមួយត្រូវបានគេហៅថាសហជីព ឬជាសមាគមក្តី មិនសំខាន់ដូចនឹងការធានាថា អង្គភាពនោះជាសំលេងដែលមានប្រសិទ្ធិភាពសំរាប់សមាជិកក្នុងមូលដ្ឋានរបស់ខ្លួននោះទេ។ ប្រអប់លេខ ៤.៥ បង្ហាញពីសមាគមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការការពារអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ប្រអប់លេខ ៤.៥

## សមាគមកម្ពុជាអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ

សមាគមមួយ ដែលមានឈ្មោះថា សមាគមកម្ពុជាអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ (CAID) ដែលកាលពីមុនគេស្គាល់ថាជា សមាគមការពារពលកម្ម និងការដឹកជញ្ជូនទំនិញ នៅក្នុងប្រទេសកម្ពុជា (GTL-PAC) ទទួលយកអ្នកធ្វើការក្រៅប្រព័ន្ធជាច្រើនផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។ សមាគមនេះបើកចំហទទួលយកសមាជិកភាពក្នុងមុខរបរជាច្រើននៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជា អ្នករត់ម៉ូតូឌុប អ្នករត់ម៉ូតូកង់បី អ្នកលក់ដូរតាមដងផ្លូវ អ្នកលក់ក្នុងផ្សារ អ្នកនេសាទ និងកសិករ។ សមាជិកភាពទាំងមូលដែលមានចំនួនប្រហែលជា ៣.១០០ នាក់ ម្នាក់ៗត្រូវឱ្យចូលរួមវិភាគទានដល់សមាគមចំនួន ១ ដុល្លារអាមេរិក ក្នុងមួយខែ។ គោលបំណងរបស់សមាគមគឺជួយផ្តល់គុណភាពនៃជីវិតឱ្យបានប្រសើរជាងមុន ការប្រកួតប្រជែងផ្នែកពាណិជ្ជកម្មដល់សមាជិករបស់ខ្លួនដែលកំពុងធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការអភិវឌ្ឍន៍សេវាអាជីវកម្ម ការបែងចែកសេវាកម្ម ការបង្កើតការងារដើម្បីបង្កើនចំណូល ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដើម្បីទទួលបាននូវផលិតកម្មដែលមានលក្ខណៈស្តង់ដារ ដើម្បីអាចឈានចូលទៅក្នុងទីផ្សារ ព្រមទាំងការតស៊ូមតិ និងសេវាការពារផ្នែកច្បាប់ (មាត្រាទី៨ នៃលក្ខន្តិកៈរបស់សមាគម CAID)។

ប៉ុន្មានឆ្នាំកន្លងមកនេះ GTL-PAC បានសំរេចនូវគោលដៅរបស់ខ្លួន ពាក់ព័ន្ធនឹងការជួយសមាជិករបស់ខ្លួនជាច្រើន នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលទទួលរងគ្រោះពីការរំលោភសិទ្ធិ។ ឧទាហរណ៍មួយចំនួនដែលទទួលបានជោគជ័យរបស់សមាគម មានដូចជា :

- នៅក្នុងឆ្នាំ ២០០១ GTL-PAC បានដឹកនាំក្រុមមួយដែលមានអ្នកបើកបររថយន្តធុនធំ និងរថយន្តតាក់ស៊ី ចំនួនប្រហែល ២០០ នាក់ ដើម្បីតវ៉ាប្រឆាំងនឹងការយកថ្លៃផ្លូវខ្ពស់ ដែលធ្វើដោយក្រុមហ៊ុនឯកជន វើង ស្រេង ។ GTL-PAC ទទួលជោគជ័យនៅក្នុងការបញ្ចុះបញ្ចូលឱ្យក្រុមហ៊ុនកាត់បន្ថយតំលៃឈ្នួលផ្លូវ បន្ទាប់ពីការពិភាក្សាជាមួយថ្នាក់គ្រប់គ្រងរបស់ក្រុមហ៊ុន។
- សន្តិសុខផ្សារម្នាក់ដែលធ្វើការឱ្យអាជ្ញាធរសាធារណៈ បានវាយអាជីវករលក់ដូរតាមផ្លូវម្នាក់ នៅពេលដែលធ្វើការដេញអាជីវករតាមដងផ្លូវចេញពីដងផ្លូវ។ GTL-PAC បានជួយសមាជិករបស់ខ្លួន ដែលរងរបួសក្នុងការស្វែងរកសំណង ។ ការធ្វើអន្តរាគមន៍ទទួលបានជោគជ័យនៅពេលដែលសន្តិសុខរូបនោះបានយល់ព្រមសងជំងឺចិត្តចំនួន ២០០ ដុល្លារអាមេរិក។
- ម៉ូតូតាក់ស៊ីកង់បី ត្រូវបានរារាំងដោយសាលាក្រុងមិនឱ្យចូលក្នុងទីក្រុង។ បន្ទាប់ពីអ្នកបើកបរយានយន្តកង់បី ចំនួន ១២០ នាក់ បានសុំឱ្យធ្វើអន្តរាគមន៍ GTL-PAC បានធ្វើការចរចាជាមួយសាលាក្រុង និងបានធ្វើឱ្យសាលាក្រុងផ្លាស់ប្តូរការសំរេចរបស់ខ្លួន។
- នៅក្នុងជំលោះដីធ្លីលើផ្ទៃដី ៩៥.៦៤៨ ហិកតា រវាងកសិកររាប់ពាន់គ្រួសារ ជាមួយនឹងក្រុមហ៊ុន Kim Svill Corp. Co.,Ltd ប្រជាពលរដ្ឋចំនួន ១.៣៨៧ គ្រួសារបានជ្រើសរើស GTL-PAC ឱ្យធ្វើជាអ្នក

តំណាងរបស់ខ្លួន។ អន្តរាគមន៍របស់ GTL-PAC បាននាំទៅដល់ការដោះលែងអ្នកជាប់ឃុំឃាំងចំនួន ៦ នាក់ ដែលជាប់ពាក់ព័ន្ធទៅនឹងជំលោះដីធ្លីនេះ និងបាននាំទៅដល់ការប្រគល់ដីទៅឱ្យគ្រួសារទាំងនោះវិញ។ កសិករទាំងនោះបានចូលរួមជាសមាជិករបស់ GTL-PAC ។

- សាលាក្រុងបានធ្វើការហាមឃាត់ម៉ូតូឌុប មិនឱ្យដឹកអ្នកដំណើរនៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញឡើយ ។ GTL-PAC បានធ្វើការចរចាជាមួយសាលាក្រុង បន្ទាប់ពីមានការស្នើសុំដោយក្រុមអ្នករត់ម៉ូតូឌុបចំនួន ៣១ រូប ហើយក្រោយមកសាលាក្រុងបានផ្លាស់ប្តូរការសំរេចរបស់ខ្លួន។

*ប្រភព : លក្ខន្តិកៈ និងរបាយការណ៍របស់សមាគមន៍ CAID ឆ្នាំ ២០០១-២០០២*

អង្គការតាមសហគមន៍មួយចំនួន (CBOs) ដែលកំពុងតែធ្វើការងារនៅថ្នាក់មូលដ្ឋាន បានចូលរួមយ៉ាងខ្លាំងក្លាក្នុងការធ្វើឱ្យសំលេងរបស់អ្នកធ្វើការក្រៅប្រព័ន្ធត្រូវបានគេដឹងឮ។ ប៉ាដិក (Padek-សហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា) ដែលបានចុះបញ្ជីជាអង្គការក្រៅរដ្ឋាភិបាល និងបានបើកដំណើរការជិតពីរទសវត្សមកហើយ។ ដោយមានគោលបំណងកាត់បន្ថយភាពក្រីក្រ ប៉ាដិកបានធ្វើការដោះស្រាយបញ្ហាជាច្រើនទាក់ទងទៅនឹងការកសាងអង្គការ សន្តិសុខស្បៀង ការអប់រំ វប្បធម៌ និងសុខភាព ហើយបានធ្វើប្រតិបត្តិការនៅក្នុងខេត្ត ក្រុងចំនួន ៥ គឺ : ខេត្តស្វាយរៀង ព្រៃវែង កំពង់ស្ពឺ សៀមរាប និងទីក្រុងភ្នំពេញ[៨០] ។ គំរូអភិវឌ្ឍន៍សហគមន៍ចំរុះរបស់ប៉ាដិកបានគូសវាសចេញគំរូ និងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍សហគមន៍នៅក្នុងប្រទេសកម្ពុជា។ គំរូអភិវឌ្ឍន៍ដែលត្រូវការពេលវេលាប្រហែលជា ៥ ឆ្នាំ ដើម្បីសំរេចបាននោះ ទាក់ទងនឹង ៤ ដំណាក់កាល។ ដំណាក់កាលទី ១ ប៉ាដិក ធ្វើការវាយតំលៃ ដូចជា ទ្រព្យរបស់សហគមន៍ ការរៀបចំផែនទីស្តីពីស្ថានភាពសេដ្ឋកិច្ចសង្គម ។ល។ បន្ទាប់មកបង្ហាញគំរូនោះដល់សហគមន៍ ហើយក្រោយមកទៀតបង្កើតក្រុមជួយខ្លួនឯង (SHGs) នៅក្នុងសហគមន៍។ បន្ទាប់ពីនោះមក ប៉ាដិកចាប់ផ្តើមដំណើរការបោះឆ្នោតឃុំក្រៅផ្លូវការ ដើម្បីជ្រើសរើសអ្នកសម្របសម្រួលដែលនឹងជួយត្រួតពិនិត្យការសម្របសម្រួល និងការអនុវត្តន៍គំរោង ដែលអ្នកសម្របសម្រួលទាំងនេះគឺជាគណៈកម្មការអភិវឌ្ឍន៍ឃុំ-សង្កាត់ (CDC) និងគណៈកម្មការអភិវឌ្ឍន៍ភូមិ (VDC)។ បន្ទាប់មក ប៉ាដិកបានធ្វើការបង្ហាញនូវជំនាញការមូលដ្ឋានដែលនឹងក្លាយជាអ្នកផ្តល់ប្រឹក្សាចំពោះ CDC និង VDC ទៅលើបញ្ហា ដូចជា ការចិញ្ចឹមសត្វ ជាដើម។ ក្នុងដំណាក់កាលទីបី ប៉ាដិកជួយសហគមន៍ដើម្បីបង្កើតអង្គការ សហគមន៍ឃុំមួយ (CCBO) ដែលក្នុងនោះអ្នកជំនាញ និងអ្នកសម្របសម្រួលធ្វើការជួយសហគមន៍ ក្នុងការផ្តល់ការបណ្តុះបណ្តាលដល់ក្រុមជួយខ្លួនឯង។ ប៉ាដិក បានជួយផ្តល់ទាំងផ្នែកធនធានមនុស្ស

[៨០] ពត៌មានបន្ថែមអំពី Padek សូមមើលតាមវិបសាយ http://www.padek.org .

និងផ្នែកហិរញ្ញវត្ថុដល់សហគមន៍ នៅពេលដែលឈានមកដល់ដំណាក់កាលទីបីនេះ។ ទោះជាដូច្នេះក្តី ប៉ាដិកដកខ្លួនចេញបន្តិចម្តងៗ នៅក្នុងដំណាក់កាលទីបួន នៅពេលដែលអង្គការសហគមន៍ឃុំមានសមត្ថភាពគ្រប់គ្រាន់ដើម្បីរស់បានដោយចីរភាព[៨១] ។

ការបង្កើតក្រុមជួយខ្លួនឯង (SHGs) មិនត្រឹមតែជាឧបករណ៍មួយសំរាប់សមាជិករបស់ខ្លួន ដើម្បីជួយគ្នាចូលរួមវិភាគទានក្នុងគំរោងប្រាក់សន្សំប៉ុណ្ណោះទេ តែថែមទាំងជួយឱ្យមានការយល់ដឹង និងរួមចំណែកចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកផងដែរ។ កម្មវិធីមួយក្នុងចំណោមកម្មវិធីគំរូអភិវឌ្ឍន៍ចំរុះ (PICDM) គឺជាការជួបជុំជាទូទៅដែលតួអង្គអភិវឌ្ឍន៍ទាំងអស់ រួមមានសមាជិកនៃក្រុមជួយខ្លួនឯង អ្នកភូមិ និងរដ្ឋាភិបាលធ្វើការជួបជុំគ្នាដើម្បីពិភាក្សា។ ភូមិ និងឃុំ ដែលធ្វើការអនុវត្តន៍ PICDM នោះ ត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្ន។ Padek ធ្វើការស្វែងរកឃុំដែលក្រីក្របំផុតសំរាប់គំរូអភិវឌ្ឍន៍ចំរុះរបស់ខ្លួន ។ ជាសរុប ប៉ាដិកធ្វើការជាមួយជាង ៣២.០០០គ្រួសារ នៅក្នុងឃុំជនបទ និងសង្កាត់នៅតាមទីក្រុងចំនួន ២២។ កិច្ចខិតខំរបស់ Padek បានអនុញ្ញាតឱ្យសហគមន៍ក្រីក្រប្រមូលផ្តុំគ្នា និងបង្ហាញពីក្តីកង្វល់ និងបំណងរបស់ខ្លួនទៅដល់អ្នកចូលរួមសំខាន់ៗផ្សេងៗ ដូចជាមេដឹកនាំសហគមន៍ អាជ្ញាធរថ្នាក់ស្រុក និងថ្នាក់ខេត្ត អង្គការក្រៅរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងសមាជិកនៃអង្គការសង្គមស៊ីវិល។ ការតស៊ូមតិទល់មុខគ្នានេះ កន្លងមកបានទទួលនូវលទ្ធផលល្អណាស់ ជាពិសេស ការជួបជុំនៅឃុំជាឃ្លាំង និងឃុំស្វាយចេក។ ការជួបជុំគ្នានៅក្នុងឃុំជាឃ្លាំង បានពាំនាំការព្រួយបារម្ភរបស់សមាជិកសហគមន៍ឱ្យលោកទេសរដ្ឋមន្ត្រីក្នុងក្រុមប្រឹក្សារដ្ឋមន្ត្រីបានដឹង តាមរយៈលោករដ្ឋលេខាធិការ ដែលបានចូលរួមនៅក្នុងការប្រជុំនោះ។ បន្ទាប់មក អ្នកតំណាងរបស់សហគមន៍បានទទួលសំបុត្រពីទេសរដ្ឋមន្ត្រី ដែលបានបញ្ជូនទៅឱ្យក្រសួងមួយចំនួនភ្ជាប់ជាមួយនឹងឯកសារមួយដែលសរសេរដោយសមាជិកសហគមន៍ និងបានសំដែងពីក្តីកង្វល់របស់ខ្លួន។ នៅក្នុងករណីនៃកិច្ចប្រជុំនៅឃុំស្វាយចេក លទ្ធផលទទួលបានគឺ ការប្រគល់មកវិញនូវដីចំការចំនួន ៩០០ ហិកតា ដែលកាន់កាប់ខុសច្បាប់ដោយកងយោធា ឱ្យទៅអ្នកភូមិវិញ។ កងយោធាបានត្រួតត្រាដីចំការរបស់អ្នកភូមិ ហើយមេភូមិហាក់បីដូចជាមិនអាចជួយបាននៅក្នុងការដោះស្រាយករណីនេះ។ របៀបវារៈនៃកិច្ចប្រជុំដែលយកបញ្ហាជំលោះដីធ្លីមកធ្វើជាបញ្ហាសំខាន់នោះ ត្រូវបានបញ្ជូនឱ្យទៅដល់មន្ត្រីដែលពាក់ព័ន្ធទាំងអស់ (អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល អាជ្ញាធររដ្ឋាភិបាល) មុនកាលបរិច្ឆេទនៃកិច្ចប្រជុំ។ បន្ទាប់ពីទទួលបាននូវរបៀបវារៈនោះមក អភិបាលស្រុកបានឆ្លើយតបយ៉ាងរហ័ស និងបាននិយាយជាមួយនឹងមេដឹកនាំកងយោធា ហើយបានធ្វើការដោះស្រាយចំពោះការផ្តល់ដីជូនប្រជាពលរដ្ឋវិញ មួយថ្ងៃមុនកិច្ចប្រជុំ[៨២] ។

[៨១] កិច្ចសម្ភាសន៍ជាមួយអ្នកស្រី ឡេង សិរីវុទ្ធ ជាមន្ត្រីគាំទ្រកម្មវិធីរបស់អង្គការ Padek ។

[៨២] សេចក្តីសង្ខេបនៃគំរូអភិវឌ្ឍន៍សហគមន៍របស់ Padek (PICDM) ។

### ៤.៦.៤. តួនាទីនៃអង្គការរបស់និយោជក

នៅក្នុងប្រទេសកម្ពុជា មីក្រូសហគ្រាសមានកំរិតចំណូល និងផលិតភាពទាប។ លើសពីនេះទៀត វាហាក់បីដូចជាមានការទាក់ទងគ្នាតិចតួចចំពោះសង្វាក់ផលិតកម្ម រវាងសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ[៨៣]។ បើទោះបីជាមានករណីនេះ ក៏សហគ្រាសក្នុង និងក្រៅប្រព័ន្ធប្រឈមមុខនឹងបញ្ហាស្រដៀងគ្នាមួយចំនួន ដូចជា បទប្បញ្ញត្តិពាណិជ្ជកម្មដ៏លំបាក បែបបទការិយាធិបតេយ្យ ការទទួលមូលធនហិរញ្ញវត្ថុមានកំរិត ហេដ្ឋារចនាសម្ព័ន្ធសង្គមមិនគ្រប់គ្រាន់ ទីផ្សារដែលមានកំហិត និងតំរូវការបង្កើនសមត្ថភាព ។ នៅទីបញ្ចប់ អំណាចនៃសហគ្រាសក្នុងប្រព័ន្ធក្នុងការចរចាតទល់នឹងរដ្ឋបាលសាធារណៈ គឺមិនបានល្អប្រសើរច្រើនជាងសហគ្រាសក្រៅប្រព័ន្ធទេ។

តាមរយៈវេទិកាវិស័យឯកជន មានកិច្ចសន្ទនាផ្ទាល់ដែលធ្វើឡើងពីរដងក្នុងមួយឆ្នាំ រវាងរដ្ឋាភិបាលប្រទេសកម្ពុជា និងវិស័យឯកជន។ វេទិកានេះត្រូវបានរៀបចំឡើងសមទៅនឹងការពិភាក្សាដែលមានប្រយោជន៏ ដែលនៅក្នុងនោះ រាល់បញ្ហាទាំងអស់ដែលប៉ះពាល់ដល់ពាណិជកម្ម និងការវិនិយោគទុន អាចត្រូវបានគេធ្វើការដោះស្រាយ។ វិស័យនិងទិដ្ឋភាពជាច្រើននៃសេដ្ឋកិច្ច និងបញ្ហារដ្ឋបាលត្រូវបានលើកឡើង និងធ្វើការពិភាក្សា។ រវាងកិច្ចពិភាក្សាជាច្រើន វេទិកានេះមានក្រុមការងារជាច្រើន ដែលមានរដ្ឋមន្ត្រី និងអ្នកតំណាងរបស់វិស័យឯកជនធ្វើជាប្រធានអង្គប្រជុំ[៨៤]។ ទោះបីជាកិច្ចពិភាក្សាមិនត្រូវបានផ្តោតសំខាន់ទៅលើមីក្រូសហគ្រាសក៏ដោយ ក៏បញ្ហាទាំងឡាយដែលគេបានពិភាក្សានោះជាប់ទាក់ទងទៅនឹងសហគ្រាសធុនតូច និងមធ្យម (SMEs) ទាំងក្នុង និងក្រៅប្រព័ន្ធ។ ដោយសារសហគ្រាសក្នុង និងក្រៅប្រព័ន្ធជួបប្រទះនឹងឧបសគ្គស្រដៀងគ្នា វេទិកាផ្សេងៗ ដូចជា វេទិការវិស័យឯកជន អាចពង្រីកការពិភាក្សារបស់ខ្លួនដោយរាប់បញ្ចូលវិស័យក្រៅប្រព័ន្ធ។ បន្ថែមពីនេះទៀត អង្គការរបស់និយោជកអាចពង្រីកសមាជិកភាពរបស់ខ្លួនឱ្យដល់ក្រុមប្រតិបត្តិករក្រៅប្រព័ន្ធ។ សនិទានភាពក្នុងបញ្ហានេះមានលក្ខណៈជាការជំរុញដោយការបន្ថែមសំលេងឱ្យបានច្រើនឡើងៗ អាចផ្តល់ការជំរុញជាចាំបាច់ឱ្យរដ្ឋបាលសាធារណៈជួយកាត់បន្ថយឧបស័គ្គក្នុងការធ្វើពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា និងបង្កើតគោលនយោបាយដែលនាំទៅដល់ផលប្រយោជន៏រួមបន្ថែមទៀតនៃវិស័យក្នុងប្រព័ន្ធ និងវិស័យក្រៅប្រព័ន្ធ។

[៨៣] អង្គការ ILO ឆ្នាំ ២០០០

[៨៤] ធនាគារពិភពលោក ឆ្នាំ ២០០៤

# ៥ សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ដូចប្រទេសជិតខាងខ្លួននៅក្នុងតំបន់អាស៊ីដែរ សេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជាតំណាងឱ្យការរួមចំណែកមួយភាគធំនៅក្នុងសកម្មភាពសេដ្ឋកិច្ចទាំងមូល ។ តាមទស្សនៈវិស័យរបស់មនុស្ស ចំនួនអ្នកធ្វើការក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជាមានចំនួនច្រើនឆ្ងាយជាងចំនួនអ្នកធ្វើការនៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។ អ្នកធ្វើការក្រៅប្រព័ន្ធគ្មានទាំងការការពារខាងផ្លូវច្បាប់ និងការពារខាងសង្គមកិច្ច ។ ពួកគាត់ទទួលរងហានិភ័យបន្ថែមទៀត និងពុំចាំបាច់សោះ ចំពោះសុខភាព និងសុវត្ថិភាព ពីព្រោះជំនាញការងារ និងឱកាសការងាររបស់ពួកគាត់មានកំរិត គ្មានជម្រើស ហើយត្រូវតែធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ការងារ និងប្រាក់ចំណូលរបស់ពួកគាត់មិនអាចធានាបានទេ ហើយមានចំនួនតិចតួច ។ ក្រៅពីចំណែកមួយនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលគ្មានសិទ្ធិ និងការការពារអ្វីទាំងអស់នោះ ពួកគាត់ជាទូទៅ ក៏ខ្វះនូវភាពតំណាងផងដែរ (ដូចជាសហជីព) ដើម្បីនាំយកបញ្ហាទាំងឡាយរបស់ពួកគាត់ ឱ្យទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកតាក់តែងគោលនយោបាយ និងភាគីពាក់ព័ន្ធទាំងអស់ ។ ជំនាញ និងផលិតភាពទាបរបស់ពួកគាត់ បង្កើតបាននូវចំណូលទាប ។ ករណីទាំងអស់នេះបង្កើតបានជារង្វង់មួយដែលក្រៅពីរង្វង់នេះ ពួកគាត់មិនទំនងជាអាចធ្វើទៅបានឡើយ ។

នៅលើក្រដាស់ កម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់ខ្លួន ក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាសំខាន់ៗភាគច្រើនរបស់អង្គការពលកម្មអន្តរជាតិ ។ នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញានេះ ដោយគាំទ្របទដ្ឋានស្នូលអន្តរជាតិស្តីពីការងារ ក៏ដូចជាច្បាប់ការងារផ្ទាល់របស់ខ្លួន ។ ដូចដែលបានលើកឡើងនៅក្នុងផ្នែកទី ៤ ការផ្តើមគំនិតជាច្រើនត្រូវបានធ្វើឡើងដោយរដ្ឋាភិបាល និងដៃគូសង្គមផ្សេងៗទៀត ។ ប៉ុន្តែនៅមានសេចក្តីត្រូវការជាចាំបាច់ច្រើនទៀតដែលត្រូវធ្វើ ដើម្បីជួយសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ កម្មវិធី និងគោលនយោបាយជាច្រើនត្រូវការជាចាំបាច់ ដើម្បីដាក់បញ្ចូលអ្នកធ្វើការក្រៅប្រព័ន្ធ នៅក្រោមការការពារសិទ្ធិសំរាប់អ្នកធ្វើការ ដែលមានចែងនៅក្នុងអនុសញ្ញាជាមូលដ្ឋានរបស់កម្ពុជា និងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ។ វាមានតំលៃខ្លាំងណាស់ក្នុងការកត់សំគាល់ថា លិខិតូបករណ៍ជាតិ និងអន្តរជាតិទាំងនេះ មិនបានញែកឱ្យ

ដាច់ពីគ្នាឡើយរវាងអ្នកធ្វើការក្នុងប្រព័ន្ធ និងអ្នកធ្វើការក្រៅប្រព័ន្ធ ។ ដូច្នេះនៅក្នុងការធានាសិទ្ធិរបស់អ្នកធ្វើការ ដោយមិនគិតដល់កន្លែងធ្វើការ និងរបៀបដែលពួកគាត់ធ្វើការយ៉ាងដូចម្ដេចនោះទេ និងក្នុងការលើកតំកើងការងារសមរម្យ ដូចដែលបានកំណត់ដោយអង្គការពលកម្មអន្តរជាតិនោះ ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ៖

១. គ្មានស្ថិតិស្ដីអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធនោះទេ ។ ជាពិសេសនៅក្នុងវិស័យផ្សេងៗ ស្ថិតិនៃអ្នកធ្វើការក្រៅប្រព័ន្ធ ជាទូទៅមិនត្រូវបានគេបង្ហាញឡើយ ហើយមានការខិតខំប្រឹងប្រែងតិចតួចក្នុងការសិក្សាស្រាវជ្រាវជាក់លាក់ណាមួយ ។ ក្ដីកង្វល់ និងបញ្ហារបស់អ្នកធ្វើការក្រៅប្រព័ន្ធ មិនត្រូវបានគេយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាឡើយ ។ ដោយសារករណីនេះ បញ្ហាទាំងឡាយដែលប៉ះពាល់ដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងការរួមចំណែកនៃសេដ្ឋកិច្ចនេះ មិនត្រូវបានកត់ត្រាឡើយ ។ ការធ្វើអង្កេត និងការសិក្សាស្រាវជ្រាវបន្ថែមទៀតចាំបាច់ត្រូវធ្វើដើម្បីរកឱ្យឃើញនូវបញ្ហារបស់អ្នកធ្វើការ ហេតុនេះទើបអាចបង្កើតការផ្ដួចផ្ដើមថ្មី និងគោលនយោបាយដើម្បីបំពេញទៅតាមសេចក្ដីត្រូវការរបស់អ្នកធ្វើការ ។

២. ច្បាប់ការងារមិនរាប់បញ្ចូលអ្នកធ្វើការក្រៅប្រព័ន្ធទេ ហើយនេះជាឧបសគ្គមួយដ៏ធំ។ កង្វះការការពារខាងផ្លូវច្បាប់ ធ្វើឱ្យកើនឡើងនូវការរំលោភសិទ្ធិជាមូលដ្ឋាន ។ ការការពារខាងសង្គមកិច្ចមិនត្រូវបានគេផ្ដល់ដល់អ្នកធ្វើការឡើយ ហើយភាពតំណាងជាសមូហភាពក៏គ្មានដែរ។ ដូច្នេះពួកគាត់គ្មានសំលេងដើម្បីតទល់ជាមួយនិយោជក និងជាមួយរដ្ឋាភិបាលទេ។ ចំណែកឯនិយោជកក្រៅប្រព័ន្ធ សហគ្រាសរបស់ពួកគេក៏ត្រូវបានធ្វើឱ្យខូចប្រយោជន៍ផងដែរ ដោយសារបទប្បញ្ញត្តិពាណិជ្ជកម្មមិនបានគ្របដណ្ដប់ទៅលើសហគ្រាសទាំងនេះ។ ភាពក្រៅប្រព័ន្ធបានរារាំងសហគ្រាសទាំងនេះមិនឱ្យទទួលបាននូវធនធានហិរញ្ញវត្ថុ និងឥណទានឡើយ ហើយរារាំងសហគ្រាសទាំងនេះមិនឱ្យធានាបាននូវសិទ្ធិមានកម្មសិទ្ធិ និងការអនុវត្តន៍កិច្ចសន្យារបស់ខ្លួន។ ក្នុងន័យនេះ ការពង្រីកច្បាប់គឺត្រូវការជាចាំបាច់ដើម្បីការពារអ្នកធ្វើការ និងនិយោជកនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ លើសពីនេះទៀត បទប្បញ្ញត្តិពាណិជ្ជកម្ម ជាពិសេសនីតិវិធីនៃការចុះបញ្ជី គួរតែធ្វើការត្រួតពិនិត្យ និងកែសម្រួលឡើងវិញ ដើម្បីកាត់បន្ថយភាពស្មុគស្មាញ និងលើកទឹកចិត្តសហគ្រាសក្រៅប្រព័ន្ធ ឱ្យក្លាយទៅជាចំណែកនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។

៣. កាលានុវត្តភាពនៃពាណិជ្ជកម្មថ្មីក្រោមសាកលភាវូបនីយកម្ម ផ្ដល់ឱកាសមិនត្រឹមតែក្នុងការកាត់បន្ថយភាពក្រីក្រដោយចីរភាពប៉ុណ្ណោះទេ តែថែមទាំងផ្ដល់នូវការងារសមរម្យនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធទៀតផង។ មនុស្សគ្រប់រូបនឹងទទួលបាននូវផលប្រយោជន៍ ជាពិសេសជនក្រីក្រ និងជនដែលងាយទទួលរងគ្រោះ តាមរយៈការបង្កើត

ការងារនៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ ។ ឧទាហរណ៍ ទំនិញដែលផលិតបាននៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានលក់នៅក្នុងទីផ្សារសហរដ្ឋអាមេរិកក្នុងតំលៃ ៦ ឬ៧ ដង នៃតំលៃដើមរបស់វានៅពេលទិញពីអ្នកផលិត ។ ច្បាស់ណាស់ថា សេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានតភ្ជាប់នឹងបណ្តាញនៃការផ្គត់ផ្គង់មួយដែលបង្កើតការងារ និងប្រាក់ចំណូលទៅដល់អ្នកដែលចូលរួម ។

៤. សហគ្រាសក្រៅប្រព័ន្ធប្រឈមមុខនឹងឧបសគ្គទាំងឡាយ ដូចជា បទប្បញ្ញត្តិដ៏ធ្ងន់ធ្ងរ កង្វះពតិមានទីផ្សារ ការយកប្រាក់នៅតាមផ្លូវមានកំរិតខ្ពស់ និងចំណាយខ្ពស់លើអគ្គិសនី ជាដើម។ វាពឹងផ្អែកលើរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តគោលនយោបាយដែលកាត់បន្ថយរបាំងទាំងនេះឱ្យនៅតិចបំផុត និងជួយសហគ្រាសឱ្យមានផលិតភាពប្រសើរឡើង ការបង្កើតការងារ និងការប្រកួតប្រជែងឱ្យកាន់តែមានប្រសិទ្ធិភាព ។

៥. ទោះបីជាមានការបណ្តុះបណ្តាលនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមួយចំនួនក្តី ក៏គ្មានការបណ្តុះបណ្តាលជាពិសេសណាមួយត្រូវបានគេបង្កើតឡើងទេ សំរាប់ជួយអ្នកធ្វើការក្រៅប្រព័ន្ធ អំពីភាពដែលអាចរកការងារធ្វើបាន និងផលិតភាពឡើយ។ ការអប់រំជាមូលដ្ឋាន និងអក្ខរកម្មសំរាប់អ្នកធ្វើការក្រៅប្រព័ន្ធ នឹងជួយលើកកំពស់សំលេងរបស់អ្នកធ្វើការ នៅក្នុងសង្គម។

៦. នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មីក្រូហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការធានា និងពង្រីកមីក្រូសហគ្រាស និងសហគ្រាសធុនតូច (MSEs) ។ ស្ថាប័នដែលពាក់ព័ន្ធនឹងការផ្តល់មីក្រូហិរញ្ញវត្ថុទៅដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ គួរតែត្រូវបានផ្តល់នូវការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីពង្រីកលទ្ធភាពទទួលបាននូវមីក្រូឥណទាន ដែលកំពុងតែផ្តោតការយកចិត្តទុកដាក់ទៅលើតំបន់ក្រីក្រតាមទីក្រុង និងជនបទ ។

៧. ការការពារខាងសង្គមកិច្ច នៅមិនទាន់មាននៅឡើយក្នុងប្រទេសកម្ពុជា សូម្បីតែនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ បើទោះជាច្បាប់ដែលពាក់ព័ន្ធនឹងសន្តិសុខសង្គមសំរាប់អ្នកធ្វើការក្នុងប្រព័ន្ធ ត្រូវបានបង្កើតនាពេលថ្មីៗនេះក៏ដោយ ។ ក្នុងការសហការជាមួយអ្នកផ្តល់ជំនួយ និងដៃគូសង្គមផ្សេងៗ ប្រទេសកម្ពុជាគប្បីអនុវត្តមេរៀនដែលបានរៀនសូត្រកន្លងមក រួមជាមួយនឹងការអនុវត្តន៍ដែលទទួលបានជោគជ័យល្អបំផុតនៅក្នុងបណ្តាប្រទេសផ្សេងៗ ដែលបានធ្វើឱ្យមានការរីកចំរើននូវផែនការធានារ៉ាប់រងសង្គមនៅពេលជាមួយគ្នានេះដែរ ច្បាប់គួរតែត្រូវធ្វើការពង្រីកឱ្យគ្របដណ្តប់លើអ្នកធ្វើការក្រៅប្រព័ន្ធផងដែរ។

៨. គប្បីប្រកាន់យកជំហានទាំងឡាយដែលជួយដល់អ្នកចូលរួមនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យប្រើប្រាស់នូវសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការបង្កើតជាសមាគម ។ ពួកគាត់គួរតែទទួលបានការលើកទឹកចិត្ត ក្នុងការចរចាធ្វើអនុសញ្ញារួម និងក្នុងការបញ្ចុះបញ្ចូលអ្នកតាក់តែងគោលនយោបាយ។ ពួកគាត់ត្រូវតែរៀនសូត្រនូវរបៀបផ្សព្វផ្សាយសំលេង

របស់ខ្លួន ដើម្បីឱ្យមានការយកចិត្តទុកដាក់លើផលប្រយោជន៍ ដែលពួកគាត់ត្រូវការ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ សិទ្ធិមានកម្មសិទ្ធិ ការយកពន្ធ និងសេវាសន្តិសុខសង្គម។ ត្រូវតែធ្វើការជំរុញឱ្យមានការប្រើប្រាស់សហជីព និងសមាគមនិយោជក ក្នុងការជួយសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ សហជីពគួរតែលើកទឹកចិត្តអ្នកធ្វើការក្រៅប្រព័ន្ធឱ្យចូលរួមនៅក្នុងអង្គការរបស់ខ្លួន ឬជួយអ្នកធ្វើការក្រៅប្រព័ន្ធឱ្យបង្កើតសហជីពរបស់ខ្លួនផ្ទាល់ ។

# ឯកសារយោង


Acharya, Sarthi; Sedara, Kim; Chap Sotharith and Meach Yady, 2003 ។ "សកម្មភាព និងការងារក្រៅពីកសិកម្ម និងស្រែចំការ" *ការងារក្រៅពីកសិកម្ម និងស្រែចំការនៅក្នុងសេដ្ឋកិច្ចអន្តរកាលនៅអាស៊ីអាគ្នេយ៍ និងប្រទេសថៃ* ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ទំព័រទី ២១-៩២ ។

Agnello, Francesca; Moller, Joanne និងគណៈកម្មការសរបស់រួលអភិវឌ្ឍន៍ទីក្រុង (USG) ឆ្នាំ ២០០៤។ *កាបូបប្រាក់របស់អ្នកលក់ដូរ : មីក្រូសហគ្រិនជាស្ត្រី និងតំរូវការអាជីវកម្មរបស់ពួកគេ ភ្នំពេញ ប្រទេសកម្ពុជា* ។ ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ។

សមាគមសិប្បករកម្ពុជា (AAC) ឆ្នាំ ២០០៤។ "ការសិក្សាអំពីតំរូវការផ្នែកច្បាប់សំរាប់មីក្រូអាជីវកម្ម និងអាជីវកម្មខ្នាតតូច អង្គការក្រៅរដ្ឋាភិបាល និងសមាគម ព្រមទាំងនីតិវិធី និងបែបបទនាំចេញផលិតផលសិប្បកម្មកម្ពុជា" សេចក្តីព្រាងនៃរបាយការណ៍ដែលរៀបចំសំរាប់គំរោងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងាររបស់អង្គការ ILO ។

Beresford, Melanie; Nguon Sokha; Roy Rathin; Sau Sisovanna; and Namazie, Ceema ឆ្នាំ ២០០៤។ *ម៉ាក្រូសេដ្ឋកិច្ចនៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា* ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP) ។

*សៀវភៅស្ថិតិប្រចាំឆ្នាំកម្ពុជា សំរាប់ឆ្នាំ ២០០៣ វិទ្យាស្ថានជាតិស្ថិតិ* ។

សមាគមកម្ពុជាអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ (CAID) ឆ្នាំ ២០០៤។ "ការអង្កេតទៅលើមុខរបរក្រៅប្រព័ន្ធ ដែលបានជ្រើសរើសជាមុន" ។ សេចក្តីព្រាងនៃរបាយការណ៍ដែលរៀបចំសំរាប់គំរោងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងាររបស់អង្គការ ILO ។

*ពតិមានសហគមន៍* ច្បាប់ចេញផ្សាយលេខ ២ ខែ មិថុនា ឆ្នាំ ២០០៣ បោះពុម្ពផ្សាយដោយមូលនិធិអភិវឌ្ឍន៍អ្នកក្រីក្រ នៅទីក្រុង និងសាមគ្គីភាពដើម្បីសហព័ន្ធអ្នកក្រីក្រនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។

*អង្គការកែច្នៃ និងអនាម័យសហគមន៍ (CSARO)* ។ *របាយការណ៍ប្រចាំឆ្នាំ ១៩៩៩-២000* ។

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) ឆ្នាំ ២00៤ ។ *សំលឹងមើលសេដ្ឋកិច្ចកម្ពុជា* ។

*លទ្ធផលបូកសរុបរយៈពេល ៥ ឆ្នាំ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា* (MOSALVY) ឆ្នាំ ១៩៩៨-២00៣ ។

"សំរាប់អ្នកក្រីក្រនៃប្រទេសកម្ពុជា មីក្រូហិរញ្ញវត្ថុ គឺជាពរជ័យ មិនមែនជាបណ្តាសារទេ" ។ កាសែតឌឹខេមបូឌាដេលី ភ្នំពេញ កម្ពុជា) ថ្ងៃទី ៣ ខែតុលា ឆ្នាំ ២00៥ ទំព័រទី ១៥ ។

Gërxhani, Klarita, ១៩៩៩ ។ "ការអង្កេតលើវិស័យក្រៅប្រព័ន្ធនៅក្នុងបណ្តាប្រទេសអភិវឌ្ឍ និងឧទាភិវឌ្ឍ" ។ *ឯកសារពិភាក្សានៃវិទ្យាស្ថាន Tinbergen* T1 1999-083/2 វិទ្យាស្ថានអាមស្ទែដាមសំរាប់ការសិក្សាជាន់ខ្ពស់អំពីការងារ (AIAS) សាលាអាមស្ទែដាមសំរាប់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រសង្គម (ASSR) និងសកលវិទ្យាល័យអាមស្ទែដាម ទីក្រុងអាមស្ទែដាម ប្រទេសហូឡង់ ។

*កិច្ចសហប្រតិបត្តិការអន្តរជាតិសំរាប់ការអភិវឌ្ឍ និងសាមគ្គីភាពកម្ពុជា (CIDSE Cambodia) របាយការណ៍ប្រចាំឆ្នាំ ២00៣*

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ឆ្នាំ ២00៤ a ។ "ការចុះបញ្ជីក្រុមហ៊ុននៅកម្ពុជា : ហេតុអ្វីក្រុមហ៊ុនឋិតនៅក្រៅប្រព័ន្ធ ?" ។ *ព្រឹត្តិប័ត្រអាជីវកម្ម* លេខ ២ ។

——— ឆ្នាំ ២00៤ b ។ "ឧបសគ្គចំពោះការប្រកួតប្រជែងនៃវិស័យឯកជនកម្ពុជា" *ព្រឹត្តិប័ត្រអាជីវកម្ម* លេខ ៣ ។

អង្គការពលកម្មអន្តរជាតិ **(ILO)** ឆ្នាំ ២000 ។ *របាយការណ៍ស្តីពីការអភិវឌ្ឍមីក្រូសហគ្រាស និងសហគ្រាសធុនតូច ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា* ។ ការិយាល័យពលកម្មអន្តរជាតិប្រចាំនៅទីក្រុងបាងកក ។

——— ឆ្នាំ ២00១ ។ *ការងារសមរម្យនៅអាស៊ី របាយការណ៍របស់អគ្គនាយក* ។ ការិយាល័យ ពលកម្មអន្តរជាតិប្រចាំនៅទីក្រុងហ្សឺណែវ

——— ឆ្នាំ ២00២ a ។ *ការងារសមរម្យ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ របាយការណ៍របស់អគ្គនាយក* ។ ការិយាល័យពលកម្មអន្តរជាតិប្រចាំនៅទីក្រុងហ្សឺណែវ ។

——— ឆ្នាំ ២00២ b ។ *វិស័យក្រៅប្រព័ន្ធនៅអាស៊ីពីទស្សនៈវិស័យនៃការងារសមរម្យ របាយការណ៍របស់អគ្គនាយក* ។ ការិយាល័យពលកម្មអន្តរជាតិប្រចាំនៅទីក្រុងហ្សឺណែវ ។

——— ឆ្នាំ ២00២ c ។ *គាំទ្រអ្នកធ្វើការនៅក្នុងប្រព័ន្ធ : ក្របខ័ណ្ឌគោលនយោបាយ* ។ ការិយាល័យ ពលកម្មអន្តរជាតិប្រចាំនៅទីក្រុងហ្សឺណែវ ។

______ ឆ្នាំ ២០០៤ a ។ *ពលកម្មកុមារបំរើតាមផ្ទះនៅក្នុងប្រទេសកម្ពុជា ហេតុអ្វីត្រូវបញ្ឈប់ពលកម្មកុមារ ហើយតើយើងអាចបញ្ឈប់វាដោយរបៀបណា* ។ (របាយការណ៏នេះអាចរកបានតាមគេហទំព័រ : http://www.ilo.org/public/english/region/asro/bangkok/library/pub1.htm)

______ ឆ្នាំ ២០០៤ b ។ "ល័ក្ខខ័ណ្ឌយោងសំរាប់សៀវភៅណែនាំ ឬវិវេចនានិពន្ធស្តីពីការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា" គំរោងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ភាពក្រីក្រ និងការងារ របស់អង្គការ ILO

Kusakabe, Kyoko; Chan Monnyrath, Chea Sopheap, and Theng Chan Chham, 2001 ។ "មូលធនសង្គមនៃស្ត្រីលក់ដូរតូចតាច នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា) : ការសិក្សាអំពីសមាគមអ្នកលក់ដូរតូចតាច " ។ កម្មវិធីគ្រប់គ្រងទីក្រុង ។

*កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) របាយការណ៏ប្រចាំឆ្នាំ ២០០១*

*កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) របាយការណ៏ប្រចាំឆ្នាំ ២០០២/៣*

"ព្រឹទ្ធសមាជិកនិយាយថា ការអនុវត្តមីក្រូហិរញ្ញវត្ថុមិនបានជួយដល់អ្នកក្រីក្រទេ" កាសែតឌីខេមបូឌាដេលី ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០២ ទំព័រ ១៤ ។

*ក្រសួងអប់រំ យុវជន និងកីឡា របាយការណ៏ប្រចាំឆ្នាំ ២០០២-២០០៣* ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ឆ្នាំ ២០០៣ ។ "ការវាយតំលៃពីវិស័យឯកជនសំរាប់ព្រះរាជាណាចក្រកម្ពុជា" ។ របាយការណ៏សំរាប់ធានាអភិវឌ្ឍន៏អាស៊ី ។

*ក្រសួងផែនការ របាយការណ៏ប្រចាំឆ្នាំ ២០០៣* ។

ក្រសួងផែនការ និងអង្គការ ILO-IPEC ឆ្នាំ ២០០៤ ។ *ការអង្កេតលើអ្នកបំរើនៅតាមផ្ទះជាកុមារនៅក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា* ។ ក្រសួងផែនការ និងការិយាល័យពលកម្មអន្តរជាតិ ។ (របាយការណ៏នេះអាចរកបានតាមគេហទំព័រ : http://www.ilo.org/public/english/region/asro/bangkok/library/pub1.htm)

សាលាក្រុងភ្នំពេញ ឆ្នាំ ១៩៩៩ ។ *យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅទីក្រុងភ្នំពេញ* រៀបចំឡើងក្រោមសេវាគាំទ្រនៃកម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ (UNDP/UNCHS) សំរាប់កម្មវិធីអភិវឌ្ឍន៏ និងគោលនយោបាយ " ក្រុងភ្នំពេញ : ការកំណត់អំពីតំរូវការអាទិភាពក្នុងការគ្រប់គ្រងទីក្រុង ដើម្បីកាត់បន្ថយភាពក្រីក្រនៃទីក្រុង " ។

*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ឆ្នាំ ១៩៩៦-២០០០* ។ ក្រសួងផែនការ ប្រទេសកម្ពុជា

*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ឆ្នាំ ២០០១-២០០៥* ។ ក្រសួងផែនការ ប្រទេសកម្ពុជា

ស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNCHR) ឆ្នាំ ២០០១។ "ស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា" របាយការណ៍នៃតំណាងពិសេសរបស់អគ្គលេខាធិការសហប្រជាជាតិ សំរាប់សិទ្ធិនៅក្នុងប្រទេសកម្ពុជា ដាក់ជូនដោយលោក Peter Leuprecht ស្របតាមសេចក្តីសំរេចលេខ 2000/79 " សម័យប្រជុំលើកទី ៥៧ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ ។

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ឆ្នាំ ២០០៣ ។ *របាយការណ៍ប្រចាំឆ្នាំស្តីពីប្រទេសកម្ពុជា* ។

គណៈកម្មការសំរបសំរួលអភិវឌ្ឍន៍ទីក្រុង (USG) ឆ្នាំ ២០០៣។ "របាយការណ៍វិភាគអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅទីក្រុងភ្នំពេញ"

ក្រសួងការងារសហរដ្ឋអាមេរិក ការិយាល័យកិច្ចការពលកម្មអន្តរជាតិ និងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ឆ្នាំ ២០០៣ ។ *និន្នាការពលកម្មបរទេសនៃប្រទេសកម្ពុជា* ។ ( សូមមើលផងដែរគេហទំព័រ : http://www.dol.gov/ILAB/media/reports/flt/cambodia-2003.htm)

ធនាគារពិភពលោកឆ្នាំ ២០០៤ *កម្ពុជាចាប់យកឱកាសសកល : ការវាយតំលៃអំពីបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកែទំរង់* ។ របាយការណ៍លេខ 27925-KH ។ រៀបចំសំរាប់រាជរដ្ឋាភិបាលកម្ពុជាដោយក្រុមធនាគារពិភពលោក ។

## ឯកសារផ្សេងៗទៀត :

សៀវភៅផ្សព្វផ្សាយរបស់សមាគមសិប្បករកម្ពុជា (AAC)

គំរោងនៃធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិជប៉ុនសំរាប់កាត់បន្ថយភាពក្រីក្រ (ADB/JFPR)

លក្ខន្តិកៈរបស់សមាគមកម្ពុជាអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ (CAID) និងរបាយការណ៍ប្រចាំឆ្នាំ ២០០១-២០០២ ។

កំណត់បង្ហាញសង្ខេបអំពីគំរោងធានារ៉ាប់រងសុខភាពនៃក្រុមអ្នកស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា (GRET)

សេចក្តីពណ៌នាសង្ខេបអំពីគំរូអភិវឌ្ឍន៍សហគមន៍ចំរុះរបស់អង្គការសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (PADEK)

ឯកសារស្ដីពីកម្មវិធីសិលា SEILA ឆ្នាំ ២០០១-២០០៥
សៀវភៅផ្សព្វផ្សាយរបស់មូលនិធិអភិវឌ្ឍន៍អ្នកក្រីក្រនៅទីក្រុង (UPDF)
របាយការណ៍ប្រចាំខែ ឧសភា ឆ្នាំ ២០០៤ មូលនិធិអភិវឌ្ឍន៍អ្នកក្រីក្រនៅទីក្រុង (UPDF)

## វិបសាយ :

*សមាគមសិប្បកម្មកម្ពុជា* – http://www.bigpond.com.kh/users/cambodian-craft/pages/CCC.html

## គេហទំព័ររបស់អង្គការ ILO :

http://www.ilo.org/ilolex/english/recdisp1.htm
http://www.ilo.org/public/english/decent.htm
http://www.ilo.org/public/english/region/asro/bangkok/public/releases/yr2004/pr04_26.hm
សហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (PADEK) http://www.padek.org
មជ្ឈមណ្ឌលស៊ីក្លូភ្នំពេញ - www.cyclo.org.uk
កម្មវិធីសិលា - www.seila.gov.kh
អង្គការ SME Cambodia- http://www.smecambodia.org
ក្រសួងការងារសហរដ្ឋអាមេរិក ការិយាល័យកិច្ចការពលកម្មអន្តរជាតិ និងស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ http://www.dol.gov/ILAB/media/reports/flt/cambodia-2003.htm)